ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល

NGO EDUCATION PARTNERSHIP

# ការជួយដល់កុមារងាយរងគ្រោះ ៖

## ការវាយតំលៃពីកម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះ (HECE) នៅក្នុងប្រទេសកម្ពុជា



២០១៤

Save the Children

អារម្ភកថា

ការជួយដល់កុមារដែលងាយរងគ្រោះគឺជាគោលបំណងរបស់កម្មវិធីជាច្រើននិងគម្រោងជាច្រើននៅជុំវិញពិភពលោក។ ប្រជាជននិងអង្គការដែលបានចូលរួមនៅក្នុងកម្មវិធីដូចនេះសមនឹងទទួលនូវការកោតសរសើរគ្រប់បែបយ៉ាងចំពោះការងាររបស់ពួកគេ ដែលពុំមានគំរូណាប្រសើរជាងការជួយកុមារដែលកំពុងត្រូវការជំនួយទេ។ ហេតុដូច្នេះហើយខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកទាំងឡាយណាដែលបានផ្តល់ឱកាសឱ្យខ្ញុំចូលរួមក្នុងការងាររបស់ពួកគេទោះបីជាការចូលរួមនេះគឺជាការរួមចំណែកដ៏តូចមួយក៏ដោយ។

ទោះបីមានចេតនាប្រកបដោយការគិតគូខ្ពស់ក៏ដោយ ក៏កម្មវិធីត្រូវការការរៀបចំដោយមានការគិតគូរពិចារណាល្អិតល្អន់និងការអនុវត្តន៍ល្អដើម្បីទទួលបានជោគជ័យ។ ការសិក្សានេះមានគោលបំណងវាយតម្លៃកម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជា ដោយពិនិត្យមើលទៅលើការរៀបចំការអនុវត្តន៍ និងឥទ្ធិពល (Impact) របស់គម្រោង។

សមិទ្ធិផលដ៏សំខាន់នៃការសិក្សានេះ គឺជាការណែនាំនូវវិធីសាស្ត្រថ្មីមួយក្នុងការជួយកុមារដែលងាយរងគ្រោះ។ វិធីសាស្ត្រនៃការវាយតម្លៃភាពងាយរងគ្រោះរបស់កុមារ គឺជាឧបករណ៍ដែលមានប្រយោជន៍មួយក្នុងការរៀបចំនិងវាយតម្លៃគម្រោងណាមួយដែលតម្រង់ទៅរកកុមារដែលងាយរងគ្រោះ។

NEPសូមថ្លែងអំណាគុណចំពោះ បណ្ឌិតអាលី អាល់អាឡយស៊ីស ជាអ្នកស្ម័គ្រចិត្តអូស្ត្រាលីនៃគំរោងអភិវឌ្ឍនិអន្តរជាតិ(AVID's) ដែលជាទីប្រឹក្សាស្រាវជ្រាវបានខិតខំប្រឹងប្រែងផលិតនូវពង្រាងរបាយការណ៍លើកដំបូងនេះឡើង។

NEP សូមអរគុណច្រើនចំពោះក្រុមការងាររបស់អង្គការសង្គ្រោះកុមារដែលរួមមាន៖ លោកស្រី ខូយ វ៉ានី ទីប្រឹក្សាគាំពារអប់រំកុមារតូច លោកសំរិទ្ធ ផាន់ណារក្ស មន្ត្រីគំរោងអប់រំ និង លោកសុខ សារេន អតីតមន្ត្រីគំរោងអប់រំសហគមន៍មូលដ្ឋាន និងសេវាសហគមន៍ ជាអ្នកជួយផ្តល់យោបល់ក្នុងការពង្រាងរបាយការណ៍ដំបូង។

សូមអរគុណជាពិសេសចំពោះក្រុមអ្នកស្រាវជ្រាវដែលមានលោកស្រី អាង សុផា មន្ត្រីសំរបសម្រួលកំរោងស្រាវជ្រាវកញ្ញា ឈុំ ស៊ីរ៉ុម មន្ត្រីគម្រោងស្រាវជ្រាវ ព្រមទាំងលោកហ្គរដិន កូណូឈី ជាអ្នកជួយស្វែងរកមូលនិធិនិងជាទីប្រឹក្សាគម្រោងការតស៊ូមតិ លោក ដានីញ៉ែល សែលមុន ទីប្រឹក្សាអប់រំ(NEP) និងលោក ប្រាក់ កុសលប្រធាននាកដ្ឋានអប់រំកុមារតូច ជាអ្នកផ្តល់យោបល់ និងបញ្ចប់របាយការណ៍នេះ ។ លោកជិន ច័ន្ទវាសនានាយកប្រតិបត្តនៃអង្គការ(NEP) បានចំណាយពេលវេលាដ៏មមាញឹកក្នុងជួយពិនិត្យមើលអក្ខរាវិរុទ្ធ នៅក្នុងរបាយការណ៍ចុងក្រោយ។

NEP សូមអរគុណចំពោះមាតាបិតា មន្ត្រីថ្នាក់ស្រុក និងប្រធានភូមិ ដែលបានចូលរួម និងអ្នកទាំងឡាយដែលបានប្តេជ្ញាចិត្តផ្តល់ដំបូន្មាន ឬ យោបល់ដើម្បីកែលម្អការសិក្សានេះ។

សូមថ្លែងអំណរគុណចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុពីអង្គការសង្គ្រោះកុមារ (SC) ដែលធ្វើឲ្យអង្គការ NEP មានលទ្ធភាពរៀបចំការសិក្សា និងបោះពុម្ពផ្សាយនូវរបាយការណ៍នេះ។

មាតិកា


អារម្ភកថា ....................................................................................................................................................២
មាតិកា ..........................................................................................................................................................៣
បញ្ជីតារាងនិងតួរលេខ ...............................................................................................................................៤
អក្សរកាត់និងពាក្យកាត់ ...............................................................................................................................៥

សេចក្តីផ្តើម ...................................................................................................................................................៦
១. កម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះ៖ បទពិសោធន៍ថ្នាក់អន្តរជាតិ ..........................................................៧

២ . កម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជា៖ .................................................................១២
៣ . ការវាយតម្លៃពីភាពងាយរងគ្រោះរបស់កុមារ ..........................................................................................១៦
៤.  ការពិនិត្យមើលការពិត ៖ ការរកឃើញពីការសង្កេត ...............................................................................១៩
៥ . ការវាយតម្លៃពីកម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះ .......................................................................................៤២
៦.  ការពិភាក្សាចុងក្រោយនិងអនុសាសន៍ ........................................................................................................៤៩

ឯកសារយោង

បញ្ជីរតារាង និងតួលេខ

រូបភាពទី ១: ក្របខ័ណ្ឌផ្នែកគោលគំនិតដែលបានអនុវត្តរបស់កម្មវិធី HIPPY
រូបភាព ២: យន្តការនៃតំណើរការរបស់កម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះ
រូបភាពទី ៣: ការគ្រប់គ្រងការថែរក្សាកុមារតូចនៅតាមខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជា
តារាងទី ១- ស្ថិតិកម្មវិធីតាមខ្នងផ្ទះសម្រាប់ឆ្នាំ ២០១២-២០១៣
តារាងទី២ ៖ ព័ត៌មានទូទៅនៅតាមភូមិ
តារាងទី ៣ - ពត៌មានទូទៅរបស់ប្រធានភូមិ
តារាងទី ៤ - ពត៌មានរបស់ប្រធានក្រុមម៉ែ
តារាងទី ៥ - សម្ភារៈសម្រាប់ម៉ែ និងលក្ខខណ្ឌនៅតាមផ្ទះ
តារាងទី ៦- ប្រវត្តិនៃការអប់រំ និងការងាររបស់ម៉ែ
តារាងទី ៧ - ស្ថានភាពសេដ្ឋកិច្ចរបស់ម៉ែ
តារាងទី ៨ - ការចូលរួមរបស់ម៉ែនៅក្នុងកម្មវិធីអបរំកុមារតូច
តារាងទី ៩- កុមារដែលបានវាយតម្លៃតាមរយៈការសិក្សានេះ - អាយុ ការចុះឈ្មោះចូលរៀន ពិការភាព ជំងឺរ៉ាំរ៉ៃ និងសុខភាព
តារាងទី ១០ - ពិន្ទុនៃការវាយតំលៃភាពងាយរងគ្រោះរបស់កុមារ
តារាងទី ១១ - កម្រិតនៃភាពងាយរងគ្រោះរបស់កុមារ
យោងទៅតាមការវាយតម្លៃពីភាពងាយរងគ្រោះរបស់កុមារ
តារាងទី ១២ - ការដាក់ពិន្ទុទៅលើកត្តាអថេរនៃការអប់រំ
តារាងទី១៣ ការដាក់ពិន្ទុទៅលើកត្តាអថេរនៃភាពក្រីក្រ
តារាងទី ១៤ - ការដាក់ពិន្ទុទៅលើកត្តាអថេរនៃភាពឯកោ
តារាងទី ១៥ - ការដាក់ពិន្ទុទៅលើកត្តាអថេរផ្នែកសុខភាព
តារាងទី១៦- ភាពងាយរងគ្រោះរបស់កុមារដែលមានអាយុពី ៣-៥ឆ្នាំ ដោយយោងទៅតាមការទទួលបាននូវកម្មវិធីសាលាមតេយ្យរបស់ខ្លួន
តារាងទី ១៧ - ភាពងាយរងគ្រោះរបស់កុមារនៅតាមភូមិដែលបានអនុវត្តកម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះ និងភូមិដែលមិនបានអនុវត្តកម្មវិធីនេះ

## អក្សរកាត់ និង ពាក្យកាត់

| | |
|---|---|
| CCDP | កម្មវិធីអភិវឌ្ឍកុមារដ៏ទូលំទូលាយ |
| HCEEP | កម្មវិធីអប់រំកុមារពិការដំណាក់កាលដំបូង |
| HECE | កម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះ |
| HIPPY | កម្មវិធីណែនាំសម្រាប់កុមាររៀននៅមតេយ្យសិក្សា (Home Instruction Program for Preschool Youngsters′) |
| HOPE | ការពង្រឹងអំណាចរបស់ឪពុកម្តាយ (Hand-On Parent Power) |
| KM | គីឡូម៉ែត្រ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| PAT | ឪពុកម្តាយមានតួនាទីជាគ្រូបង្រៀន |
| PEEP | ភាពជាដៃគូអប់រំកុមារតូចតាមលក្ខណៈមិត្តអប់រំមិត្ត (Peer Early EducationPartnership) |
| SCI | អង្គការសង្គ្រោះកុមារអន្តរជាតិ |

## សេចក្តីផ្តើម

ពុំមានសំណួរអ្វី ថាបរិយាកាសនៃការអប់រំកុមារតូច ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍន៍ ផ្នែករាងកាយ និងផ្លូវចិត្តរបស់កុមារ។ ដូច្នេះទើបមានកម្មវិធីយ៉ាងច្រើន ត្រូវបានគេណែនាំនៅជុំវិញពិភពលោកដើម្បីដោះស្រាយបញ្ហាទាក់ទង នឹងបរិយាកាសល្អនៅក្នុងគ្រួសារ ជាពិសេសសម្រាប់កុមារដែលស្ថិតនៅក្នុងស្ថាន ភាពងាយរងគ្រោះ និងជួបការលំបាក។ ស្ថិតនៅក្នុងដំណាក់កាលនៃការចាប់ផ្តើមសារជាថ្មី ក្រោយពីការដួលរលំរបបខ្មែរក្រហម ប្រទេសកម្ពុជា បានបង្ហាញឲ្យឃើញនូវការចាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះការដោះស្រាយនូវបញ្ហាការអប់រំកុមារតូច ហើយបានស្វែងរកជំនួយពីអង្គការអន្តរជាតិជាច្រើន។

អ្វីៗគ្រប់យ៉ាងនៅក្នុងប្រទេសកម្ពុជាត្រូវបានគេចងចាំនូវអតីតកាល និងការខ្វះធនធាន។ វិស័យអប់រំក៏មិនការពឹងទុកដូចគ្នានេះដែរ។ ភាពចាំបាច់នៃការកើនឡើងនូវមនុស្សជំនាន់ថ្មី ដែលមានសមត្ថភាពនៅក្នុងការកសាងប្រទេសរបស់ខ្លួន និងរៀនសូត្រពីបទពិសោធន៍ពីអតីតកាល គឺជាភារកិច្ចដ៏ចម្បងរបស់រដ្ឋាភិបាលកម្ពុជា។

ផ្អែកតាមរបាយការណ៍សន្និបាតរបស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០១២-២០១៣ បានបង្ហាញថាមត្តេយ្យសិក្សាមាន ៥,៤៧០ កើន ៣៤៥សាលា/កន្លែង ក្នុងនោះមត្តេយ្យសិក្សារដ្ឋមាន ២,៨១៣ កើន ២៣៨សាលា/កន្លែង (មត្តេយ្យសិក្សាដាច់ដោយឡែក ២០២ កើន ៥) មត្តេយ្យសិក្សាឯកជនមាន ៣៤៨ កើន ១១៧សាលា និងមត្តេយ្យសិក្សាសហគមន៍ ២, ៣០៩កន្លែង ថយ ១០កន្លែង។ ថ្នាក់រៀនមាន ៨, ០៩០ កើន ៧០១ ក្នុងនោះថ្នាក់មត្តេយ្យសិក្សារដ្ឋមាន ៤, ២៤៨ កើន ២៤២ មត្តេយ្យសិក្សាឯកជនមាន ១, ៤២៣ កើន ៥០៩ និងមត្តេយ្យសិក្សាសហគមន៍មាន ២, ៤១៩ ថយ ៥០ថ្នាក់។

កុមារអាយុពី ០ ទៅក្រោម ៦ឆ្នាំ បានទទួលសេវាអប់រំមាន ៣១១, ១៥៤នាក់ ស្មើនឹង ១៦,៨០ភាគរយនៃក្រុមអាយុ ស្រី ៤៩,៩៨ភាគរយ។ កុមារអាយុពី ០ ទៅក្រោម ៣ឆ្នាំមាន ៣០ ៩៦៣នាក់ ស្មើនឹង ៣,១៩ ភាគរយនៃក្រុមអាយុ ស្រី ៤៩,៩៨ភាគរយ។ កុមារអាយុ៣ និង ៤ឆ្នាំមាន ១២២, ៩៦៥នាក់ ស្មើនឹង ២១,២៣ ភាគរយនៃក្រុមអាយុស្រី ៥០,៥៨ភាគរយ។ កុមារអាយុ ៥ឆ្នាំ មាន ១៥៧, ២២៦នាក់ ស្មើនឹង ៥៦,៤៩ ភាគរយ នៃក្រុមអាយុ ស្រី ៤៩,៥០ភាគរយ (ចំណុចដៅ ESP ៥៥ ភាគរយ )។

ការអប់រំកុមារតូចតាមផ្ទះ និងក្រុមអប់រំតាមកុមារតូចតាមខ្នងផ្ទះមាន ១៧៦ ក្រុង ស្រុក ខណ្ឌ។ ឪពុកម្តាយ ឬអាណា ព្យាបាលកុមារចូលរួមកម្មវិធីមាន ៥១, ៤៣៥នាក់ ម៉ែបង្គោលមាន ២, ១២៤នាក់ និងកុមារមាន ៧៦, ២០៧ នាក់ ស្រី ៤៩,៨០ភាគរយ។ កុមារមត្តេយ្យសិក្សាកម្រិតខ្ពស់អាយុ ៥ឆ្នាំបានបញ្ចប់ការសិក្សា ១៥៦, ១០៧ នាក់ ស្រី ៥០,៦៣ភាគរយ កើន ៣៨, ២៧១នាក់។

ការសិក្សានេះត្រូវបានបែងចែកទៅតាកជំពូកផ្សេងៗដូចខាងក្រោម ៖

១. កម្មវិធីអប់រំតាមខ្នងផ្ទះ៖ បទពិសោធន៍ថ្នាក់អន្តរជាតិ

២. កម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជា

៣. ការវាយតម្លៃភាពងាយរងគ្រោះរបស់កុមារ

៤. ការពិនិត្យមើលការពិត ៖ លទ្ធផលរកឃើញពីការសង្កេត

៥. ការវាយតម្លៃកម្មវិធីអប់រំតាមខ្នងផ្ទះ

៦. ការពិភាក្សា និងអនុសាសន៍ចុងក្រោយ

## **១. កម្មវិធីអប់រំតាមខ្នងផ្ទះ** ៖ បទពិសោធន៍អន្តរជាតិ

សង្គមវិទូ និងចិត្តវិទូបានឯកភាព ចំពោះតម្លៃដ៏ខ្ពស់នៃការវិភាគពីទំនាក់ទំនងទៅវិញទៅមកយ៉ាងជិតស្និទ រវាងកុមារនិង និងបរិយាកាសរូបវន្តែ និងសង្គមរបស់ពួកវា (Ford និង Lerner ឆ្នាំ ១៩៩២ Mangnusson ឆ្នាំ ១៩៩៥;Wachs,១៩៩២, ២000)។ ពុំមានចំណុចយល់ស្របណាមួយ ពីសារៈសំខាន់នៃការអប់រំតាមផ្ទះ សម្រាប់ការសិក្សារៀនសូត្ររបស់កុមារ និងឥទ្ធិពលរបស់វាដែលជាកត្តាដ៏ចំបងមួយចំពោះការអភិវឌ្ឍន៍ របស់កុមារទេ(Iltus២00៦)។ នៅក្នុងរយៈពេលប៉ុន្មានដំបូងរបស់កុមារ ឪពុកម្តាយដើរតួនាទីយ៉ាងសំខាន់មួយចំពោះការអភិវឌ្ឍន៍របស់កូនខ្លួន ស្របតាមបរិយាកាសជុំវិញ ហើយឪពុកម្តាយ គឺជាមនុស្សដ៏សំខាន់ដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយកូនៗរបស់ខ្លួននៅក្នុងរយៈពេលប៉ុន្មានឆ្នាំដំបូងនៃជីវិតរបស់កុមារ។ Bronfernbrenner បានរៀបរាប់ពីទំនាក់ទំនងទាំងនេះថាជាៈ "ការអភិវឌ្ឍន៍ដំបូងរបស់កុមារ" (Bronfernbrenner, ១៩៩៨)។ ការយល់ដឹងពីបញ្ហា បទពិសោធន៏ផ្នែកកុមារតូច និង ឥទ្ធិពលរបស់វាទៅលើការអភិវឌ្ឍមនុស្សពីសំណាក់អ្នកអប់រំ អ្នកនយោបាយ និងឪពុកម្តាយបានធ្វើឱ្យ បញ្ហាទាំងនេះស្ថិតនៅផ្នែកខាងលើនៃរបៀបវារៈជាសារធារណៈនៅក្នុងប្រទេសជាច្រើន។ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិបានបង្កើតគំនិតផ្តួចផ្តើមក្នុងការអនុវត្តគម្រោង និងកម្មវិធីជាច្រើនដែលទាក់ទងទៅនឹងបញ្ហានៃការបង្កើតបរិយាកាសដ៏ត្រឹមត្រូវសម្រាប់ការអភិវឌ្ឍរបស់កុមារ។ កម្មវិធីអបរ់តាមខ្នងផ្ទះ គឺកម្មវិធីមួយក្នុងចំណោមកម្មវិធីទាំងនេះ។

Sarah Miller ដែលអញ្ជើញមកពីមជ្ឈមណ្ឌលសម្រាប់ការអប់រំប្រកបដោយប្រសិទ្ធភាព នៃសាកលវិទ្យាល័យ queen Belfast បានពិព៌ណ៌នាពីគោលបំណងផ្សេងៗរបស់កម្មវិធីនេះថា "ដើម្បីធ្វើឲ្យប្រសើរបំផុត ចំពោះលទ្ធផលនៃការអភិវឌ្ឍន៍របស់កុមារ តាមរយៈការអប់រំ ការបណ្តុះបណ្តាល និងការគាំទ្ររបស់ឪពុកម្តាយនៅផ្ទះរបស់ពួកគាត់ផ្ទាល់ ដើម្បីផ្តល់នូវបរិយាកាសនៃអប់រំនិងការជំរុញបន្ថែមទៀតសម្រាប់កូនរបស់ពួកគាត់" (Miller ២០១២)។ ឬតាមសំដីរបស់ Christine Powell កម្មវិធីអប់រំតាមខ្នងផ្ទះត្រូវបានគេ "តម្រង់ទិសទៅរកការកែលំអរស្ថានភាពនៃការអភិវឌ្ឍន៍របស់កុមារ តាមរយៈការពង្រឹងការអប់រំកុមារ និងថែរក្សាកុមារនៅតាមផ្ទះ " ហើយលោកស្រីបានបន្ថែមទៀតថា ទោះជាចំណុចរបស់កម្មវិធីមានឪពុកម្តាយ និងកុមារក៏ដោយ ប៉ុន្តែ

ផលប្រយោជន៍ នឹងសាយភាយដល់កុមារផ្សេងទៀតនៅក្នុងគ្រួសារ ហើយក៏អាចមានលទ្ធភាពសាយភាយដល់អ្នកជិតខាងផងដែរ។ គេក៏សង្ឃឹមដែរថា ឪពុកម្តាយ នឹងពាំនាំនូវផលប្រយោជន៍សម្រាប់ខ្លួនគាត់ផ្ទាល់ ហើយកម្មវិធីជាច្រើនរាប់បញ្ចូលទាំងសកម្មភាពផ្សេងៗ ដើម្បីជួយឪពុកម្តាយឲ្យអភិវឌ្ឍន៍នូវគោលគំនិតផ្ទាល់ខ្លួនជាវិជ្ជមានច្រើនថែមទៀត មានអារម្មណ៍ថាមានសុវត្ថិភាព និងការបណ្តុះបណ្តាលផ្នែកជំនាញ (Powell ១៩៩៩)។ ហេតុដូច្នេះហើយកម្មវិធីអប់រំតាមខ្នងផ្ទះ គឺជាការតម្រង់ទិសទៅរកកុមារ ក៏ដូចជាឪពុកម្តាយបង្កើតនូវបរិយាកាសតាមផ្ទះ ដែលមានអំណោយផលមួយសម្រាប់ការអភិវឌ្ឍន៍ផ្នែករាងកាយ បង្កើតចិត្តគំនិត និងការអប់រំរបស់កុមារ (Miller ឆ្នាំ ២០១២)។

កម្មវិធីអប់រំតាមខ្នងផ្ទះមានចំនួន២ប្រភេទៈ ទី១ កម្មវិធីអន្តរាគមន៍ដល់កុមារតូចតាមខ្នងផ្ទះ គឺមានគោលដៅទៅរកការជួយដល់ឪពុកម្តាយការថែរក្សាកូនរបស់ខ្លួនដែលស្ថិតនៅក្នុងហានិភ័យ ដូចជាកុមារពិការជាដើម។ កម្មវិធីអប់រំកុមារតូចដែលពិការ (HCEEP) នៅសហរដ្ឋអាមេរិក គឺជាឧទាហរណ៍មួយនៃកម្មវិធីទាំងនេះ (white ឆ្នាំ ១៩៩២)។ ទី២ កម្មវិធីអប់រំតាមខ្នងផ្ទះដែលគោលដៅទៅរកការជួយកុមារដែលងាយរងគ្រោះ កុមារដែលងាយរងគ្រោះដោយសារកត្តាផ្សេងៗ ភាពក្រីក្រ និងការមិនទទួលផលប្រយោជន៍ (field ២០១០) (Marmotឆ្នាំ២០១២)។ កម្មវិធីអប់រំតាមខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជា មានទិសដៅស្រដៀងគ្នាទៅនឹងកម្មវិធីប្រភេទនេះដែរ។

លក្ខណៈខុសគ្នារវាងកម្មវិធីទាំងពីរប្រភេទនេះ គឺទ្រឹស្តី និងការអនុវត្តជាក់ស្តែង។ នៅក្នុងទិដ្ឋភាពផ្នែកទ្រឹស្តីកម្មវិធីទាំងនេះមានវិធីសាស្ត្រផ្នែកគោលគំនិតខុសគ្នា ក្នុងពេលដែលកម្មវិធីអប់រំដោះស្រាយនូវគោលគំនិតនៃភាពងាយរងគ្រោះ កម្មវិធីនៃការធ្វើអន្តរាគមន៍ដោះស្រាយនូវគោលគំនិតនៃការគំរាមកំហែង និងហានិភ័យ។ នៅក្នុងទិដ្ឋភាពជាក់ស្តែង អ្នកស្រាវជ្រាវបានអះអាងថា កម្មវិធីនៃការធ្វើអន្តរាគមន៍ គឺតម្រង់ទៅរកកុមារដែលមានហានិភ័យរួចហើយ និងស្ថិតនៅក្នុងស្ថានភាពនៃភាពងាយរងគ្រោះ ចំណែកឯកម្មវិធីអប់រំ គឺតម្រង់ទៅរកកុមារដើម្បីការពារពួកគេ កុំឲ្យធ្លាក់ទៅក្នុងហានិភ័យ។ ក្នុងពេលជាមួយគ្នានេះដែរ ការលើកទឹកចិត្តរបស់ឪពុកម្តាយឲ្យចូលរួមតាមកម្មវិធីនីមួយៗ គឺមានភាពខុសគ្នា។ ការចូលរួមរបស់ឪពុកម្តាយក្នុងកម្មវិធីអន្តរាគមន៍ គឺកើតចេញពីតម្រូវការ និងការព្យាយាមសម្រេចឲ្យបាននូវការផ្តល់ជំនួយ(white ឆ្នាំ១៩៩២) ចំណែកឯការចូលរួមរបស់ឪពុកម្តាយនៅក្នុងកម្មវិធីអប់រំ ពុំបានយល់ដឹងពីតម្រូវការសម្រាប់កម្មវិធីនេះទេ ហើយមានការលើកទឹកចិត្តតិចតួចនៅក្នុងការចូលរួមក្នុងសកម្មភាពរបស់កម្មវិធី។

កម្មវិធីណែនាំតាមផ្ទះសម្រាប់កុមារនៅសាលាមតេយ្យ (HIPPY) គឺជាកម្មវិធីអប់រំតាមខ្នងផ្ទះដែលគេទទួលស្គាល់ ជាអន្តរជាតិច្រើនបំផុតនៅក្នុងពិភពលោក។ HIPPY គឺជាកម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះដែលមានរយៈពេល២ឆ្នាំដែលតម្រង់ទៅរក "ការជួយឪពុកម្តាយដែលមានការអប់រំជាផ្លូវការតិចតួច ដើម្បីរៀបចំកូនៗដែលមានអាយុ ៤-៥ ឆ្នាំឲ្យចូលសាលារៀន" (លោក Baker ១៩៩៩)។ កម្មវិធីនេះត្រូវបានបង្កើតឡើងជាលើកដំបូងនៅក្នុងប្រទេសអ៊ីស្រាអែលក្នុងឆ្នាំ ១៩៦៩។ ក្រោយមកទៀតកម្មវិធីនេះត្រូវបានគេនាំយកទៅកាន់សហរដ្ឋអាមេរិចក្នុងឆ្នាំ១៩៧៤ (លោក Baker ១៩៩៩) និងទៅកាន់ប្រទេសផ្សេងទៀត ដូចជាចក្រភពអង់គ្លេស NZ ក្រុងហុងកុង និងប្រទេសកាណាដា។ នៅក្នុងករណីជាច្រើន កម្មវិធីត្រូវបានអនុវត្តដោយមាន

ឈ្មោះខុសៗគ្នា ដូចជាភាពជាដៃគូអប់រំ Peer early education partnership (PEEP) ការពង្រឹងអំណាចឪពុកម្តាយ (Hand on Parent Empowerment) កម្មវិធីអភិវឌ្ឍកុមារទូលំទូលាយ (CCDP) ឪពុកម្តាយដើរតួនាទីជាគ្រូបង្រៀន (PAT) និងកម្មវិធីភាពជាឪពុកម្តាយភាពជាវិជ្ជមាន (Leung ២០១១)។ លក្ខណៈទូទៅក្នុងចំណោមកម្មវិធីទាំងអស់នេះ ថាកម្មវិធីទាំងនេះមិនត្រឹមតែមានទិសដៅដូចគ្នាទេ ប៉ុន្តែវាអ្នកទទួលផលស្រដៀងគ្នាដែរ។ អ្នកទទួលផលភាគច្រើនពីកម្មវិធី គឺមកពីគ្រួសារក្រីក្រ មានការលំបាក ចំពោះការអប់រំកូនរបស់ខ្លួនឬ / និងមានការលំបាក ក្នុងការទទួលបានសេវាសារធារណៈ ដោយសារអ្នកទាំងនោះទទួលរងការឈឺចាប់ពីការផាត់ចេញរបស់សង្គមក្នុងប្រភេទណាមួយ។ (Leung ២០១១)

Amy Baker បានពន្យល់ពីធាតុសំខាន់ៗនៃចក្ខុវិស័យរបស់កម្មវិធី HIPPY សហរដ្ឋអាមេរិកថា (មានការចុះត្រួតពិនិត្យតាមផ្ទះជារៀងរាល់២ខែម្តង ពីសំណាក់អ្នកមានជំនាញវិជ្ជាជីវៈ (paraprofessional) ដោយបន្ថែមទៅលើការប្រជុំតាមសប្តាហ៍ជាមួយម៉ែៗ និងអ្នកមានជំនាញវិជ្ជាជីវៈ(paraprofessional) ដែលដឹកនាំដោយអ្នកសម្របសម្រួលកម្មវិធី HIPPY ដែលមានជំនាញវិជ្ជាជីវៈ (លោក Baker ១៩៩៩)។ មានហេតុផលចំនួន២ដែល Avima Lombard ជាស្ថាបនិករបស់កម្មវិធីបានជ្រើសរើសយកការត្រួតពិនិត្យធ្វើជាវិធីសាស្ត្រនៃការផ្តល់កម្មវិធី៖ ទី១ ដើម្បីធានាបាននូវការចូលរួមរបស់ឪពុកម្តាយ ទី២ ដើម្បីធ្វើឲ្យម្នាក់ៗបានយល់ពីខ្លឹមសារព័ត៌មានរបស់ម៉ែៗត្រូវការ និង ទី៣ដើម្បីបង្កើតទំនាក់ទំនងផ្ទាល់ខ្លួនជាមួយពួកគេ(Baker,១៩៩៩) ។

ក្នុងពេលចុះពិនិត្យគេបានផ្តល់ឲ្យឪពុកម្តាយនូវព័ត៌មាន ដើម្បីជួយពួកគាត់ឲ្យដោះស្រាយនូវការអភិវឌ្ឍន៍ ផ្នែកបញ្ញា សង្គម និងផ្លូវចិត្តរបស់កូនៗរបស់គាត់ ព្រមទាំងទទួលនូវការណែនាំពីរបៀបដែលគេប្រើប្រាស់សកម្ម ក្នុងនាមជាឪពុកម្តាយប្រចាំថ្ងៃរបស់ខ្លួន ដើម្បីធ្វើឲ្យមានការរីកចំរើនដល់ការអភិវឌ្ឍន៍របស់កូន។ ជាងនេះទៅទៀតឪពុកម្តាយនឹងទទួលបាននូវជំនួន្ទានផ្នែកជំនាញវិជ្ជាជីវៈ ដើម្បីកែលំអរជំនាញ ភាពជាឪពុកម្តាយរបស់ខ្លួនព្រមទាំងនូវទង្វើល្អរបស់ឪពុកម្តាយ នឹងមានឥទ្ធិពលជាវិជ្ជមានទៅលើអាកប្បកិរិយារបស់ខ្លួន (Miller ឆ្នាំ ២០១២)។ ដូច្នេះការស្នើឡើងនូវការចុះត្រួតពិនិត្យតាមផ្ទះ គឺលើសពីអ្វីដែលជាការផ្តល់ព័ត៌មាន ទៅឲ្យឪពុកម្តាយទៅទៀត។ គេតម្រង់ទៅរកការលើកចិត្តឪពុកម្តាយឲ្យមានចេតនាមានទំនាក់ទំនងជាមួយកូនរបស់ខ្លួន និងផ្តល់ឲ្យពួកគេ នូវការបណ្តុះបណ្តាល និងឧបករណ៍ផ្សេងៗ ដែលអាចធ្វើបានដូចជា (Westheimer ឆ្នាំ១៩៩៧)។ រូបភាពទី១ ដែលបង្ហាញពីក្របខ័ណ្ឌការងារដែលជាគោលគំនិតនៃកម្មវិធី HIPPY នៅក្នុងទស្សនៈវិស័យរបស់អាមេរិក។

រូបភាពទី ១៖ ក្របខ័ណ្ឌគោលគំនិតរបស់កម្មវិធី HIPPYដែលបានអនុវត្ត




ប្រភព៖ (Baker ១៩៩៩)

ភាពជោគជ័យរបស់កម្មវិធីអប់រំតាមខ្នងផ្ទះ គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើកម្រិតនៃការចូលរួមរបស់ឪពុកម្តាយ។ Korfmacher (២០០៨) បានពន្យល់ពីពាក្យនៃការចូលរួមរបស់ឪពុកម្តាយថាជា "ដំណើរការនៃការតភ្ជាប់របស់ឪពុកម្តាយ និងការប្រើប្រាស់សេវាកម្ម សកម្មល្អបំផុត នៃសមត្ថភាពរបស់ឪពុកម្តាយ និងកម្មវិធី"។ មានកត្តាចំនួន៣ ដែលមានឥទ្ធិពលទៅលើការចូលរួមរបស់ឪពុកម្តាយ គឺចរិកលក្ខណៈរបស់ឪពុកម្តាយ លក្ខណៈសម្បត្តិរបស់អ្នកចុះត្រួតពិនិត្យ និងលក្ខណៈរបស់កម្មវិធី (Korfmacher ២០០៨)។ Barker បានសន្និដ្ឋានពីបទពិសោធន៍ជាក់ស្តែងដ៏យូរលង់របស់ខ្លួនតាមរយៈការធ្វើការក្នុងកម្មវិធីការអប់រំតាមខ្នងផ្ទះ ដែលការចូលរួមរបស់ឪពុកម្តាយ និងការលើកសរសើរ ចំពោះសកម្មភាពនៃការចុះត្រួតពិនិត្យតាមផ្ទះ គឺលើសពីសកម្មភាពដទៃទៀតដូចជា ការរៀបចំប្រជុំតាមក្រុម។ លោកស្រីក៏បានរកឃើញដែរថា គ្រួសារភាគច្រើនបានចូលរួមតែនៅក្នុងសកម្មភាពដែលកើតឡើងនៅខាងក្នុងផ្ទះរបស់ខ្លួនតែប៉ុណ្ណោះ ប៉ុន្តែមានតែឪពុកម្តាយមួយក្រុមតូចប៉ុណ្ណោះដែលបានចូលរួមក្នុងកិច្ចប្រជុំក្រុម ដែលរៀបចំឡើងរៀងរាល់២សប្តាហ៍ម្តង( Baker ១៩៩៩)។

ផ្នែកផ្សេងទៀតនៃភាពជោគជ័យរបស់កម្មវិធីអប់រំតាមខ្នងផ្ទះ គឺតួនាទីរបស់អ្នកមានជំនាញវិជ្ជាជីវៈនៅក្នុងការអនុវត្តកម្មវិធី។ អ្នកសម្របសម្រួលនិងបុគ្គលិកដែលមានជំនាញវិជ្ជាជីវៈរបស់កម្មវិធី ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអនុវត្តន៍កម្មវិធី HIPPY។ អ្នកសម្របសម្រួលទទួលខុសត្រូវលើការប្រតិបត្តិការទូទៅរបស់កម្មវិធី នៅក្នុងផ្នែករបស់ខ្លួនផ្ទាល់។ អ្នកសម្របសម្រួលភាគច្រើនមានប្រវត្តិលើកការងារអប់រំកុមារតូច មានបទពិសោធន៍ក្នុងការបង្រៀន ឬមានបទពិសោធន៍ជាភ្នាក់ងារសង្គម។ អ្នកទាំងនោះទទួលខុសត្រូវ ចំពោះការជ្រើសឪពុកម្តាយដែលជាអ្នកចូលរួម និងអ្នកមានជំនាញវិជ្ជាជីវៈសម្រាប់កម្មវិធីបណ្តុះបណ្តាល អ្នកមានជំនាញវិជ្ជាជីវៈនិងត្រួតពិនិត្យ។ អ្នកមានជំនាញវិជ្ជាជីវៈជាទូទៅ គឺជាក្រុមដឹកនាំម៉ែៗ ដែលអ្នកសម្របសម្រួលបានជ្រើសរើសហើយអ្នកទាំងនោះមានការទទួលខុសត្រូវលើការចុះត្រួតពិនិត្យតាមផ្ទះ។ នៅក្នុងករណីនៃកម្មវិធីរបស់PAT អ្នក

ទាំងនោះគឺជាអ្នកអប់រំដែលទទួលបានការបណ្តុះបណ្តាល និងមានលិខិតទទួលស្គាល់ (Wagner, ១៩៩៩)។ Miriam Westhemier ដែលបានបម្រើការងារនៅក្នុងកម្មវិធី HIPPY បានពិព័ណ៌នាអំពីការងាររបស់អ្នកដែលមានជំនាញវិជ្ជាជីវៈថា៖ "ជាធម្មតាអ្នកដែលមានជំនាញវិជ្ជាជីវៈធ្វើការរហូតដល់ទៅ ២០ម៉ោងក្នុងមួយសប្តាហ៍។ ពួកគាត់ម្នាក់ៗទទួលខុសត្រូវ ចំពោះការណែនាំដល់ក្រុមម៉ែៗមួយក្រុមមានសមាជិកចំនួន១០-១២នាក់ពីរបៀបប្រើប្រាស់សម្ភារៈ HIPPY ជាមួយកូនៗរបស់ខ្លួន និងទទួលខុសត្រូវចំពោះការត្រួតពិនិត្យវឌ្ឍនភាពរបស់គ្រួសារនីមួយៗរបស់កម្មវិធីពេញមួយឆ្នាំ....។ អ្នកមានជំនាញវិជ្ជាជីវៈជួបប្រជុំគ្នាជាក្រុមរៀងរាល់សប្តាហ៍ជាមួយនឹងអ្នកសម្របសម្រួលតាមមូលដ្ឋាន។ គោលបំណងនៃការប្រជុំ គឺដើម្បីសំដែងតួដោយប្រើប្រាស់សម្ភារៈផ្សេងៗ ដើម្បីរាយការណ៍និងពិភាក្សាពីការងារប្រចាំសប្តាហ៍កន្លងមក ព្រមទាំងចែករំលែកនូវបទពិសោធន៍ និងបញ្ហាផ្សេងៗ" (Westheimer ឆ្នាំ ១៩៩៧) ។

បើទោះបីជាមូលដ្ឋានផ្នែកទ្រឹស្តីរបស់កម្មវិធីអប់រំតាមខ្នងផ្ទះមានចំណុចល្អ ក៏ដោយ(Baenett ឆ្នាំ ២០១២) ការវាយតម្លៃទៅលើប្រសិទ្ធភាពរបស់កម្មវិធីបានរកឃើញនូវភាពចម្រូងចម្រាស់។ អ្នកស្រាវជ្រាវមួយចំនួនដូចជា Sheila Brooke បានអះអាងថា ការស្រាវជ្រាវលើកម្មវិធីចុះត្រួតពិនិត្យតាមផ្ទះ បានបង្ហាញនូវលទ្ធផលដែលមានការខកចិត្ត ហើយបានអះអាងថា "ការសិក្សាទូទៅផ្សេងៗ ចង្អុលបង្ហាញនូវឥទ្ធិពលរយៈពេលវែងតិចតួចទៅលើគ្រួសារនិងកុមារ" (Brooke, ២០០៦)។ Wagner និង Clayton បានសន្និដ្ឋាននៅក្នុងការសិក្សារបស់ខ្លួននៅក្នុងរដ្ឋចំនួនពីរ នៅសហរដ្ឋអាមេរិកដែលបានវាយតម្លៃទៅលើកម្មវិធីឪពុកម្តាយជាជាគ្រូបង្រៀន(PAT) បានចង្អុលបង្ហាញឲ្យឃើញនូវលទ្ធផលតិចតួចទៅលើចំណេះដឹងឪពុកម្តាយ និងពុំមានឥទ្ធិពលទាល់តែសោះទៅលើការអភិវឌ្ឍន៍របស់កុមារ(Wagner១៩៩៩)។

ផ្ទុយទៅវិញ Baker បានធ្វើការវាយតម្លៃមួយទៅលើកម្មវិធី HIPPY នៅញូវយ៉កនិង Arkansas ទាក់ទងនឹងលទ្ធផលនៃការសិក្សារបស់កុមារនៅសាលារៀន។ លោកស្រីបានរកឃើញពីឥទ្ធិពលរបស់ HIPPY នៅលើឥទ្ធិពលរបស់សាលាមតេយ្យ (Baker ១៩៩៨)។ ការវាយតម្លៃមួយសម្រាប់កុមារដែលបានចូលរួមនៅក្នុងកម្មវិធី PEEP បានសន្និដ្ឋានថា "បន្ទាប់ពីរយៈពេលពីរឆ្នាំនៃការចូលរួមរបស់ឪពុកម្តាយ កុមារនៅក្នុងក្រុម PEEP មានការនាំមុខមិត្តភក្តិរបស់ខ្លួន (ដែលមិនមែនជា PEEP) នៅក្នុងផ្នែកផ្សេងៗដូចខាងក្រោម ៖ ភាសា និងអក្សរសាស្ត្រ (ការយល់ដឹងពីពាក្យ វាក្យស័ព្ទ និងគោលគំនិតស្តីពីការបោះពុម្ព) ការគណនា (គោលគំនិតស្តីពីចំនួនដំបូង) និងការឲ្យតម្លៃលើខ្លួនឯង (សមត្ថភាពផ្នែកគំនិត និងរាងកាយ)។ កុមារនៅក្នុងក្រុម PEEP បានទទួលផលចំណេញនៅក្នុងផ្នែកនេះយ៉ាងច្រើនរវាងកុមារអាយុ៤ និង៥ឆ្នាំ នៅពេលដែលប្រៀបធៀបទៅនឹងកុមារស្រដៀងគ្នានេះ ដែលឪពុកម្តាយរបស់គេមិនបានចូលរួមក្នុង PEEP។ ការទទួលបានមាន៖ ភាសា និងអក្សរសាស្ត្រ (សមត្ថភាពនៃការគិត និងរាងកាយ)" (Evangelou ២០០៣)។ នៅក្នុងអត្ថបទដែលបានបោះពុម្ព ដោយវិទ្យាស្ថានអូស្ត្រាលីសម្រាប់ការសិក្សាពីគ្រួសារបានរកឃើញថា កម្មវិធីរបស់ HIPPY មានឥទ្ធិពលជាទៅលើរបៀបនៃការអនុវត្តន៍ក្នុងនាមជាឪពុកម្តាយ ជាងឥទ្ធិពលផ្សេងទៀត ទៅលើការអភិវឌ្ឍន៍នៃការអប់រំរបស់កុមារ។ អត្ថបទបានគូសបញ្ជាក់ថា "HIPPY មានឥទ្ធិពលទៅលើការកាត់បន្ថយកម្រិតនៃសកម្មភាពរបស់ឪពុកម្តាយដែលមានលក្ខណៈច្រងេងច្រង៉ាង" (Baenett ឆ្នាំ ២០១២)។ ការសិក្សាថ្មីៗនេះបានរកឃើញថា កម្មវិធីរបស់ HIPPY ភាគច្រើន(៨៤.៨%) នៅសហរដ្ឋអាមេរិកគឺជា "ការត្រៀម

ខ្លួនចូលសាលារៀន” ហើយ “ការវិភាគបានបង្ហាញថា សិស្សសាលាមតេយ្យរបស់ HIPPY មានអត្រាចុះឈ្មោះចូលរៀនខ្ពស់ជាង អត្រាចុះឈ្មោះនៅថ្នាក់មតេយ្យ និងមានអត្រាឡើងថ្នាក់ទី១ខ្ពស់ជាង បើធៀបទៅនឹងមតេយ្យសិក្សាផ្សេងៗទៀតនៅក្នុងស្រុក។ អ្នករៀនថ្នាក់ទី៣របស់ HIPPY មានពិន្ទុខ្ពស់ជាង ចំពោះការធ្វើតេស្តលទ្ធផលនៃការសិក្សាផ្នែកគណិតវិទ្យាដែលរដ្ឋបានកំណត់ បើប្រៀបធៀបទៅនឹងមិត្តភក្តិរបស់ខ្លួនដែលបានប្រកួតប្រជែង។ លទ្ធផលនេះបង្ហាញថា HIPPY មានទំនាក់ទំនងជាវិជ្ជមានជាមួយគ្រួសារ និងសាលារៀនតាមរយៈការចូលរួមរបស់ឪពុកម្តាយ និងលទ្ធផលនៃការរៀនសូត្ររបស់សិស្សនៅសាលារៀន” (Johnson ២០១២)។

បទពិសោធន៍ជាអន្តរជាតិរបស់កម្មវិធីអប់រំតាមខ្នងផ្ទះ បានបង្ហាញឲ្យឃើញថា ការអនុវត្តកម្មវិធីមួយចំនួន ទោះតិចក្តី ច្រើនក្តីបានទទួលជោគជ័យដែរ។ អ្នកស្រាវជ្រាវភាគច្រើនឯកភាពថា វាពុំមែនជាការឆ្លាតវៃទាល់តែសោះក្នុងការបោះបង់ចោលការអនុវត្តន៍កម្មវិធីអប់រំតាមខ្នងផ្ទះនេះទេ ពីព្រោះឪពុកម្តាយកំពុងតែត្រូវការសេវាកម្មនៃកម្មវិធីអប់រំតាមខ្នងផ្ទះ (Gomby ១៩៩៩)។ ហើយនៅក្នុងករណីមួយចំនួនទៀត កម្មវិធីបានទទួលបានជោគជ័យនៅកន្លែងដែលគេត្រូវការជាទីបំផុត ដូចជាជាមួយឪពុកម្តាយ និងកុមារដែលមកពីក្រុមជនជាតិភាគតិច (Wagner ១៩៩៩) (Leung ២០១០)[1] ។
ជាសង្ខេប បទពិសោធន៍ជាអន្តរជាតិរបស់កម្មវិធីអប់រំតាមខ្នងផ្ទះ បានបញ្ជាក់ពីភាពសមហេតុផលរបស់កម្មវិធី ហើយបានបញ្ជាក់ពីភាពមានប្រយោជន៍របស់កម្មវិធីទាំងនេះ ប៉ុន្តែកម្មវិធីទាំងនេះទទួលបានជោគជ័យផ្សេងៗពីគ្នា។

## ២. កម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជា

នៅក្នុងឆ្នាំ ២០០០ ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) នៅក្នុងប្រទេសកម្ពុជា និងអង្គការសង្គ្រោះកុមាររបស់ប្រទេសន័រវែស(SCN)បានបើកដំណើរការកម្មវិធីសាកល្បងការថែរក្សា និងការអភិវឌ្ឍន៍កុមារតូចតាមខ្នងផ្ទះនៅក្នុងភូមិ២ ក្នុងខេត្តកំពង់ឆ្នាំង។ ដោយផ្អែកទៅលើភាពជោគជ័យនៃគម្រោងសាកល្បងនេះ (MoEYS) បានអនុម័តកម្មវិធីនេះទូទាំងប្រទេសដោយដាក់ឈ្មោះថា កម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះ(HBE) នៅក្នុងឆ្នាំក្នុងឆ្នាំ២០០៤។ បើទោះបីជាកម្មវិធីនេះត្រូវបានគេដាក់បញ្ចូលជាលើកដំបូង នៅក្នុងផែនការអប់រំថ្នាក់ជាតិឆ្នាំ ២០០៣ ហើយទទួលបានការគាំទ្រពីអង្គការអន្តរជាតិមួយចំនួន ដូចជាអង្គការ UNICEF ក៏ដោយ ប៉ុន្តែវានៅមានការខ្វះខាតឯកសារផ្សេងៗ ស្តីពីគោលគំនិត និងការរៀបចំរបស់គម្រោងនេះ (Rao ឆ្នាំ២០០៧)។ ជាលទ្ធផលវាមានការលំបាកណាស់ក្នុងការស្វែងរកក្របខ័ណ្ឌស្តីពីគោលគំនិតដែលត្រឹមត្រូវដ៏ច្បាស់លាស់មួយសម្រាប់ទិសដៅ និងការអនុវត្តកម្មវិធី ។

[1] Wagner ចង្អុលបង្ហាញពីជោគជ័យរបស់កម្មវិធី TAT ជាមួយម៉ែជនជតិឡាទីន នៅសហរដ្ឋអាមេរិកនិងកូនៗរបស់គាត់។ Leung សន្និដ្ឋានពីលទ្ធផលជាវិជ្ជាមានក្នុងការអនុវត្តន៍កម្មវិធី HOPE នៅទីក្រុងហុងកុងជាមួយអ្នកចំណាកស្រុកថ្មីមកពីចិនដីគោក។ អ្នកស្រីបានរកឃើញថា គ្រួសារដែលបានចូលរួមនៅក្នុង កម្មវិធីនេះបានកែលំអរន្ទូវទឹកចិត្តក្នុងការរៀនសូត្រ និងកាត់បន្ថយនូវទង្វើដែលមានបញ្ហាច្រើនរបស់កូនៗរបស់ខ្លួន។

ចំពោះទិសដៅរបស់កម្មវិធីនេះ(HBE) គឺពុំមានលក្ខណៈខុសគ្នាពីកម្មវិធីអប់រំតាមខ្នងផ្ទះផ្សេងៗទៀតនៅជុំវិញពិភពលោកទេ។ ទិសដៅសំខាន់របស់កម្មវិធីនេះ គឺជួយឪពុកម្តាយឲ្យបង្កើតបរិយាកាសឲ្យមានអំណោយផលមួយសម្រាប់ការអភិវឌ្ឍន៍កូនតូចៗរបស់ខ្លួន តាមរយៈការរៀបចំក្រៅផ្លូវការ។ ក្រសួងអប់រំ យុវជន និងកីឡា បានសង្កត់ធ្ងន់ទៅលើវត្ថុបំណងគោលនយោបាយ គឺពង្រីកសេវាអប់រំកុមារតូចតាមគ្រប់រូបភាព សម្រាប់កុមារអាយុពី ០ ទៅក្រោម ៦ឆ្នាំ ពិសេសកុមារក្រីក្រ កុមារជនជាតិ និងកុមារពិការ ដោយផ្តល់អាទិភាពដល់សេវាមត្តេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ(ESP2009-2013)។ ហេតុផលរបស់អ្នករៀបចំកម្មវិធីនៅក្នុងប្រទេសកម្ពុជា គឺដើម្បីបង្កើតកម្មវិធីកុមារតូចដើម្បីជួយដល់កុមារដែលពុំទទួលបានសេវាពីកម្មវិធីអប់រំកុមារ តូចៗផ្សេងៗទៀតដូចជាសាលាមតេយ្យរដ្ឋ/សហគមន៍។

កុមារអាយុ ៣ និង ៤ឆ្នាំមាន ១២២, ៩៦៥នាក់ ស្មើនឹង ២១,២៣ ភាគរយនៃក្រុមអាយុ ស្រី ៥០,៥៨ភាគរយ និងកុមារអាយុ ៥ឆ្នាំមាន ១៥៧, ២២៦នាក់ ស្មើនឹង ៥៦,៤៩ ភាគរយ នៃក្រុមអាយុ ស្រី ៤៩,៥០ភាគរយ (ចំណុចដៅ ESP ៥៥ ភាគរយ) តម្រូវការក្នុងការបង្កើនការចុះឈ្មោះចូលរៀនបឋមសិក្សា។

អ្នករៀបចំកម្មវិធីបានគិតថា ពួកគាត់បានមើលឃើញ ចំពោះកម្មវិធីអប់រំតាមខ្នងផ្ទះនូវរូបមន្តសម្រាប់កម្មវិធីអប់រំកុមារតូច ដែលអាចធ្វើទៅបានតាមរយៈធនធានដែលមានស្រាប់របស់ប្រព័ន្ធអប់រំជាផ្លូវការ និងសហគមន៍តាមមូលដ្ឋាន។ គ្រូបង្រៀនសាលារៀនបឋមសិក្សា គ្រូថ្នាក់មតេយ្យសិក្សា អ្នកអប់រំ ក្រុមតស៊ូមតិរបស់ស្ត្រី គ្រូបង្រៀនផ្នែកសាសនា និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល នឹងត្រូវបានគេប្រើប្រាស់អស់លទ្ធភាព សម្រាប់ការអនុវត្តន៍កម្មវិធីនេះ ដោយមានការជួយជ្រោមជ្រែងពីក្រសួងផ្សេងៗទៀត ដូចជាក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល។ រូបភាពទី២ បញ្ជាក់ពីរបៀបដែលអ្នករៀបចំកម្មវិធីបង្ហាញពីយន្តការរបស់កម្មវិធី។

រូបភាពទី ២ ៖ យន្តការនៃដំណើរការកម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះ




ប្រភព៖ ឯកសារ SCI

អ្នករៀបចំកម្មវិធីបានគិតថា ពួកគាត់អាចប្រើប្រាស់នូវរចនាសម្ព័ន្ធ ដែលមានស្រាប់ក្នុងសហគមន៍ សម្រាប់អនុវត្តកម្មវិធីនេះ។ ពួកគេគិតថាប្រធានភូមិ និងក្រុមស្ត្រីដែលមានឥទ្ធិពលនៅតាមសហគមន៍ នឹងដឹកនាំការអនុវត្តន៍គម្រោងផ្សេងៗ ដោយមានជំនួយបច្ចេកទេសពីប្រព័ន្ធអប់រំផ្លូវការ ដូចជាសាលាមត្តេយ្យសិក្សា សាលារៀនបឋមសិក្សា និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក។

យោងទៅតាមស្ថិតិឆ្នាំសិក្សា២០១២-២០១៣ របស់ក្រសួងអប់រំ យុវជន និងកីឡា(MoEYS) ការអប់រំកុមារតូចតាមផ្ទះ និងក្រុមខ្នងផ្ទះមាន១៧៦ ក្រុង ស្រុក ខណ្ឌ។ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលកុមារចូលរួមកម្មវិធីមាន ៥១, ៤៣៥នាក់ ម៉ែបង្គោលមាន ២, ១២៤នាក់ ដែលបានផ្តល់សេវាអប់រំដល់កុមារមាន ៧៦, ២០៧ នាក់ ស្រី ៤៩,៨០ភាគរយ។

រូបភាពទី៣ ៖ ការគ្រប់គ្រងការថែរក្សាកុមារតូចតាមខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជា




ប្រភព: ឯកសារ SCI

តារាងទី ១ - ស្ថិតិកម្មវិធីអប់រំតាមខ្នងផ្ទះឆ្នាំ ២០១២-២០១៣

| ការពិពណ៌នា | ឆ្នាំសិក្សា | | ចំនួនកើន | សំគាល់ |
|---|---|---|---|---|
| | ២០១១-២០១២ | ២០១២-២០១៣ | (+) | |
| ទីក្រុង / ខេត្ត | ២៤ | ២៤ | 0 | ទីក្រុង / ខេត្ត |
| រាជធានី / ស្រុក / ខណ្ឌ | ១៧២ | ១៧៦ | ៤ | ១៧៦ / ១៩៤ |
| ឃុំ / សង្កាត់ | ៦៩៦ | ៧៤៤ | ៤៨ | ៧៤៤/ ១៦៣៣ |
| ភូមិ | ១៧៤៣ | ១៨៣៦ | ៩៣ | ១៨៣៦ / ១៤០៨៨ |
| ម៉ែជាជនបង្គោល | ១៨០៩ | ២១២៤ | ៣១៥ | ១៤,៨៣% |
| ចំនួនក្រុមរបស់ម៉ែ | ៩៩៣២ | ១០១៨៤ | ២៥២ | ២,៤៧% |
| ចំនួនអ្នកចូលរួមក្នុងកម្មវិធី | ៥៩៧៤៣ | ៦៣៧៤៣ | ៤000 | ៦,២៨% |
| ចំនួនសរុបរបស់កុមារ | ៧៤៨១៧ | ៧៦២០៧ | ១៣៩០ | ១,៨២% |
| ស្រី | ៣៦៨៩៨ | ៣៧៩៥២ | ១០៥៤ | ២,៧៨% |

ប្រភព ៖ ( MoEYS ២០១៣ )

ភាពខុសគ្នាដ៏សំខាន់រវាងកម្មវិធីអប់រំតាមខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជា និងកម្មវិធីអប់រំតាមខ្នងផ្ទះផ្សេងៗទៀតនៅជុំវិញពិភពលោកមាន៖

ក. កម្មវិធីអប់រំតាមខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជាត្រូវបានគេមើលឃើញថាជាមធ្យោបាយ សម្រាប់ឆ្លើយតបទៅ នឹងតម្រូវការរបស់កុមារតូច នៅតាមតំបន់ជនបទ និងដាច់ស្រយាលនៅក្នុងប្រទេសនេះ ដោយសាររដ្ឋាភិបាលមិនទាន់លទ្ធភាព ផ្តល់នូវសេវាកម្មសាលាមតេយ្យនៅក្នុងតំបន់នោះបាន (Rao ឆ្នាំ ២០០៧)។ អាចប្រៀបធៀបបានថា នៅកម្រិតអន្តរជាតិ គេមិនដែលមើលឃើញថា កម្មវិធីផ្សេងៗ ជំនួសឲ្យកម្មវិធីមតេយ្យសិក្សាទេ ប៉ុន្តែកម្មវិធីទាំងពីរនេះវាបំពេញឲ្យគ្នាទៅវិញទៅមក។

ខ. ចុះពិនិត្យតាមផ្ទះគឺជាចំណុចស្នូលរបស់កម្មវិធីអប់រំតាមខ្នងផ្ទះ ចំពោះបទពិសោធន៍ថ្នាក់អន្តរជាតិ ចំណែកឯការកំណត់កម្មវិធីមិនមែនជាបញ្ហាសំខាន់ចំពោះកម្មវិធីនៅក្នុងប្រទេសកម្ពុជាទេ។

## ៣. ការវាយតម្លៃពីភាពងាយរងគ្រោះរបស់កុមារ

គោលបំណងសំខាន់របស់កម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះ គឺការជួយដល់កុមារដែលងាយរងគ្រោះ។ សម្រាប់ហេតុផលជោគជ័យរបស់កម្មវិធីទាំងនេះ អាចត្រូវបានគេវាស់វែងបានតាមរយៈឥទ្ធិពលរបស់កម្មវិធីទៅលើជីវិតរបស់កុមារងាយរងគ្រោះម្នាក់ៗនិងរួមគ្នាតែម្តង។

បញ្ហាកុមារដែលងាយរងគ្រោះត្រូវនបានគេពិភាក្សាស្ទើរតែគ្រប់ពេល នៅក្នុងការសិក្សាពីការការពារកុមារ និងសុខុមាលភាពរបស់កុមារ ហើយផ្តោតទៅលើបញ្ហានៃសុវត្ថិភាពរបស់កុមារ (Anthony, ២០០៣ លោក Lee, ២០០១)។ ហេតុដូច្នេះហើយ ភាពងាយរងគ្រោះត្រូវបានគេកំណត់ថាជាការទុកឲ្យកុមារស្ថិតនៅក្រោម ការឈឺចាប់ដែលអាចកើតមានទាំងផ្នែកផ្លូវចិត្ត និងផ្លូវអារម្មណ៍។ ភាពងាយរងគ្រោះរបស់កុមារនៅក្នុងការសិក្សានេះ គឺចូលជ្រៅមួយជំហានទៀតក្នុងការដាក់បញ្ចូលនូវស្ថានភាពណាមួយ ដែលមានលទ្ធភាពក្នុងការការពារកុមារពីការបំពេញនូវសក្តានុពលភាពរបស់ខ្លួនឲ្យក្លាយទៅជាមនុស្សដែលមានតុល្យភាពផ្នែកសុខភាពល្អ ផលិតភាព ការអប់រំផ្លូវចិត្ត និងក្លាយជាមនុស្សល្អ។ ផ្ទុយពីអ្នកស្រាវជ្រាវពីការពារកុមារជាច្រើនដែលកំពុងប្រើប្រាស់ពាក្យនេះថា មានន័យថាជាការគំរាមកំហែងនិងហានិភ័យ (Daniel ឆ្នាំ ២០១០)។ ពាក្យងាយរងគ្រោះនៅទីនេះមានន័យថាលទ្ធភាព និងការដែលអាចកើតមាន។

ភាពងាយរងគ្រោះអាចកើតចេញពីប្រភពផ្នែករាងកាយ សង្គម និងផ្ទាល់ខ្លួន។ ភាពងាយរងគ្រោះរបស់កុមារអាចត្រូវបានសម្រេចចិត្ត ដោយទាក់ទងទៅនឹងប្រភពមួយ ឬច្រើនក្នុងចំណោមប្រភពទាំងនេះ។ ភាពក្រីក្រតែងតែជាប់ទាក់ទងជានិច្ចទៅនឹងការមិនទទួលបានផលប្រយោជន៍ពីសង្គមដែលមានឥទ្ធិពលជាដុំកំភួនទៅលើសុខភាពនិងសុខមាលភាព(Siddiqi ឆ្នាំ ២០០៧) (Lucas ២០០៨) (Matthews ២០១០) និងការអភិវឌ្ឍន៍ផ្នែកផ្លូវចិត្តរបស់ពួកគេ(Kaplan ២០០១) (schoon ២០០៣) (Najman ២០០៤ ) (Sektnan ២០១០)។ ភាពឯកោ គឺជាចំណុចមួយនៃភាពងាយរងគ្រោះរបស់កុមារ។ ភាពឯកកោអាចមានលក្ខណៈ ជារូបវន្តដូចជា ការរស់នៅក្នុងតំបន់ដាច់ស្រយាល ដែលសេវាជាមូលដ្ឋានជាច្រើនពុំអាចទៅដល់ ឬមិនអាចទទួលបានធនធានផ្សេងៗ ឬ ហើយភាពឯកោអាចបណ្តាលមកពីការផាត់ចេញរបស់សង្គម ដោយសារស្ថានភាពសង្គម ភាពតក់ស្លុត បូរវិនិច្ឆ័យ ឬការខ្វះខាតសិទ្ធិទទួលបាន ចំពោះក្រុមមនុស្សជាក់លាក់ (Bradley ២០១១)។ ភាពប្រែប្រួលនៃភាពងាយរងគ្រោះទាំងនេះ អាចត្រូវបានគេមើលឃើញថា ជាមូលហេតុ និងផលវិបាកចំពោះភាពប្រែប្រួលផ្សេងទៀតនៃភាពងាយរងគ្រោះរបស់កុមារ។ ដូច្នេះហើយសុខភាពមិនល្អ កង្វះអាហារូបត្ថម្ភ ជំងឺនិងអនក្ខរភាព តែងតែជាប់ទាក់ទងជានិច្ចជាមួយ ភាពក្រីក្រ និងការផាត់ចេញ ។

ភាពងាយរងគ្រោះរបស់កុមារ គឺជាផលនៃឥទ្ធិពលដែលបានរួមបញ្ចូលគ្នានៃភាពប្រែប្រួលទាំងបួន ហើយភាពប្រែប្រួលនីមួយៗ មានកត្តាផ្សេងៗមួយចំនួនដូចដែលបានរៀបរាប់នៅខាងក្រោមនេះ៖

១. ភាពប្រែប្រួលនៃការអប់រំ ៖

- ស្ថានភាពនៃការចុះឈ្មោះចូលរៀនរបស់គ្រួសារសម្រាប់កុមារដែលគ្រប់អាយុចូលរៀន។
- ការចុះឈ្មោះថ្នាក់មតេយ្យសិក្សាសម្រាប់កុមារក្រោមអាយុ៦ឆ្នាំ
- ភាពប្រែប្រួលរបស់សាលាបឋមសិក្សានៅក្នុងភូមិ និងរយៈចម្ងាយ
- កម្រិតនៃការអប់រំរបស់ម៉ែឪ
- លទ្ធភាពក្នុងការអាន និងសរសេររបស់ម៉ែឪ

២. ភាពប្រែប្រួលនៃភាពក្រីក្រ

- ប្រាក់ចំណូលរបស់គ្រួសារ( តិចជាង ឬច្រើនជាងបន្ទាត់នៃភាពក្រីក្រ)
- កម្មសិទ្ធិដីធ្លីសម្រាប់គ្រួសារកសិករ
- ស្ថានភាពអាពាហ៍ពិពាហ៍របស់ម៉ែឪ

៣. ភាពប្រែប្រួលនៃភាពឯកកោ

- មន្ទីរព្យាបាលរោគដែលនៅជិតបំផុត
- មន្ទីរពេទ្យដែលនៅជិតបំផុត
- ទីរួមខេត្ត (Urban Center) ដែលនៅជិតបំផុត
- ស្ថិតនៅក្នុងក្រុមភាគតិច
- អគ្គីសនីដែលមាន
- ស្ថានភាពនៃការរស់នៅ (នៅផ្ទះដាច់ដោយឡែក ឬនៅផ្ទះជាមួយអ្នកដទៃ)
- មានទូរស័ព្ទចល័តផ្ទាល់ខ្លួន
- ប្រវត្តិនៃការអនុវត្តគម្រោងរបស់ NGOs នៅក្នុងតំបន់

៤. ភាពប្រែប្រួលផ្នែកសុខភាព៖

- ពិការភាព
- ជម្ងឺរ៉ាំរ៉ៃ
- ប្រភពទឹកសម្រាប់ទទួលទាន
- ប្រវត្តិផ្នែកសុខភាពរបស់កុមារ( ការចូលសំរាកពេទ្យ ការឲ្យវេជ្ជបណ្ឌិតពិនិត្យ ជម្ងឺ)

ការវាយតម្លៃពីភាពងាយរងគ្រោះរបស់កុមារដោយផ្អែកលើមូលដ្ឋានសមិទ្ធិកម្មចំនួន៤គឺ៖ សមិទ្ធិកម្មទី១ ឪពុកម្តាយទោះបីជានៅទីកន្លែងណាក៏ដោយ នៅក្នុងលោកនេះតែងតែខិតខំប្រឹងប្រែងអស់ពីលទ្ធភាពរបស់ខ្លួនដើម្បីការពារកូនៗរបស់ខ្លួន និងបង្កើតនូវបរិយាកាសដែលមានអំណោយផលសម្រាប់ការអភិវឌ្ឍន៍របស់កូន។ មិនត្រឹមតែមានសីលធម៌ និងការទទួលខុសត្រូវតាមផ្លូវច្បាប់របស់ឪពុកម្តាយដើម្បីកូនៗរបស់ខ្លួនទេ គឺមានឫសគល់របស់វានៅក្នុងសភាវគតិពីធម្មជាតិរបស់មនុស្ស។ ទោះបីជាត្រូវការសេវាកម្មក៏ដោយ ក៏ពុំមានសម្រាប់ពួកគាត់ដែរ ដូចជាការរស់នៅក្នុងប្រទេសក្រីក្រ ឬតំបន់ដាច់ស្រយាល។ ប្រសិនបើជាមានសេវាទាំងនេះក៏ដោយក៏ពួកគាត់មិនអាចមានលទ្ធភាពទទួលបានសេវាកម្មទាំងនោះបានដែរ ដោយសារតម្លៃនៃសេវាកម្មនេះហួស

ពីលទ្ធភាពផ្នែកសេដ្ឋកិច្ចរបស់គាត់ទៅទៀត។ ពួកគាត់មិនអើពើចំពោះវិធីសាស្ត្រដែលល្អបំផុតនេះទេ ចំពោះការយកចិត្តទុកដាក់ក្នុងនាមជាឪពុកម្តាយទៅលើកូនៗរបស់ខ្លួន គឺដោយសារអនក្ខរភាព superstitious ឬការខ្វះចំណេះដឹង។ ហើយម៉្យាងទៀតពួកគាត់មានជម្ងឺ ពុំមានលទ្ធភាពមើលថែកូនៗរបស់ខ្លួន និងខ្លួនឯងបាន ឧទាហរណ៍ ការញៀនគ្រឿងញៀន ភាពប្រមឹក ឬមានជម្ងឺផ្នែកខួក្បាល និងចិត្តសាស្ត្រក្នុងកម្រិតធ្ងន់ធ្ងរ។

សម្មតិកម្មទី២គឺ៖ ភាពងាយរងគ្រោះរបស់កុមារ គឺជាផលនៃឥទ្ធិពលដែលប្រមូលផ្តុំគ្នារបស់កត្តាផ្សេងៗ ដែលមានចំនួនលើសពីមួយ។ ចំណុចនេះមានន័យថា កត្តាតែមួយខ្លួនឯងមិនអាចជានាបាននូវភាពរងគ្រោះរបស់កុមារទេ។ ឧទាហរណ៍ ការពិតគឺថាមិនមែនកុមារទាំងអស់ដែលមកពីគ្រួសារក្រីក្រ និងមានភាពងាយរងគ្រោះនោះទេ ហើយមិនមែនកុមារទាំងអស់ដែលម្តាយមិនអាចអាន និងសរសេរបាន គឺជាកុមារដែលងាយរងគ្រោះទេ (Daniel ២០១០)។ ដោយសារតែមានម្តាយរាប់លាននាក់ ដែលពុំទទួលបានការអប់រំ ដែលមានគុណភាព ប៉ុន្តែនៅតែជាម្តាយដ៏អស្ចារ្យ ហើយពួកគាត់បានផ្តល់នូវបរិយាកាសដ៏ប្រសើរបំផុត សម្រាប់ការអភិវឌ្ឍន៍របស់កូន។ ការសិក្សានេះអះអាងពីប្រភេទផ្សេងៗ ដូចជាហានិភ័យ ការជួបការលំបាក និងភាពងាយរងគ្រោះជាការពិព័ណ៌នាពីស្ថានភាពរបស់កុមារខុសៗគ្នា ទាក់ទងទៅនឹងសុខភាព និងសុខុមាលភាពរបស់កុមារ។ ចំណែកឯកុមារជួបការលំបាកមានន័យថា ពុំមានអ្វីច្រើនជាងស្ថានភាពដែលពុំមានអំណោយផលរបស់ខ្លួនទេ បើប្រៀបធៀបជាមួយកុមារផ្សេងៗទៀត ភាពងាយរងគ្រោះ គឺលទ្ធភាពមួយដែលកុមារមិនអាចសម្រេចបាននូវសក្តានុពលភាពរបស់ខ្លួន។ មិនមែនដោយសារតែស្ថានភាពជួបការលំបាករបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏មានការគំរាមកំហែងជាក់លាក់មួយ ចំពោះសមត្ថភាពរបស់កុមារក្នុងការសម្រេចបាននូវសក្តានុពលភាពរបស់ខ្លួនដែរ។ ផ្ទុយទៅវិញកុមារដែលស្ថិតនៅក្នុងហានិភ័យ គឺសំដៅទៅលើកុមារទាំងឡាយណាដែលស្ថិតក្នុងគ្រោះថ្នាក់ ចំពោះសុខមាលភាពរបស់ខ្លួន ហើយការគំរាមកំហែងដែលពួកគេកំពុងប្រឈមមុខ គឺមានទំហំលើសពីភាពដែលអាចកើតមានទៅទៀត។

សម្មតិកម្មទី៣៖ ទម្ងន់របស់កុមារងាយរង្គ្រោះនៃការវាយតំលៃអាចប្រែប្រួលទៅតាមការយល់ដឹងរួមនូវបរិយាកាសផ្នែកសេដ្ឋកិច្ចសង្គមរបស់ប្រទេសជាក់លាក់។ ឧទាហរណ៍ កត្តាមួយចំនួនអាចមានទំងន់ធ្ងន់ជាង ឬស្រាលជាងដោយយោងទៅលើស្ថានភាពរស់នៅរបស់សង្គមជាក់លាក់។

សម្មតិកម្មទី៤៖ ភាពងាយរងគ្រោះរបស់កុមារមានកម្រិតខុសគ្នា ហើយក៏មានកម្រិតនៃការទទួលខុសត្រូវខុសគ្នាដែរ។ ពុំមានការវាស់ស្ទង់ផ្នែកវិទ្យាសាស្ត្រជាក់លាក់ដើម្បីវាស់វែងពីភាពងាយរងគ្រោះទេ មានមធ្យោបាយតែមួយដែលយើងអាចកំណត់ពីកម្រិតនៃភាពងាយរងគ្រោះបាន គឺត្រូវកំណត់វានៅក្នុងលក្ខខ័ណ្ឌដែលធូរលុងបំផុត។ ការសិក្សានេះកំណត់ពីកម្រិតនៃភាពងាយរងគ្រោះចំនួន៤៖ ១) ពុំមានភាពងាយរងគ្រោះ ២) មានភាពងាយរងគ្រោះទាប ៣) មានភាពងាយរងគ្រោះមធ្យម និង ៤) មានភាពងាយរងគ្រោះខ្ពស់។

ការវាយតម្លៃពីភាពងាយរងគ្រោះរបស់កុមារ គឺជាឧបករណ៍ដ៏សំខាន់មួយដើម្បីរកឲ្យឃើញនូវកុមារដែលងាយរងគ្រោះ និងធ្វើការវិភាគពីមូលហេតុនៃភាពងាយរងគ្រោះរបស់ពួកគេ។ គេអាចត្រូវបានប្រើប្រាស់វាបានជាផ្នែកមួយនៃអង្កេតជាមូលដ្ឋានណាមួយនៅក្នុងកម្មវិធីអភិវឌ្ឍផ្សេងៗ។ ជាងនេះទៅទៀតវាក៏ជាជំនួយយ៉ាងសម្បើម

ជាសេចក្តីណែនាំដល់អ្នករៀបចំគម្រោង តាមរយៈការផ្តល់ឲ្យនូវរូបភាពដ៏ច្បាស់លាស់របស់អ្នកទទួលផលរបស់គម្រោងណាមួយដែលតម្រង់ទិសទៅរកកុមារ។ លើសពីនេះទៀតការវាយតម្លៃពីភាពងាយរងគ្រោះរបស់កុមារអាចណែនាំអ្នករៀបចំគម្រោងឲ្យប្រើប្រាស់អស់លទ្ធភាពនូវគម្រោង ដើម្បីដោះស្រាយបញ្ហាជាក់ស្តែងរបស់អ្នកទទួលផលរបស់គម្រោង។ នៅទីបញ្ចប់ការវាយតម្លៃពីភាពងាយរងគ្រោះរបស់កុមារអាចត្រូវបានគេប្រើប្រាស់ជាឧបករណ៍វាយតម្លៃ ដើម្បីវាយតម្លៃពីឥទ្ធិពលរបស់គម្រោងណាមួយ ចំពោះការផ្លាស់ប្តូរភាពងាយរងគ្រោះរបស់កុមារនៅក្នុងគម្រោង។

ក្នុងគោលបំណងបង្កើតបាននូវទិន្នន័យផ្នែកបរិមាណ ចំនួននៃពិន្ទុនឹងត្រូវបានគេរៀបចំឡើងសម្រាប់កត្តានីមួយៗដោយបង្ហាញនូវគុណតម្លៃរបស់វា។ កម្រិតនៃភាពងាយរងគ្រោះរបស់កុមារម្នាក់ៗនឹងត្រូវបានគេកំណត់ដោយពិន្ទុសរុបដែលបានមកពីការគណនាតាមបែបគណិតវិទ្យានូវគុណតម្លៃរបស់កត្តាផ្សេងៗដែលទាក់ទងទៅនឹងកុមារជាក់លាក់។ ការដាក់ពិន្ទុលើការវាយតម្លៃត្រូវឆ្លុះបញ្ចាំងនូវសម្មតិកម្មនៃការវាយតម្លៃទាំង៤។ នៅក្នុងជំពូកបន្ទាប់យើងនឹងផ្តល់នូវឧទាហរណ៍ជាក់ស្តែងពីរបៀបដែលយើងអាចបង្កើតបាននូវការវាយតម្លៃភាពពីងាយរងគ្រោះរបស់កុមារនិងប្រើប្រាស់វាជាឧបករណ៍វាយតម្លៃ។

## ៤.ការរកមើលការពិត៖ ការរកឃើញពីការសង្កេត

ការសិក្សានេះស្ថិតនៅក្នុងដែនកំណត់របស់អ្នកស្រាវជ្រាវដោយផ្តោតពីវិធីសាស្ត្រប្រមូលពត៌មាន ថវិកា ពេលា ក្នុងនោះ យើងព្យាយាមជ្រើសរើសយកភូមិ ភាគច្រើនដែលមានកម្មវិធីអប់រំតាមខ្នងផ្ទះបានអនុវត្ត ហើយភូមិមួយចំនួនទៀតតំណាងឲ្យភូមិដែលស្ថិតនៅក្នុងតំបន់ដាច់ស្រយាល។ ការសិក្សានេះធ្វើឡើងទៅតាមការកំណត់ភាគីដែលពាក់ព័ន្ធរបស់អ្នករៀបចំកម្មវិធី ហើយបានរកឃើញថា ភាគីពាក់ព័ន្ធទាំងនោះ ភាគច្រើនគឺជាមន្ត្រីអប់រំស្រុក ប្រធានភូមិ ទីប្រឹក្សាបច្ចេកទេស ប្រធានក្រុមម៉ែ ម៉ែនិងកុមារ។ ចំពោះករណីលើកលែងរបស់កុមារក្រុមស្រាវជ្រាវ និងក្រុមប្រមូលទិន្នន័យបានសំភាសន៍ពីអ្នកពាក់ព័ន្ធផ្សេងៗពីគ្នាៗ ជាលក្ខណៈបុគ្គល ក្រុមពិភាក្សា ឬសំភាសន៍តាមទូរស័ព្ទ។ ទិន្នន័យទាំងអស់អំពីកុមារត្រូវបានគេទទួលតាមរយៈម្តាយរបស់កុមារទាំងនោះ។ ពុំមានកុមារណាម្នាក់ត្រូវបានគេសភាសន៍ធ្វើតេស្ត ឬចូលរួមក្នុងដំណើរទាំងអស់នៃការរៀបចំការស្រាវជ្រាវនេះទេ។

ផែនទីចង្អុលបង្ហាញខេត្តដែលការសិក្សាស្រាវជ្រាវនេះបានគ្របដណ្តប់



## ១៨ ភូមិនៅក្នុងខេត្តចំនួន ៦

តារាងទី២ មានទិន្នន័យអំពីភូមិទាំង១៨ នៅក្នុងខេត្តចំនួន ៦ ដែលការសិកស្រាវជ្រាវនេះគ្របដណ្តប់។ ភូមិទាំងនេះត្រូវបានគេជ្រើសរើសដោយឆ្លោះៗ ទៅតាមភូមិដែលធ្លាប់មានបទពិសោធន៍ ក្នុងការអនុវត្តកម្មវិធីតាមខ្នងផ្ទះ។ ដោយយោងទៅលើការទាក់ទងរបស់យើងជាមួយនឹងការិយាល័យអប់រំស្រុកមន្ត្រីនៅតាមស្រុកទាំងនោះផ្តល់ព័ត៌មានឲ្យយើងថា កម្មវិធីអប់រំតាមខ្នងផ្ទះត្រូវបានគេអនុវត្តនៅគ្រប់ភូមិទាំងអស់សម្រាប់ការសិក្សានេះ។ សម្រាប់តារាងទី២ ទិន្នន័យត្រូវបានគេប្រមូលតាមរយៈការសំភាសន៍ប្រធានភូមិ។ ភូមិចំនួន៤ត្រូវបានគេចាត់ចំណាត់ថ្នាក់ថាជា "ភូមិដាច់ស្រយាល " និងភូមិចំនួន ១២ ត្រូវបានគេចាត់ទុកថាជា "ភូមិជនបទ"។

ភូមិទាំងនេះមានភាពខុសគ្នា ចំពោះប្រជាពលរដ្ឋនៅក្នុងភូមិ និងទីតាំងដែលនៅជិតបំផុត និងទីប្រជុំជនរបស់វា។ ចំនួនប្រជាពលរដ្ឋនៅក្នុងភូមិតូចបំផុតគឺ ២៧៤នាក់ ហើយភូមិដែលធំបំផុតមាន ១៤.១៤០នាក់។ ចំនួនប្រជាពលរដ្ឋរបស់ភូមិចំនួន ១០ មានចំនួនតិចជាង1000នាក់។ ការសង្កេតនេះបានរកឃើញថា ភូមិចំនួន៧មានចរន្តអគ្គីសនីប្រើប្រាស់ ប៉ុន្តែមិនមានន័យថា ផ្ទះនីមួយនៅក្នុងភូមិមានចរន្តអគ្គិសនីប្រើប្រាស់ទេ។ ក្នុងចំណោមភូមិទាំងអស់ លើកលែងតែភូមិមួយប៉ុណ្ណោះដែលធ្លាប់មានបទពិសោធន៍ក្នុងការអនុវត្តគម្រោងមួយ ឬច្រើនពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល។ ព័ត៌មានល្អមួយក្នុងចំណោមព័ត៌មានល្អៗទាំង១៨ភូមិ គឺមានសាលាបឋមសិក្សាមួយបានបម្រើឲ្យកុមារដែលរស់នៅពីសាលាមានចម្ងាយតិចជាង ៥គីឡូម៉ែត្រ។

## ប្រធានភូមិចំនួន១៨នាក់

តារាងទី៣ បង្ហាញពីព័ត៌មានទូទៅរបស់ប្រធានភូមិ។ ការអង្កេតរកឃើញថា នៅក្នុងភូមិចំនួន៣ តួនាទីរបស់ប្រធានភូមិត្រូវបានគ្រប់គ្រងដោយស្ត្រី។ លើកលែងតែប្រធានភូមិមួយប៉ុណ្ណោះ ប្រធានភូមិទាំងអស់មានអាយុរវាង ៤១ ដល់៦៨ឆ្នាំ។ ហេតុដូច្នេះហើយប្រធានភូមិភាគច្រើនជាបុរសដែលមានអាយុលើសពី ៥0ឆ្នាំ។ តាមរយៈតារាងទី២ ក៏បង្ហាញឲ្យឃើញដែរថា ប្រធានភូមិចំនួន ៤នាក់ ពុំទទួលបានការអប់រំជាផ្លូវការទេ។ ប្រធានភូមិភាគច្រើនបានទទួលការអប់រំដែលសមហេតុផលតាមបទដ្ឋានរបស់ប្រទេសកម្ពុជា។

## ទិន្នន័យបរិមាណៈ

ប្រធានភូមិពុំមានគំនិតច្បាស់លាស់ទេ ចំពោះការអនុវត្តកម្មវិធីតាមខ្នងផ្ទះ។ នៅក្នុងនោះមានភូមិចំនួន៣ដែលបានអនុវត្តកម្មវិធីអប់រំតាមខ្នងផ្ទះ ប៉ុន្តែប្រធានភូមិពុំបានដឹងពីការអនុវត្តកម្មវិធីនេះទាល់តែសោះ។ មានប្រធានភូមិចំនួន២នាក់ដែលគំនិតទាក់ទងនឹងកម្មវិធីអប់រំតាមខ្នងផ្ទះនេះ ថាពុំមានសកម្មភាពអ្វីច្រើន ក្រៅពីការប្រជុំជាសារធារណៈមួយម៉ែៗទាំងអស់ ដើម្បីលើកទឹកចិត្តពួកគាត់ឲ្យអនុវត្តនូវទម្លាប់ជាម្តាយល្អ។

ប្រធានភូមិភាគច្រើន មិនអាចបញ្ជាក់ពីភាពខុសគ្នា រវាងសកម្មភាពរបស់កម្មវិធីអប់រំតាមខ្នងផ្ទះ និងសកម្មភាព

ផ្សេងៗទៀតដែលឈានទៅរកការបង្កើនការចុះឈ្មោះចូលរៀនទេ។ នៅពេលដែលគេសួរពីសកម្មភាពទាក់ទងទៅនឹងការអប់រំម៉ែៗ ពួកគាត់បានលើកឡើងថា សកម្មភាពផ្សេងៗភាគច្រើនត្រូវបានអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល ដោយផ្តោតទៅលើការអប់រំស្ត្រីស្តីពីបញ្ហាសុខភាព។ ពួកគាត់ភាគច្រើនបានសំណូមពរឲ្យបង្កើតសាលាមតេយ្យនៅក្នុងភូមិរបស់ពួកគាត់ ថាជាមធ្យោបាយល្អបំផុតនៅក្នុងការកែលំអរកម្មវិធីនេះ។ ពួកគាត់មួយចំនួនបានលើកឡើងពីកង្វះនូវសេវាសាធារណៈ ដូចជា ចរន្តអគ្គីសនី ហើយការខ្វះខាតសម្ភារៈអប់រំសម្រាប់ថ្នាក់សាលាមតេយ្យ គឺជាឧបសគ្គសម្រាប់ការអនុវត្តកម្មវិធីនេះ។ មានតែប្រធានភូមិចំនួន៧នាក់ប៉ុណ្ណោះ ដែលបានដឹងពីចំនួនរបស់ក្រុមម៉ែៗដែលចូលរួមនៅក្នុងកម្មវិធី។

## តារាងទី២ ៖ ព័ត៌មានទូទៅរបស់ភូមិ *

| ឈ្មោះខេត្ត/ស្រុក/ឃុំ/ភូមិ | លេខកូដភូមិ | កម្មវិធីអប់រំតាមខ្នងផ្ទះ | ចំណាត់ប្រភេទភូមិ | ចំងាយជិតបំផុតទៅទីប្រជុំជន (គិតជា គ.ម) | ចំនួនប្រជាជន | ចំងាយជិតបំផុតទៅមណ្ឌលសុខភាព (គិតជា គ.ម) | ចំងាយជិតបំផុតទៅមន្ទីរពេទ្យ (គិតជា គ.ម) | ប្រភពទឹកផឹក | អគ្គិសនី | បណ្ដាញ ទូរស័ព្ទចល័ត | ចំនួនគម្រោង NGO ដែលអនុវត្ត |
|---|---|---|---|---|---|---|---|---|---|---|---|
| កំពង់ចាម/ចំការលើ/ល្វា(លើ)/ក្បាលហុង(ចាស់) | ១ | មាន | ដាច់ស្រយាល | ៤៧,0 | ៨៣៨ | ១,0 | ១,0 | អណ្ដូង | មាន | មាន | ១ |
| កំពង់ចាម/ចំការលើ/ល្វា(លើ)/ក្រលៀង(កើត) | ២ | មិនមាន | ដាច់ស្រយាល | ៥0,0 | ៨៥៩ | ១,0 | ១,0 | អណ្ដូង | មាន | មាន | ៤ |
| កំពង់ចាម/ចំការលើ/ល្វា (លើ)/ល្វា(ជើង) | ៣ | មាន | ជនបទ | ១,0 | ៨៣៦ | ១.0 | ១.0 | អណ្ដូង | មាន | មាន | ៤ |
| កំពង់ឆ្នាំង/បរិបូរ/ពពិល/ក្រាំងខ្នារ | ៤ | មាន | ជនបទ | ៣២,0 | ៦៨0 | ៣.0 | ៣.0 | អណ្ដូង | មិនមាន | មាន | ៣ |
| កំពង់ឆ្នាំង/បរិបូរ/ពពិល/ ក្រោលជី | ៥ | មិនមាន | ជនបទ | ៣៥,0 | ៨៧៥ | ៥.0 | ៥.0 | អណ្ដូង | មិនមាន | មិនមាន | ២ |
| កំពង់ឆ្នាំង/បរិបូរ/ពពិល/សាលាឃុំ | ៦ | មាន | ជនបទ | ១,៥ | ៥.0៨១ | ១.៥ | ១.៥ | អណ្ដូង | មិនមាន | មិនមាន | ២ |
| ព្រះសីហនុ/ព្រៃនប់/ទឹកល្អក់/ប្រលង | ៧ | មាន | ដាច់ស្រយាល | ៦៥,0 | ៨0៨ | ៨.0 | ៦៥.0 | អណ្ដូង | មិនមាន | មាន | ៤ |
| ព្រះសីហនុ/ព្រៃនប់/ទឹកល្អក់/កំពង់ស្នាច់តូច | ៨ | មិនមាន | ជនបទ | ៦៥,0 | ១.២៨៦ | ២.0 | ៦៥.0 | អណ្ដូង | មិនមាន | មិនមាន | ៣ |
| ព្រះសីហនុ/ព្រៃនប់/ទឹកល្អក់/ព្រែកផ្អាវ | ៩ | មាន | ជនបទ | ៧៥,0 | ៥៧0 | ១0.0 | ៧៥.0 | អណ្ដូង | មិនមាន | មិនមាន | ២ |
| ព្រះវិហារ/គូលែន/គូលែនត្បូង/គូលែនត្បូង | ១0 | មាន | ជនបទ | ៤0,0 | ២.៧00 | ៨0.0 | ៨0.0 | អណ្ដូង | មាន | មាន | ≥ ៤ |
| ព្រះវិហារ/គូលែន/ភ្នំត្បែងព័រ/បរិបូរ | ១១ | មិនមាន | ជនបទ | ៨0,0 | ៨៥0 | ៨0.0 | ៨0.0 | អណ្ដូង | មិនមាន | មាន | ≥ ៤ |
| ព្រះវិហារ/គូលែន/ថ្មី/ដាន | ១២ | មាន | ជនបទ | ៤៨,0 | ២៧៤ | ៤៨.0 | ៤៨.0 | អណ្ដូង | មាន | មាន | ២ |
| សៀមរាប/សូត្រនិគម/សំរោង/ក្រាំងខ្នាយ | ១៣ | មាន | ជនបទ | ៧,0 | ៩៩១ | ៧.0 | ១៥.0 | អណ្ដូង | មាន | មាន | ៤ |
| សៀមរាប/សូត្រនិគម/សំរោង/សំរោងត្បូង | ១៤ | មាន | ដាច់ស្រយាល | ៧,0 | ១.៦៤0 | ៧.0 | ១៥.0 | អណ្ដូង | មាន | មាន | ៤ |
| សៀមរាប/សូត្រនិគម/តាយៀក/ប្រាវិល | ១៥ | មិនមាន | ជនបទ | ១៥,0 | ២.៧៥៨ | ១៥.0 | ១៥.0 | អណ្ដូង | មិនមាន | មាន | ១ |
| តាកែវ/ទ្រាំង/សំបួរ/រវៀង | ១៦ | មិនមាន | ជនបទ | ៥0,0 | ១៤.១៤0 | ៥.0 | ៥0.0 | បឹង/ស្រះ | មិនមាន | មិនមាន | ≥ ៤ |
| តាកែវ/ទ្រាំង/សំបួរ/ត្នោតជុំ | ១៧ | មាន | ជនបទ | ៥៤,0 | ១.៦៤៨ | ១១.0 | ៥៤.0 | បឹង/ស្រះ | មិនមាន | មិនមាន | ២ |
| តាកែវ/ទ្រាំង/ថ្លុក/ចិន | ១៨ | មាន | ជនបទ | ៤៨,0 | ១.0២៦ | ១៥.0 | ៤៨.0 | អណ្ដូង | មាន | មិនមាន | មិនមាន |

ប្រភព ៖ ព័ត៌មានទាំងអស់ខាងលើដកស្រង់ចេញពីការសំភាសន៍ប្រធានភូមិ

* ព័ត៌មាននេះប្រហែលជាមិនអាចអនុវត្តបានសម្រាប់គ្រប់ផ្ទះទាំងអស់នៅក្នុងភូមិបានទេ ដូចជាបណ្ដាញទូរស័ព្ទចល័ត អគ្គិសនី ឬ ប្រភពទឹកផឹក

# តារាងទី ៣ ៖ ព័ត៌មានទូទៅរបស់ប្រធានភូមិ

| ឈ្មោះខេត្ត/ស្រុក/ឃុំ/ភូមិ | លេខកូដភូមិ | ភេទ | អាយុ | ប្រវត្តិនៃការអប់រំ | ចំនួនឆ្នាំធ្វើជាប្រធានភូមិ |
|---|---|---|---|---|---|
| កំពង់ចាម/ចំការលើ/ល្វា(លើ)/ក្បាលហុង (ចាស់) | ១ | ប្រុស | ៦០ | អនុវិទ្យាល័យ | ១ |
| កំពង់ចាម/ចំការលើ/ល្វា(លើ)/ក្រលៀង(កើត) | ២ | ស្រី | ៣២ | អនុវិទ្យាល័យ | ៧ |
| កំពង់ចាម/ចំការលើ/ល្វា (លើ)/ល្វា(ជើង) | ៣ | ប្រុស | ៦០ | អនុវិទ្យាល័យ | ៨ |
| កំពង់ឆ្នាំង/បរិបូរ/ពពិល/ក្រាំងខ្នារ | ៤ | ប្រុស | ៦៣ | បឋមសិក្សា | ៣៤ |
| កំពង់ឆ្នាំង/បរិបូរ/ពពិល/ ក្រោលជី | ៥ | ប្រុស | ៦១ | អនុវិទ្យាល័យ | ២ |
| កំពង់ឆ្នាំង/បរិបូរ/ពពិល/សាលាឃុំ | ៦ | ស្រី | ៤៤ | មិនមាន | ៦ |
| ព្រះសីហនុ/ព្រៃនប់/ទឹកល្អក់/ច្រលង | ៧ | ប្រុស | ៤១ | អនុវិទ្យាល័យ | ១ |
| ព្រះសីហនុ/ព្រៃនប់/ទឹកល្អក់/កំពង់ស្មាច់តូច * | ៨ | ប្រុស | ៥៦ | មិនមាន | ពុំមានព័ត៌មាន |
| ព្រះសីហនុ/ព្រៃនប់/ទឹកល្អក់/ព្រែកផ្អាវ | ៩ | ស្រី | ៣៦ | អនុវិទ្យាល័យ | ១ |
| ព្រះវិហារ/គូលែន/គូលែនត្បូង/គូលែនត្បូង | ១០ | ស្រី | ៦៨ | មិនមាន | ៣៣ |
| ព្រះវិហារ/គូលែន/ភ្នំត្បែងព័រ/បរិបូរ | ១១ | ប្រុស | ៥៥ | មិនមាន | ៧ |
| ព្រះវិហារ/គូលែន/ថ្មី/ដាន | ១២ | ប្រុស | ៥៨ | បឋមសិក្សា | ១៥ |
| សៀមរាប/សូត្រនិគម/សំរោង/ក្រាំងខ្ចាយ | ១៣ | ប្រុស | ៥៩ | អនុវិទ្យាល័យ | ១៣ |
| សៀមរាប/សូត្រនិគម/សំរោង/សំរោងត្បូង | ១៤ | ប្រុស | ៦០ | អនុវិទ្យាល័យ | ២៦ |
| សៀមរាប/សូត្រនិគម/តាយៀក/ប្រាវិល | ១៥ | ប្រុស | ៦០ | បឋមសិក្សា | ៦ |
| តាកែវ/ទ្រាំង/សំបួរ/រវៀង | ១៦ | ប្រុស | ៤៨ | បឋមសិក្សា | ២៦ |
| តាកែវ/ទ្រាំង/សំបួរ/ត្នោតជុំ | ១៧ | ប្រុស | ៥៣ | បឋមសិក្សា | ២៤ |
| តាកែវ/ទ្រាំង/ថ្លុក/ចិន | ១៨ | ប្រុស | ៦៨ | បឋមសិក្សា | ២៨ |

ប្រភព ៖ ព័ត៌មានទាំងអស់ខាងលើដកស្រង់ចេញពីការសំភាសន៍ប្រធានភូមិ

* ការសំភាសន៍ត្រូវបានធ្វើឡើងជាមួយជំនួយការប្រធានភូមិ ដោយសារប្រធានភូមិជាប់រវល់

## ប្រធានក្រុមម៉ែៗ

ក្រុមស្រាវជ្រាវបានបានសំភាសន៍ប្រធានក្រុមអ្នកដឹកនាំម៉ែៗចំនួន៦៤នាក់ នៅក្នុងការរៀបចំក្រុមពិភាក្សាចំនួន ១២លើក។ តារាងទី៤ ចង្អុលបង្ហាញពីព័ត៌មានទូទៅរបស់ប្រធានក្រុមម៉ែៗ។ ទោះបីជាពួកគាត់ភាគច្រើនបាន ទទួលការអប់រំសមស្របទៅតាមបទដ្ឋានរបស់កម្ពុជាក៏ដោយ ក៏មានម៉ែចំនួន១៤នាក់ ក្នុងចំណោមពួកគាត់មិនចេះ អាន និងសរសេរដែរ។ មានតែប្រធានក្រុមម៉ែៗដែលបានសំភាសន៍ចំនួន៨នាក់ប៉ុណ្ណោះ ដែលបានលើកឡើងថា ពួកគាត់បានជួបជាមួយម៉ែៗនៅក្នុងកម្មវិធីអប់រំតាមខ្ទង់ផ្ទះជាផ្លូវការ។ លើកលែងតែម៉ែបង្គោលដែលជាប្រធាន ក្រុមរួមម្នាក់ប៉ុណ្ណោះ ដែលមានប្រវត្តិការងារជាប្រធានក្រុម ក្រៅពីនោះគឺជាកសិករ ឬជាមេផ្ទះ។

## ទិន្នន័យបរិមាណៈ

ការអង្កេតនេះបានរកឃើញថា ប្រធានក្រុមម៉ែ បានទទួលការបណ្តុះបណ្តាលចំនួន៤ដងក្នុងមួយឆ្នាំ ដែលរៀបចំ ចាត់ចែងដោយមន្ត្រីការិយាល័យអប់រំស្រុក។ ពួកគាត់បាននិយាយសំដៅទៅរកការបណ្តុះបណ្តាលដែលផ្តោត ទៅលើបញ្ហាក្នុងនាមជាម៉ែៗដូចជា ការថែរក្សាកូន ទំនាក់ទំនងរវាងម្តាយ និងកូន ព្រមទាំងឲ្យកូនចូលរួមនៅ ក្នុងសកម្មភាពជាមូលដ្ឋាននៅក្នុងផ្ទះ។ ក្នុងនោះភូមិចំនួន៣ គឺក្រុមម៉ែៗបានបង្ហាញថា ពួកគាត់ពុំបានធ្វើសកម្មភាព ណាមួយទេ អស់រយៈពេល៦ខែកន្លងមក ដោយសារតែពួកគាត់ជាប់រវល់ ពុំមានពេលវេលាគ្រប់គ្រាន់ព្រោះការងារ និងការទទួលខុសត្រូវច្រើននៅក្នុងផ្ទះរបស់ពួកគាត់។ មានតែមួយភូមិប៉ុណ្ណោះដែលក្រុមម៉ែៗបានលើកឡើងថាមាន ការរៀបចំប្រជុំក្រុមប្រចាំខែជាទៀតទាត់។

ប្រធានក្រុមម៉ែៗទាំងអស់បានចង្អុលបង្ហាញថា កម្មវិធីបានបង្កើតឲ្យមានលទ្ធផលជាវិជ្ជមាន សម្រាប់កូន រឺម៉ែៗដែល បានចូលរួម។ ភាគច្រើនម៉ែៗបានលើកឡើងថា ពួកបានកាត់បន្ថយអំពើហឹង្សាទៅលើកូន ជាលទ្ធផលមួយក្នុង ចំណោមលទ្ធផលចំបងៗនានារបស់កម្មវិធី។ ក្នុងពេលជាមួយគ្នានេះដែរពួកគាត់ក៏បានបង្ហាញឲ្យឃើញនូវតម្រូវការ ចំពោះការគាំទ្របន្ថែមទៀតពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលជាពិសេសក្នុងផ្នែកកសាងសមត្ថភាព។

តារាងទី ៤ - ព័ត៌មានរបស់ក្រុមម៉ែជាអ្នកដឹកនាំ

| លេខកូដភូមិ | ចំនួននៃការសំភាសន៍ | អាន និងសរសេរ | | ប្រវត្តិនៃការអប់រំ | | ប្រវត្តិការងារ | | | រយៈពេលបំរើការ HBE? | | | ចំនួនម៉ែនៅក្នុងក្រុមដែលអ្នកដឹងនាំ | | | | ការកំណត់ HB | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មិនចេះអាន និងសរសេរ | ចេះអាន និង សរសេរ | បញ្ចប់ បឋម សិក្សា | អនុ វិទ្យា ល័យ | មេផ្ទះ | កសិករ | ផ្សេងៗ | តិច ជាង ៦ខែ | តិចជាង ១ឆ្នាំ | លើស ពី១ឆ្នាំ | តិចជា ង ៥នាក់ | ពី៦- ១០នាក់ | លើសពី ២១នាក់ | មិនដឹង | ការកំណត់ ជាផ្លូវការ | ការកំណត់ ក្រៅផ្លូវការ |
| ១ | ៥ | | ៥ | ៥ | | ៣ | ២ | | | | ៥ | ៥ | | | | ២ | ៣ |
| ២ | មិនមាន HB | | | | | | | | | | | | | | | | |
| ៣ | ៣ | | ៣ | ៣ | | ៣ | | | | | ៣ | ១ | ២ | | | ១ | ២ |
| ៤ | ៥ | | ៥ | ១ | ៤ | | ៥ | | | | ៥ | | ៥ | | | ៣ | ២ |
| ៥ | មិនមាន HB | | | | | | | | | | | | | | | | |
| ៦ | ៥ | | ៥ | ២ | ៣ | ៥ | | | | | ៥ | | ៥ | | | | ៥ |
| ៧ | ៦ | | ៦ | ៤ | | | ៦ | | | ២ | ៤ | ៥ | ១ | | | ១ | ៥ |
| ៨ | មិនមាន HB | | | | | | | | | | | | | | | | |
| ៩ | ៦ | | ៦ | ៦ | | | ៦ | | | ៦ | | ៥ | ១ | | | ១ | ៥ |
| ១០ | ៧ | | ៧ | ៦ | ១ | | 7 | | | ៧ | | ២ | | | ៥ | | ៥ |
| ១១ | មិនមាន HB | | | | | | | | | | | | | | | | |
| ១២ | ៦ | ៤ | ២ | | | | ៦ | | | | ៦ | | | | ៦ | | ៦ |
| ១៣ | ៣ | ២ | ១ | ១ | | | ២ | ១ | ២ | | ១ | ២ | | ១ | | | ៣ |
| ១៤ | ៧ | ៦ | ១ | ១ | | | ៧ | | ៣ | ៣ | ១ | ៧ | | | | | ៧ |
| ១៥ | មិនមាន HB | | | | | | | | | | | | | | | | |
| ១៦ | មិនមាន HB | | | | | | | | | | | | | | | | |
| ១៧ | ៥ | ១ | ៤ | ២ | | | ៥ | | | | | | | | | | |
| ១៨ | ៦ | ១ | ៥ | ២ | ១ | | ៦ | | | | | | | | | | |
| Total | ៦៤ | ១៤ | ៥០ | ៣៣ | ៩ | ១១ | ៥២ | ១ | ៥ | ១៨ | ៣០ | ២៧ | ១៤ | ១ | ១១ | ៨ | ៤៣ |

## ការិយាល័យអប់រំស្រុក/ទីប្រឹក្សាអនុវត្តកម្មវិធី

ការសង្កេតនេះបានរកឃើញថាមន្ត្រីអប់រំស្រុក មានការទទួលខុសត្រូវពិតប្រាកដ ចំពោះការការអនុវត្តន៍កម្មវិធីអប់រំតាមខ្នងផ្ទះ។ ពួកគាត់មានការទទួលខុសត្រូវលើកដំណើរការមួយចំនួនដូចជា ការបណ្តុះបណ្តាលប្រធានក្រុមម៉ែ ទីប្រឹក្សារបស់កម្មវិធី និងអ្នកសម្របសម្រួលកម្មវិធីនៅគ្រប់ភូមិទាំងអស់នៅក្នុងស្រុក។

ក្រុមស្រាវជ្រាវបានសំភាសន៍មន្ត្រីការិយាល័យអប់រំស្រុកចំនួន៦នាក់ ក្នុងនោះការសំភាសន៍មាន២ដងគឺ លើកទី១ក្នុងនាមពួកគាត់ក្នុងនាមជាមន្ត្រីការិយាល័យអប់រំស្រុក(ការសំភាសន៍តាមទូរស័ព្ទ) និងលើកទីពីរ ក្នុងនាមពួកគាត់ជាទីប្រឹក្សារបស់កម្មវិធី។ មន្ត្រីការិយាល័យអប់រំស្រុកដែលបានសំភាសន៍ទាំងអស់មានបទពិសោធន៍ក្នុងវិស័យអប់រំ និងការបង្រៀនពី៣ទៅ ៣៣ឆ្នាំ។ មន្ត្រីការិយាល័យអប់រំស្រុកចំនួន៥នាក់ ក្នុងចំណោមមន្ត្រីទាំងនោះមានការទទួលខុសត្រូវលើការគ្រប់គ្រងកម្មវិធីលើសពី ២៥ភូមិ នៅក្នុងស្រុករបស់ពួកគាត់។

មន្ត្រីទាំងនោះបានលើកឡើងថា ពួកគាត់បានទទួលការបណ្តុះបណ្តាលពិសេសនៅលើទិសដៅ និងសកម្មភាពមួយឬច្រើន ក្នុងចំណោមទិសដៅ និងកម្មវិធីនានារបស់កម្មវិធីអប់រំតាមខ្នងផ្ទះ។ ជាទូទៅពួកគាត់មានការយល់ដឹងជារួម ពីទិសដៅរបស់កម្មវិធីអប់រំតាមខ្នងផ្ទះ។ ចំពោះយោបល់របស់ពួកគាត់ថាកម្មវិធីនេះបានទទួលជោគជ័យ និងមានឥទ្ធិពលជាវិជ្ជមានទៅលើជីវិតរបស់កុមារ។ ឥទ្ធិពលជាវិជ្ជមានមួយចំនួនក្នុងចំណោមឥទ្ធិពលទាំងនេះ គឺជាការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ ការបង្កើនការចុះឈ្មោះចូលរៀន ការចែករំលែកចំណេះដឹង និងការបង្កើននូវការយល់ដឹងរបស់ម៉ែៗនៅក្នុងទិដ្ឋភាពនានាដូចជាទំនាក់ទំនងរវាងកូននិងឪពុកម្តាយនិងបញ្ហាសុខភាព។
មន្ត្រីការិយាល័យអប់រំស្រុកទាំងអស់បានសំណូមពរឲ្យមានការចូលរួមច្រើនថែមទៀតពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងកម្មវិធីនេះ។

## ម៉ែៗចំនួន ៥៤៧ នាក់

ក្រុមការងារស្រាវជ្រាវបានសំភាសន៍ម៉ែៗចំនួន៦៤៧នាក់។ ពួកគាត់ត្រូវបានគេជ្រើសរើសដោយចៃដន្យតាមរយៈការគោះទ្វាផ្ទះនៅតាមភូមិនីមួយ។ តារាងទី៥ ចង្អុលបង្ហាញពីសម្ភារៈ និងស្ថានភាពផ្ទះសម្បែងរបស់ម៉ែៗ។ ការអង្កេតនេះបានរកឃើញម៉ែៗចំនួន ៨៦% បានរៀបការ និងរស់នៅជាមួយប្តីរបស់ខ្លួន និង ៩% ទៀតរស់នៅបែកគ្នា ឬប្តីរបស់ខ្លួនទៅធ្វើការនៅបរទេស ឬខេត្តផ្សេងទៀត។ ម៉ែៗចំនួន ៣% គឺជាស្ត្រីមេម៉ាយ ហើយមានតែ២% ប៉ុណ្ណោះដែលលែងលះគ្នា។ ម៉ែចំនួ៧៤% រស់នៅក្នុងផ្ទះដាច់ពីគ្នា ហើយ ២៦% ទៀតរស់នៅជាលក្ខណៈគ្រួសាររួមគ្នា។

កត្តាចង្អុលបង្ហាញពីការផ្លាស់ប្តូរមួយក្នុងចំណោមកត្តាចង្អុលបង្ហាញផ្សេងៗនៅតាមភូមិក្នុងប្រទេសកម្ពុជា គឺចំនួនស្ត្រីដែលមានទូរស័ព្ទចល័តប្រើប្រាស់។ ការអង្កេតនេះបានរកឃើញថាម៉ែចំនួន ៦៦% មានលទ្ធភាពប្រើប្រាស់ទូរស័ព្ទចល័ត។ក្នុងពេលជាមួយគ្នានោះដែរម៉ែចំនួន៨៨%មិនមានចរន្តអគ្គិសនីប្រើប្រាស់នៅក្នុងផ្ទះរបស់ខ្លួនទេ។

តារាងទី ៥ - សំភារៈ និងស្ថានភាពផ្ទះសំបែងរបស់ម៉ែ

| លេខកូដភូមិ | ស្ថានភាពគ្រួសារ | | | | | ស្ថានភាពរស់នៅក្នុងផ្ទះ | | ស្ថិតក្នុងក្រុមជនជាតិភាគតិច | | មានទូរស័ព្ទចល័ត | | អគ្គិសនី | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | រៀបការ | បែកគ្នា | ប្ដីធ្វើការនៅខេត្ត ផ្សេង / ក្រៅប្រទេស | មេមាយ | លែងលះ | រស់នៅបែកផ្ទះគ្នា | រស់នៅក្នុងគ្រួសារដែលមានសមាជិកច្រើន | មែន | មិនមែន | មិនមាន | មាន | មិនមាន | មាន |
| ១ | ២៥ | ២ | ៣ | | | ១៦ | ១៤ | ២ | ២៨ | ២ | ២៨ | ២៦ | ៤ |
| ២ | ២៣ | ៣ | ៣ | ១ | | ១៥ | ១៤ | | ៣ | ៥ | ២៥ | ២៧ | ៣ |
| ៣ | ២៣ | ១ | ២ | ៤ | | ២០ | ១០ | | ៣០ | ១០ | ២០ | ២៥ | ៥ |
| ៤ | ២៤ | ២ | ១ | ២ | ១ | ២៣ | ៧ | | ៣០ | ១៤ | ១៦ | ៣០ | |
| ៥ | ២៨ | ១ | | | ១ | ២៥ | ៥ | | ៣០ | ១៤ | ១៦ | ៣០ | |
| ៦ | ២៧ | | ១ | | ២ | ២៧ | ៣ | | ៣០ | ៤ | ២៦ | ៣០ | |
| ៧ | ២៣ | ៤ | ២ | ៣ | ១ | ២២ | ១១ | | ៣៣ | ១៦ | ១៧ | ២៥ | ៨ |
| ៨ | ២៥ | ១ | ៣ | ១ | | ២៣ | ៧ | | ៣០ | ១៥ | ១៥ | ២៥ | ៥ |
| ៩ | ២៥ | ២ | ២ | ១ | | ២៣ | ៧ | | ៣០ | ១១ | ១៩ | ២៤ | ៦ |
| ១០ | ២៨ | ១ | | | ១ | ២៣ | ៧ | | ៣០ | ៩ | ២១ | ១៧ | ១៣ |
| ១១ | ២៩ | | ១ | | | ២៧ | ៣ | | ៣០ | ១៨ | ១២ | ២៩ | ១ |
| ១២ | ២៧ | ២ | | ១ | | ២៦ | ៤ | ១ | ២៩ | ១៦ | ១៤ | ២៧ | ៣ |
| ១៣ | ២៨ | | ១ | ១ | | ២៤ | ៦ | | ៣០ | ៩ | ២១ | ២៥ | ៥ |
| ១៤ | ២៧ | ១ | ២ | | | ២៣ | ៧ | | ៣០ | ៦ | ២៤ | ២០ | ១០ |
| ១៥ | ២៩ | | | ១ | | ២៦ | ៤ | | ៣០ | ១០ | ២០ | ២៩ | ១ |
| ១៦ | ២៦ | ១ | ១ | ១ | ១ | ២២ | ៨ | ១ | ២៩ | ១២ | ១៨ | ៣០ | |
| ១៧ | ២៨ | | ២ | ១ | ២ | ១៩ | ១៤ | ១ | ៣២ | ៦ | ២៧ | ៣១ | ២ |
| ១៨ | ២៤ | ៤ | ៣ | | | ១៨ | ១៣ | ១ | ៣០ | ៩ | ២២ | ៣១ | |
| សរុប | ៤៦៩ | ២៥ | ២៧ | ១៧ | ៩ | ៤០២ | ១៤៤ | ៦ | ៥៤១ | ១៨៦ | ៣៦១ | ៤៨១ | ៦៦ |

តារាងទី៦: បង្ហាញពីប្រវត្តិនៃការអប់រំ និងការងាររបស់ម៉ែ។ នៅក្នុងផ្នែកអប់រំការអង្កេតបានរកឃើញថា ម៉ែៗចំនួន ៤៥% ពុំចេះអាននិងសរសេរទេ។ ម៉ែៗប្រហែលជា ៦១% បានបញ្ចប់ការអប់រំថ្នាក់បឋមសិក្សាឬការអប់រំចាផ្លូវការ ដែលខ្ពស់ជាងនេះដែលចង្អុលបង្ហាញថា ម៉ែជាច្រើនបាត់បង់ជំនាញក្នុងការអាន និងសរសេរ បន្ទាប់ពីពួកគាត់ចាក ចេញពីការអប់រំ។

ចំពោះផ្នែកការងារវិញម៉ែៗចំនួន ៨៦% គឺជាកសិករ ហើយមានតែ ៥% ប៉ុណ្ណោះគឺជាមេផ្ទះ។ ការអង្កេតបានរក ឃើញថាមានស្នង់មតិនេះបានរកឃើញថា មានតែម៉ែតែម្នាក់ប៉ុណ្ណោះដែលធ្វើការឲ្យអង្គការមិនមែនរដ្ឋាភិបាលទោះ បីជានៅក្នុងភូមិភាគច្រើនមានគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាល។

តារាងទី៧: បង្ហាញពីស្ថានភាពរបស់ម៉ែៗ សូចនាករដែលសំខាន់បំផុតនៃលក្ខខណ្ឌផ្នែកសេដ្ឋកិច្ចរបស់កសិករ គឺ កម្មសិទ្ធិដីធ្លី។ ការអង្កេតបានរកឃើញថាម៉ែៗចំនួន ៧៩% ដែលមកពីគ្រួសារកសិករមានកម្មសិទ្ធិដីធ្លី។ ៥៤% នៃ អ្នកទាំងនោះមានដីតិចជាងមួយហិកតា ២៧% មានពី១-២ ហិកតា ១០% មាន ២-៣ ហិកតា ៥%មាន ៣-៤% ហិកតា ១% មាន ៤-៥ ហិកតា និង១% មាន៥ហិកតា ឬលើសពីនេះ ។

ចំពោះម៉ែៗដែលគ្រួសាររបស់ខ្លួន ពុំមានដីធ្លី ឬមិនមែនជាកសិករ ការអង្កេតបានរកឃើញថាពួកគាត់ចំនួន ២៦% មានប្រាក់ចំណូលប្រចាំគ្រួសារចំនួន ៣០$ អាមេរិក ឬតិចជាងនេះក្នុងមួយខែ ១៨%មានប្រាក់ចំណូល ៣១-៥០ ដុល្លា ១៤% មានចំណូលពី៥១$-៨០ដុល្លា ២២%មានចន្លោះពី ៨១$-១00ដុល្លា និង ២0% មានលើសពី១00 ដុល្លា។

តារាងទី៨: បង្ហាញពីការចូលរួមរបស់ម៉ែៗក្នុងកម្មវិធីអប់រំកុមារតូច យើងនិយាយនៅទីនេះថា ការអង្កេតបានកំណត់ យកតែម៉ែៗដែលមានកូនតូច គឺផ្អែកទៅលើគោលបំណងនៃការសិក្សា។ ហេតុដូច្នេះហើយមានតែម៉ែៗចំនួន ៩នាក់ ប៉ុណ្ណោះក្នុងចំណោមម៉ែសរុប ដែលបានសម្ភាសន៍ពុំមានកូនក្រោមអាយុ៦ឆ្នាំ។ ម៉ែចំនួន៦២%ដែលបានសម្ភាសន៍ មានកូនម្នាក់មានអាយុក្រោមអាយុ៦ឆ្នាំ ហើយ៣៤% មានកូន២នាក់មានអាយុក្រោម៦ឆ្នាំ។

ការអង្កេតបានរកឃើញថាម៉ែចំនួន ៤៦% មានកូនដែលបានចុះឈ្មោះចូលរៀននៅមតេយ្យសិក្សា។ ៨៩% នៃម៉ែៗ ទាំងនោះបានចុះឈ្មោះកូនឲ្យចូលរៀននៅមតេយ្យសិក្សារបស់រដ្ឋ ក្នុងនោះ៧%ពួកគាត់បានចុះឈ្មោះនៅមតេយ្យ សិក្សាសហគមន៍ និង៤% ចុះឈ្មោះនៅមតេយ្យសិក្សាឯកជន។ ម៉ែៗដែលមានកូនតូចពុំបានចុះឈ្មោះចូលរៀននៅ សាលាមតេយ្យសិក្សា បានពន្យល់ពីហេតុផលថា ការមិនចុះឈ្មោះឲ្យកូនចូលរៀននៅសាលាមតេយ្យមាន៖ ៤៣% នៃពួកគាត់បានគិតថា វាពុំមានផលប្រយោជន៍ទេ២៥% ថាពុំមានសាលាមតេយ្យនៅក្នុងតំបន់របស់ពួកគាត់២0% ថាកូនរបស់ពួកគាត់នៅក្មេងពេក ៧% បាននិយាយថាបានចុះឈ្មោះនៅសាលា ប៉ុន្តែសាលាមតេយ្យមិនទទួល

យកកូនរបស់ពួកគាត់ ៤% បាននិយាយថា សាលាមតេយ្យនៅឆ្ងាយពីផ្ទះរបស់ពួកគាត់ពេក ហើយ១% បាននិយាយថាពួកគេមិនពួកគាត់ពុំមានអ្នកជូនទៅសាលាមតេយ្យទេ។

**សូមបញ្ជាក់:** នៅតាមភូមិគោលដៅមិនមែនគ្រប់ឪពុកម្ដាយ ដែលមានកូនអាយុក្រោម ៦ឆ្នាំទាំងអស់ចូលរួមក្នុងកម្មវិធីអប់រំតាមខ្នងផ្ទះ(HBE)នៅទេ ប៉ុន្តែការចូលរួមនោះគឺជាការស្ម័គ្រចិត្ត។

| តារាងទី៦ - ប្រវត្តិនៃការអប់រំ និងការងាររបស់ម៉ែ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចេះអាន និងសរសេរ | | ប្រវត្តិនៃការអប់រំ | | | | | | មុខរបរ | | | | | | |
| លេខកូដភូមិ | មិនចេះ | ចេះ | សកលវិជ្ជាល័យ | បញ្ចប់វិទ្យាល័យ | បញ្ចប់អនុវិទ្យាល័យ | បញ្ចប់បឋមសិក្សា | មិនទាន់បញ្ចប់បឋមសិក្សា/ មិនបានរៀន | ផ្សេងៗ | កសិករ | មេផ្ទះ | មានមុខរបរផ្ទាល់ខ្លួន | មន្ត្រីរដ្ឋាភិបាល | ធ្វើការឲ្យ NGO | ផ្សេងៗ |
| ១ | ៧ | ២៣ | | ១ | ៦ | ១៧ | ៦ | | ២៤ | ៣ | ២ | | | ១ |
| ២ | ២ | ២៨ | | | ៧ | ២០ | ២ | ១ | ២២ | ៥ | ១ | | ១ | ១ |
| ៣ | ១១ | ១៩ | | ១ | ៦ | ១២ | ១១ | | ២៤ | ១ | | ១ | | ៤ |
| ៤ | ១៤ | ១៦ | | ២ | ៤ | ១១ | ៦ | ៧ | ២៨ | ១ | ១ | | | |
| ៥ | ១៨ | ១២ | | | | ២១ | ៧ | ២ | ២៩ | ១ | | | | |
| ៦ | | ៣០ | | ៣ | ១០ | ១៧ | | | ២៥ | ២ | | ៣ | | |
| ៧ | ១៤ | ១៩ | | | ២ | ២២ | ៤ | ៥ | ៣១ | ១ | | | | ១ |
| ៨ | ១៣ | ១៧ | | ១ | ២ | ១៥ | ១០ | ២ | ៣០ | | | | | |
| ៩ | ១២ | ១៨ | | ១ | | ២២ | ៦ | ១ | ២៦ | ៤ | | | | |
| ១០ | ១៨ | ១២ | ១ | ១ | ៤ | ៦ | ១៨ | | ២៤ | ១ | | ២ | | ៣ |
| ១១ | ២៦ | ៤ | | | | ២ | ២៧ | ១ | ២៩ | | | | | ១ |
| ១២ | ២៥ | ៥ | | | | ៣ | ២៧ | | ២៩ | | | | | ១ |
| ១៣ | ២៣ | ៧ | | | ១ | ៨ | ២១ | | ២២ | ៥ | | | | ៣ |
| ១៤ | ១៣ | ១៧ | ១ | ២ | ២ | ១០ | ១១ | ៤ | ១៦ | ៣ | ១ | | | ១០ |
| ១៥ | ២៥ | ៥ | | | ១ | ៦ | ២៣ | | ២៥ | ២ | | | | ៣ |
| ១៦ | ១៣ | ១៧ | | ១ | ២ | ២៣ | ៤ | | ២៨ | | | | | ២ |
| ១៧ | ៤ | ២៩ | | ២ | ៨ | ២៣ | | | ៣២ | | | | | ១ |
| ១៨ | ៥ | ២៥ | | ៦ | ៦ | ១៤ | ៤ | ១ | ២៩ | | ២ | | | |
| សរុប | ២៤៤ | ៣០៣ | ២ | ២១ | ៦១ | ២៥២ | ១៨៧ | ២៤ | ៤៧៣ | ២៩ | ៧ | ៦ | ១ | ៣១ |

សូមបញ្ជាក់: (នៅតាមភូមិគោលដៅមិនមែនគ្រប់មាតាបិតាដែលមានកូនអាយុក្រោម៦ឆ្នាំទាំងអស់ចូលរួមក្នុងកម្មវិធីអប់រំតាមខ្នងផ្ទះ (HBE)នៅទេ ប៉ុន្តែការចូលរួមនោះគឺជាការស្ម័គ្រចិត្ត)

តារាងទី៧ - ស្ថានភាពសេដ្ឋកិច្ចរបស់ម៉ែ

| លេខកូដភូមិ | កម្មសិទ្ធិដីធ្លី (កសិករ) | | ចំណូលមិនមែនរបស់កសិករ | | | | | ទំហំដីកម្មសិទ្ធិ (កសិករ) ហិកតា | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | មិនមាន | មាន | $៣០/ តិចជាង | $ ៣១ - ៥០ | $ ៥១-៨០ | $ ៨០-១០០ | $១០១ /ច្រើនជាង | តិចជាង១ | ១ | ២ | ៣ | ៤ | ៥/ច្រើនជាង |
| ១ | ១៥ | ១៥ | ២ | ៤ | ២ | ៦ | ១ | ១១ | ១ | ៣ | | | |
| ២ | ១៥ | ១៥ | ៣ | ៥ | | | ៧ | ៣ | ៩ | ២ | | | ១ |
| ៣ | ១១ | ១៩ | ៤ | ២ | ២ | ៣ | | ១២ | ៥ | ១ | ១ | | |
| ៤ | ២ | ២៨ | | ២ | | | | ២២ | ៥ | | ១ | | |
| ៥ | | ៣០ | | | | | | ២៣ | ៦ | | | | ១ |
| ៦ | ៤ | ២៦ | ២ | | | ២ | | ២០ | ៤ | ២ | | | |
| ៧ | ៥ | ២៨ | ១ | | ១ | ២ | ១ | ២០ | ៥ | ៣ | | | |
| ៨ | ៤ | ២៦ | ២ | | ២ | | | ១៩ | ៧ | | | | |
| ៩ | ៦ | ២៤ | ១ | ១ | ១ | ១ | ២ | ១១ | ១៣ | | | | |
| ១០ | ៥ | ២៥ | | ១ | ១ | ១ | ២ | ២ | ៨ | ៦ | ៦ | ១ | ២ |
| ១១ | ២ | ២៨ | ២ | | | | | ៣ | ៩ | ៨ | ៣ | ១ | ៤ |
| ១២ | | ៣០ | | | | | | ១ | ១០ | ១០ | ៨ | | ១ |
| ១៣ | ១៣ | ១៧ | ២ | ២ | ៣ | ៤ | ២ | ១១ | ៦ | | | | |
| ១៤ | ១៣ | ១៧ | ៤ | ២ | ១ | ៣ | ៣ | ១៤ | ២ | | ១ | | |
| ១៥ | ៦ | ២៤ | | | ១ | ៤ | ១ | ១១ | ៧ | ៤ | | | ២ |
| ១៦ | ៥ | ២៥ | ១ | | ២ | | ២ | ១៥ | ៧ | ៣ | | | |
| ១៧ | ៤ | ២៩ | ២ | ១ | | | ១ | ១៦ | ៨ | ២ | ១ | ១ | ១ |
| ១៨ | ៦ | ២៥ | ៤ | ១ | | | ១ | ១៨ | ៦ | | | ១ | |
| សរុប | ១១៦ | ៤៣១ | ៣០ | ២១ | ១៦ | ២៦ | ២៣ | ២៣២ | ១១៨ | ៤៤ | ២១ | ៤ | ១២ |

## តារាងទី៨- ការចូលរួមរបស់ម៉ែនៅក្នុងកម្មវិធីអប់រំកុមារតូច

| លេខកូដ ភូមិ | តើមានកុមារអាយុ៥ឆ្នាំចំនួនប៉ុន្មាននាក់ | | | | | | តើគេចុះឈ្មោះចូលរៀនមតេយ្យសិក្សាដែរឬទេ | | ប្រសិនបើចុះឈ្មោះ តើមតេយ្យសិក្សាអ្វី | | | ប្រសិនបើមិនចុះឈ្មោះ តើមកពីមូលហេតុអ្វី | | | | | | ការចូលរួមនៅក្នុងកម្មវិធី HB | | តើអ្នកស្គាល់ប្រធានក្រុមដែរឬទេ | | តើសកម្មភាព HB កើតឡើងនៅក្នុងកម្រិតណាក្នុងមួយឆ្នាំៗ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ | ០ | មាន | មិនមាន | SP | CP | PS | សាលាមតេយ្យនៅឆ្ងាយ | ពុំមានអ្នកជូនកូនទៅ | នៅក្មេងពេក | គេមិនឲ្យចុះឈ្មោះ | មិនត្រូវការ | គ្មានសាលាមតេយ្យនៅក្នុងតំបន់ | មិនមាន | មិន មាន | មិន មាន | មាន | ១ - ២ | ៣ -៤ | មិនដឹង |
| ១ | ២២ | ៨ | | | | | ២៩ | ១ | ២៨ | | ១ | | | | ១ | | | ២១ | ១ | ១ | ៨ | ៣ | ៥ | ១ |
| ២ | ២៧ | ៣ | | | | | ២៦ | ៤ | ២៦ | | | ១ | ១ | ១ | ១ | | | ២៤ | ៦ | ៣ | ៣ | ៥ | ១ | |
| ៣ | ២០ | ៩ | ១ | | | | ២៧ | ៣ | ២៧ | | | ១ | | ២ | | | | ១០ | ១១ | ២ | ៩ | ១០ | | ១ |
| ៤ | ២០ | ៨ | ១ | | ១ | | ២ | ១០ | ៦ | ១៤ | | | | ៤ | ៦ | | | ១ | ២៩ | ៩ | ២០ | ១៦ | ១៣ | |
| ៥ | ៩ | ១៧ | ៤ | | | | ១០ | ២០ | ១០ | | | | | ១២ | ៦ | | ២ | ៣០ | | | | | | |
| ៦ | ២០ | ៨ | ១ | | | ១ | ២៥ | ៤ | ២៥ | | | | | ១ | ៣ | | | ៥ | ២៥ | | ២៥ | ១៨ | ៧ | |
| ៧ | ១៧ | ១៦ | | | | | ១២ | ២១ | ៩ | ៣ | | ២ | | ៣ | | ១៤ | ២ | ២៦ | ៧ | ២ | ៥ | ៥ | ២ | |
| ៨ | ២០ | ១០ | | | | | ៩ | ២១ | ៨ | ១ | | | | | | ២១ | | ៣០ | | | | | | |
| ៩ | ២៨ | ១២ | | | | | ១៦ | ១៤ | ១៥ | | ១ | | | ៧ | | ៧ | | ១៣ | ១៧ | ៣ | ១៤ | ១២ | ៥ | |
| ១០ | ២៨ | ២ | | | | | ១១ | ១៩ | ១១ | | | | | ៦ | | ១៣ | | ២២ | ៨ | ១ | ៧ | ៦ | ២ | |
| ១១ | ២២ | ៤ | ១ | | | ៣ | ១ | ២៦ | ១ | | | ៥ | ១ | | | ១ | ១៩ | ៣០ | | | | | | |
| ១២ | ២២ | ៥ | ១ | | | ២ | ១ | ២៧ | ១ | | | ១ | | ៤ | | ២ | ២០ | ១៦ | ១៤ | ១៤ | | ៨ | ៥ | ១ |
| ១៣ | ១៦ | ១២ | | | ១ | ១ | ១៣ | ១៦ | ៨ | | ៥ | | | ១១ | ១ | ៤ | | ២៦ | ៤ | ១ | ៣ | ២ | ១ | ១ |
| ១៤ | ១៩ | ១១ | | | | | ២០ | ១០ | ១៨ | | ២ | | ១ | ៦ | | ១ | ២ | ២៣ | ៧ | ៤ | ៣ | ២ | ១ | ៤ |
| ១៥ | ១៩ | 9 | | | | ២ | | ២៨ | | | | | | | | | ២៨ | ៣០ | | | | | | |
| ១៦ | ៦ | ២២ | ១ | ១ | | | ៩ | ២១ | ៩ | | | | | ១ | ១ | ១៩ | | ៣០ | | | | | | |
| ១៧ | ១៩ | ១៣ | ១ | | | | ១៥ | ១៨ | ១៥ | | | | | | | ១៨ | | ២៩ | ៤ | ៤ | | ៤ | | |
| ១៨ | ១៥ | ១៦ | | | | | ៦ | ២៥ | ៦ | | | ១ | | | ២ | ២២ | | ២៧ | ៤ | ៤ | | ៣ | ១ | |
| សរុប | ៣៣៩ | ១៨៥ | ១១ | ១ | ២ | ៩ | ២៥០ | ២៨៨ | ២២៣ | ១៨ | ៩ | ១១ | ៣ | ៥៨ | ២១ | ១២២ | ៧៣ | ៣៩៣ | ១៤៥ | ៤៨ | ៩៧ | ៩៤ | ៤៣ | ៨ |

( សូមបញ្ជាក់ថា នៅតាមភូមិគោលដៅមិនមែនគ្រប់មាតាបិតាដែលមានកូនអាយុក្រោម៦ឆ្នាំទាំងអស់ចូលរួមក្នុងកម្មវិធីHBEនៅទេ ប៉ុន្តែការចូលរួមនោះគឺជាការស្ម័គ្រចិត្ត )

## ការវាយតម្លៃភាពងាយរងគ្រោះរបស់កុមារចំនួន ១៣00នាក់

តារាងទី៩: មានទិន្នន័យដែលទាក់ទងទៅនឹងកុមារចំនួន១៣00 នាក់ដែលមានអាយុ១៥ ឆ្នាំឬតិចជាងនេះ។ កុមារចំនួន៥៨% ក្នុងចំណោមកុមារទាំងនេះមានអាយុក្រោម ៦ឆ្នាំ។ ទិន្នន័យបានបង្ហាញថាកុមារចំនួន១៨% ដែលគ្រប់អាយុចូលរៀនពុំបានចុះឈ្មោះចូលរៀនទេ។ នៅក្នុងភូមិមួយចំនួនការអង្កេតបានរកឃើញថាកុមារប្រមាណ៥0% ដែលគ្រប់អាយុចូលរៀនពុំបានចុះឈ្មោះចូលរៀនទេ។

ចំពោះផ្នែកសុខភាព ការអង្កេតបានរកឃើញថា កុមារប្រមាណ៥% កំពុងទទួលរងការឈឺចាប់ពីជម្ងឺរ៉ាំរ៉ៃ ឬពិការភាពមួយចំនួន។ ម៉ែៗបានរាយការណ៍ថាកុមារចំនួន ១១% ដែលបានអង្កេតបានធ្លាក់ខ្លួនឈឺយ៉ាងហោចណាស់ក៏ម្តងដែរក្នុងរយៈពេល៦ខែកន្លងមកនេះ ហើយកុមារចំនួន១៤% បានទៅពិគ្រោះជាមួយវេជ្ជបណ្ឌិតក្នុងរយៈពេលដូចគ្នានេះដែរ។ ម៉ែៗក៏បានរាយការណ៍ផងដែរថា កុមារចំនួន៩% ក្នុងចំណោមកុមារសរុបទាំងអស់បានទៅសំរាកនៅមន្ទីរពេទ្យក្នុងរយៈពេល១២ខែកន្លងមកនេះ។

ការសិក្សានេះត្រូវបានធ្វើឡើងដើម្បីវាយតម្លៃពីភាពងាយរងគ្រោះរបស់កុមារចំនួន១៣00នាក់។ ការវាយតម្លៃគឺពឹងផ្អែកទៅលើទិន្នន័យដែលគេបានប្រមូលក្នុងពេលធ្វើសំភាសន៍ម៉ែៗនិងប្រធានភូមិ។ នៅក្នុងការរៀបចំការវាយតម្លៃការសិក្សានេះបានអនុវត្តនូវក្របខណ្ឌផ្នែកទ្រឹស្តីដែលបានរៀបរាប់នៅក្នុងជំពូកទី៣នៃការសិក្សានេះ។

តារាងទី១០: ពន្យល់ពីកត្តានិងការដាក់ពិន្ទុនៃការវាយតម្លៃ។ ការសិក្សានេះ វាយតម្លៃទៅលើភាពងាយរងគ្រោះរបស់កុមារ ដោយយោងទៅលើផលប៉ះពាល់នៃកត្តាចំនួន ២៥។ សម្រាប់កត្តានីមួយត្រូវបានគេឲ្យតម្លៃទៅតាមគណិតវិទ្យាតាមរយៈការកំណត់ចំនួនពិន្ទុដែលឆ្លុះបញ្ជាំងពីតម្លៃរបស់វា។ កត្តាមួយចំនួនក្នុងចំណោមកត្តាទាំងនោះមានតម្លៃជាអវិជ្ជមាននិងវិជ្ជមាន។ ដើម្បីរកឲ្យឃើញនូវកម្រិតនៃភាពងាយរងគ្រោះរបស់កុមារកុមារ កុមារម្នាក់ៗមានចំណុចចាប់ផ្តើមផ្សេងៗដែលវាមានតម្លៃខ្ពស់ជាងពិន្ទុនៃភាពរងគ្រោះណាមួយ។ នៅក្នុងការសិក្សានេះពិន្ទុចាប់ផ្តើមរបស់កុមារម្នាក់ៗមានចំនួន១៣០ពិន្ទុ។

ដំណើរការនៃការវាយតម្លៃត្រូវបានបូកបន្ថែម ឬដកចេញនូវកត្តាដែលអាចអនុវត្តបាន និងចំនួននៃពិន្ទុដែលជាលទ្ធផលនៃការគណនា តាមគណិតវិទ្យា គឺជាអ្នកសម្រេចនូវកម្រិតនៃភាពងាយរងគ្រោះរបស់កុមារ។ កុមារដែលមានពិន្ទុលើសពី១០0ពិន្ទុ ជាទូទៅត្រូវបានគេចាត់ទុកថាមិនស្ថិតនៅក្នុងស្ថានភាពនៃភាពរងគ្រោះទេ (មិនមានភាពងាយរងគ្រោះ)។ កុមារដែលមានពិន្ទុពី ៨១ ដល់ ១០0 ពិន្ទុ គឺស្ថិតនៅក្នុងកម្រិតនៃភាពងាយរងគ្រោះទាប (ភាពងាយរងគ្រោះទាប)។ កុមារដែលមានពិន្ទុពី ៥១ ទៅ ៨0ពិន្ទុ ស្ថិតនៅក្នុងភាពងាយរងគ្រោះមធ្យម (ភាពងាយរងគ្រោះមធ្យម)។ ចុងក្រោយកុមារដែលបានពិន្ទុ ៥0 ពិន្ទុឬទាបជាងនេះគឺស្ថិតនៅក្នុងភាពងាយរងគ្រោះខ្លាំង (ភាពងាយរងគ្រោះខ្លាំង)។

**តារាងទី១១ទី១២** បង្ហាញពីកម្រិតនៃភាពងាយរងគ្រោះនៅតាមភូមិនីមួយៗដោយផ្អែកទៅលើការដាក់ពិន្ទុនៃវាយតម្លៃ នៃភាពងាយរងគ្រោះរបស់កុមារ។ ការអង្កេតបានរកឃើញថាកុមារចំនួន២៣% មិនមែនជាកុមារដែលមានភាពងាយរងគ្រោះទេ ប៉ុន្តែនៅក្នុងភូមិចំនួន៦កុមារទាំងអស់ស្ថិតនៅក្នុងកម្រិតណាមួយនៃភាពងាយរងគ្រោះ។ ក្នុងពេលជាមួយគ្នានេះដែរការអង្កេតបានរកឃើញថាកុមារចំនួន២៣% ស្ថិតនៅក្នុងកម្រិតនៃភាពងាយរងគ្រោះខ្ពស់ដែលក្នុងចំណោមនោះកុមារត្រូវការយកចិត្តទុកដាក់និងការថែទាំខ្ពស់ដូចជាកុមារដែលមានជំងឺរ៉ាំរ៉ៃ និងពិការភាព។ តារាងទី ១១ បង្ហាញថាកុមារចំនួន ២៤% ស្ថិតនៅក្នុងកម្រិតនៃភាពងាយរងគ្រោះទាប និង ៣០% ស្ថិតនៅក្នុងកម្រិតនៃភាពងាយរងគ្រោះមធ្យម។

**តារាងទី១៣ ទី១៤ និងទី១៥** បង្ហាញពីពិន្ទុចំពោះការប្រែប្រួលទាំង៤ (ការអប់រំ សុខភាព ភាពក្រីក្រ និងភាពឯកកោ) និងកត្តានីមួយ។ ទិន្នន័យនៅក្នុងតារាងនេះបញ្ជាក់ពីសម្មតិកម្មមួយក្នុងចំណោមសម្មតិកម្មសំខាន់ៗនៃការស្រាវជ្រាវ ដែលថាពុំមានកត្តាតែមួយណាអាចសម្រេចដោយខ្លួនឯងបាន ចំពោះភាពងាយរងគ្រោះរបស់កុមារទេ ហើយភាពងាយរងគ្រោះគឺជាលទ្ធផលនៃឥទ្ធិពលដែលរួមបញ្ចូលគ្នា ដែលមានចំនួនច្រើនជាងកត្តាតែមួយ។ កត្តាពិការភាពនិងជម្ងឺរ៉ាំរ៉ៃ គឺជាកត្តាតែមួយគត់ដែលទំនងជាធ្វើឲ្យកុមារស្ថិតនៅក្នុងកម្រិតនៃភាពងាយរងគ្រោះច្រើនបំផុត ដោយសារកត្តាទាំងនោះតាមធម្មតាធ្វើឲ្យកុមារស្ថិតនៅក្នុងហានិភ័យ និងស្ថានភាពនៃភាពងាយរងគ្រោះខ្ពស់។ ចំពោះហេតុផលនោះវាជារឿងត្រឹមត្រូវក្នុងការសន្មតថា កុមារពិការទាំងអស់ ឬដែលទទួលរងការឈឺចាប់ពីជម្ងឺរ៉ាំរ៉ៃ គឺជាកុមារដែលងាយរងគ្រោះ។

ការសិក្សានេះពុំបានប្រើប្រាស់ការសង្កេត (០១ សូមមើលតារាងទី១០) ដោយសារតែរបៀបប្រមូលទិន្នន័យសង្កេតមិនមែនជាទិសដៅ។ ដូច្នេះក្រុមប្រមូលទិន្នន័យបានកត់សំគាល់ថា ការសំភាសន៍ចំនួន៦២ លើកជាមួយម៉ែៗ (ប្រមាណជា១២% នៃម៉ែៗទាំងអស់ដែលបានសំភាសន៍) មានកុមារដែលមានជម្ងឺកង្វះអាហារូបត្ថម្ភ។ ក្រុមក៏បានកត់សម្គាល់ផងដែរនូវករណីនៃការញៀនសូរានិងបរិយាកាសផ្ទះសម្បែងដែលពុំមានអនាម័យ។

# តារាងទី៩- កុមារដែលការសិក្សានេះបានវាយតម្លៃ - អាយុ ការចុះឈ្មោះចូលរៀន មានជម្ងឺរ៉ាំរ៉ៃ ព័ត៌មានផ្នែកសុខភាព

| លេខកូដភូមិ | អាយុកុមារ | | | | | | | | | | | | | | | | ការចុះឈ្មោះចូលរៀនអាយុពី៦-១៥ឆ្នាំ | | កុមារពិការ | កុមារមានជម្ងឺរ៉ាំរ៉ៃ | មានជម្ងឺក្នុងរយៈពេល៦ខែកន្លងមក | ទៅឲ្យពេទ្យពិនិត្យ ក្នុងរយៈពេល៦ខែកម្លងមក | សម្រាកពេទ្យកាលពីឆ្នាំមុន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | សរុប | មិនបានចុះឈ្មោះ | ចុះឈ្មោះ | | | | | |
| ១ | ១ | ១ | ៥ | ១២ | ១៧ | ៤ | ៤ | ៨ | ៦ | ៥ | ៣ | ៥ | | ៣ | | ៧៤ | ២ | ៣៦ | ១ | ២ | ៤ | ១០ | ៥ |
| ២ | ២ | ១ | ១ | ១១ | ១៨ | ៤ | ៥ | ៩ | ៣ | ៥ | ១ | ៣ | ១ | ២ | ២ | ៦៨ | | ៣៥ | ១ | ៣ | ៤ | ៥ | ៧ |
| ៣ | ៥ | ៦ | ២ | ៨ | ២០ | ៤ | ៥ | ២ | ៨ | ៤ | ៣ | ៩ | ១ | ៣ | ២ | ៨២ | ៣ | ៣៨ | ០ | ០ | ១០ | ១៣ | ៧ |
| ៤ | ៥ | ៣ | ៩ | ១៥ | ៧ | ៤ | ២ | ២ | ៤ | ៤ | ១ | | ១ | | | ៥៧ | | ១៨ | ០ | ៣ | ៧ | ៩ | ៤ |
| ៥ | ១៣ | ៨ | ១១ | ៦ | ១៧ | ៨ | ១ | ៤ | ១ | ២ | ១ | ១ | ២ | | ១ | ៧៦ | ៣ | ១៨ | ០ | ២ | ៤ | ២១ | ៩ |
| ៦ | ៤ | ៣ | ៧ | ៥ | ២០ | ២ | ៤ | ៣ | ៣ | ៣ | ១ | ៤ | ១ | ៤ | ២ | ៦៦ | | ២៧ | ០ | ១ | ៣ | ១៤ | ៤ |
| ៧ | ១២ | ១២ | ២ | ៩ | ១៤ | ៥ | ៣ | ១ | ៦ | ២ | ៣ | ៧ | ២ | ២ | | ៨០ | ១ | ៣០ | ០ | ០ | ៣ | ១១ | ១០ |
| ៨ | ១២ | ៦ | ៩ | ៦ | ១២ | ៤ | ៥ | ២ | ៥ | ២ | ៦ | ៤ | ៣ | ១ | ៣ | ៨០ | ៤ | ៣១ | ០ | ០ | ០ | ១ | ១ |
| ៩ | ១២ | ៤ | ៤ | ១២ | ១២ | ២ | ៧ | ៦ | ៤ | | ៤ | ១ | ៧ | ១ | | ៧៦ | | ៣២ | ០ | ៩ | ៤ | ៥ | ៥ |
| ១០ | ១១ | ៥ | ៥ | ៥ | ៦ | ៥ | ៤ | ១ | | ៤ | ៣ | ៣ | ៣ | ៣ | ២ | ៦០ | ៨ | ២០ | ០ | ៤ | ១១ | ១១ | ៧ |
| ១១ | ៤ | ៧ | ៦ | ៥ | ១៣ | ៤ | ៣ | ៤ | ៥ | ៤ | ១ | ៣ | ៣ | ២ | ១ | ៦៥ | ៦ | ២៤ | ១ | ៥ | ១៣ | ១៤ | ៤ |
| ១២ | ៣ | ៦ | ៨ | ៣ | ១១ | ៤ | ២ | ២ | ២ | ៤ | ២ | ២ | ៥ | ១ | ៣ | ៥៨ | ៦ | ២១ | ២ | ២ | ៨ | ៨ | ២ |
| ១៣ | ៨ | ៧ | ៤ | ៧ | ១៥ | ៦ | ៦ | ៥ | ៣ | ៥ | ៤ | ២ | ៦ | ១ | ៣ | ៨២ | ១៥ | ២៦ | ១ | ៧ | ១៨ | ១៥ | ១០ |
| ១៤ | ៧ | ៦ | ៤ | ៨ | ១៧ | ២ | ២ | ៣ | ៦ | ១ | ៥ | ១ | ២ | ២ | | ៦៦ | ៦ | ១៨ | ០ | ៥ | ១៨ | ១៤ | ១០ |
| ១៥ | ១០ | ៤ | ១០ | ៧ | ៨ | ៧ | ៦ | ៥ | ២ | ៤ | ២ | ៨ | ៤ | ២ | ៤ | ៨៣ | ១៥ | ២៩ | ០ | ៥ | ១៦ | ១៦ | ១៣ |
| ១៦ | ១៦ | ៧ | ៨ | ៨ | ១៤ | ៥ | ៥ | ២ | ១ | ១ | ១ | ២ | | ២ | ១ | ៧៣ | ៦ | ១៤ | ១ | ៣ | ៩ | ៦ | ៩ |
| ១៧ | ១៧ | ៧ | ៤ | ១២ | ៧ | | ៣ | ៤ | ២ | ៣ | ៤ | ៤ | ៥ | ៤ | ១ | ៧៧ | ១១ | ១៩ | ០ | ១ | ៧ | ៦ | ៥ |
| ១៨ | ១៧ | ៥ | ៥ | ១២ | ៩ | ២ | ១ | ៣ | ២ | ៦ | ២ | ៤ | 2 | ៣ | ៤ | ៧៧ | ១៤ | ១៥ | ០ | ០ | ១ | ២ | ២ |
| | ១៥៩ | ៩៨ | ១០៤ | ១៥១ | ២៣៧ | ៧២ | ៦៨ | ៦៦ | ៦៣ | ៥៩ | ៤៧ | ៦៣ | ៤៨ | ៣៦ | ២៩ | ១៣០០ | ១០០ | ៤៥១ | ៧ | ៥២ | ១៤០ | ១៨១ | ១១៤ |

| តារាងទី១០-ពិន្ទុនៃការវាយតម្លៃនៃភាពងាយរងគ្រោះរបស់កុមារ | | | |
|---|---|---|---|
| ពិន្ទុ | សូចនាករនៃភាពងាយរងគ្រោះ | ការប្រែប្រួលនៃភាពងាយរងគ្រោះ | COD |
| -៥០ | កុមារដែលគ្រប់អាយុចូលរៀន តែមិនបានចុះឈ្មោះចូលរៀន | ការអប់រំ | E១ |
| -៣០ | សម្រាប់កុមារដែលមានបងប្អូនគ្រប់អាយុចូលរៀន ប៉ុន្តែមិនបានចុះឈ្មោះចូលរៀន | | |
| ១០ | ការចុះឈ្មោះចូលរៀននៅមតេយ្យសិក្សា | ការអប់រំ | E៣ |
| -១០ | សាលាបឋមសិក្សាដែលនៅជិតបំផុតមានចំងាយ៥គីឡូម៉ែត្រ | ការអប់រំ | E៤ |
| ១០ | កម្រិតនៃការអប់រំរបស់ម៉ែលើសពីថ្នាក់បឋមសិក្សា | ការអប់រំ | E៥ |
| -១០ | ម៉ែមិនចេះអាន ឬសរសេរ | ការអប់រំ | E៦ |
| -៣០ | ប្រាក់ចំណូលរបស់គ្រួសារតិចជាង៣០ $ក្នុងមួយខែ (មិនមែនកសិករ) | ភាពក្រីក្រ | P១ |
| -៣០ | គ្រួសារពុំមានដីធ្លី (កសិករ) | ភាពក្រីក្រ | P២ |
| -១០ | ម៉ែដែលចិញ្ចឹមកូនឯងតែឯង | ភាពក្រីក្រ | P៣ |
| -១០ | ប្រសិនបើមណ្ឌលសុខភាពដែលនៅជិតបំផុតមានចំងាយ ៥គីឡូម៉ែត្រ | ភាពនៅដាច់ឆ្ងាយពីគេ | IS១ |
| -១០ | ប្រសិនបើមន្ទីរពេទ្យដែលនៅជិតបំផុតមានចំងាយលើសពី ២៥គីឡូម៉ែត្រ | ភាពនៅដាច់ឆ្ងាយពីគេ | IS២ |
| -១០ | ប្រសិនបើទីក្រុងដែលនៅជិតបំផុតមានចំងាយលើសពី ៥០គីឡូម៉ែត្រ | ភាពនៅដាច់ឆ្ងាយពីគេ | IS៣ |
| -១០ | ស្ថិតនៅក្នុងក្រុមជនជាតិភាគតិច | ភាពនៅដាច់ឆ្ងាយពីគេ | IS៤ |
| -១០ | ពុំមានអគ្គីសនី | ភាពនៅដាច់ឆ្ងាយពីគេ | IS៥ |
| ១០ | រស់នៅក្នុងគ្រួសារដែលមានសមាជិកច្រើន | ភាពនៅដាច់ឆ្ងាយពីគេ | IS៦ |
| -១០ | ពុំមានបណ្តាញទូរស័ព្ទចល័ត | ភាពនៅដាច់ឆ្ងាយពីគេ | IS៧ |
| -១០ | ពុំមានគម្រោងដែលអនុវត្តដោយ NGO ក្នុងរយៈពេល៥ឆ្នាំកន្លងមក | ភាពនៅដាច់ឆ្ងាយពីគេ | IS៨ |
| -១១០ | ពិការភាព | សុខភាព | H១ |
| -១១០ | មានជម្ងឺរ៉ាំរ៉ៃ | សុខភាព | H២ |
| -១០ | ពុំមានទឹកស្អាតសម្រាប់ទទួលទាន | សុខភាព | H៣ |
| -២០ | សម្រាប់កុមារដែលបងប្អូនរបស់គេមានជម្ងឺរ៉ាំរ៉ៃ ឬពិការភាព | សុខភាព | H៤ |
| -៣០ | ទៅសម្រាកពេទ្យកាលពីឆ្នាំមុន | សុខភាព | H៥ |
| -២០ | មានជម្ងឺកាលពី៦ខែមុន | សុខភាព | H៦ |
| ១០ | ទៅឲ្យវិជ្ជបណ្ឌិតពិនិត្យកាលពី៦ខែមុន | សុខភាព | H៧ |
| - រហូតដល់៤០ | កត្តានៃការសង្កេត ៖ ដូចជាបរិយាកាសដែលបង្កឲ្យមានជម្ងឺ អំពើហឹង្សាក្នុងគ្រួសារ ការញៀនស្រា និងគ្រឿងញៀន | | O១ |

តារាងទី១១ -១២ កម្រិតនៃភាពងាយរងគ្រោះរបស់កុមារដោយផ្អែកលើការវាយតម្លៃពីភាពងាយរងគ្រោះរបស់កុមារ

| លេខកូដភូមិ | ពុំមានភាពងាយរងគ្រោះ | | មានភាពងាយរងគ្រោះទាប | | មានភាពងាយរងគ្រោះមធ្យម | | មានភាពងាយរងគ្រោះខ្ពស់ | | សរុប |
|---|---|---|---|---|---|---|---|---|---|
| | # របស់កុមារ | % | # របស់កុមារ | % | # របស់កុមារ | % | # របស់កុមារ | % | |
| ១ | ៥៨ | ៧៨ | ៨ | ១១ | ៤ | ៥ | ៤ | ៥ | ៧៤ |
| ២ | ៤៦ | ៦៨ | ៨ | ១២ | ៨ | ១២ | ៦ | ៩ | ៦៨ |
| ៣ | ៥២ | ៦៣ | ១៤ | ១៧ | ១៤ | ១៧ | ២ | ២ | ៨២ |
| ៤ | ៣៤ | ៦០ | ១៦ | ២៨ | ២ | ៤ | ៥ | ៩ | ៥៧ |
| ៥ | ៨ | ១១ | ៣២ | ៤២ | ២៦ | ៣៤ | ១០ | ១៣ | ៧៦ |
| ៦ | ៥៧ | ៨៦ | ៧ | ១១ | ១ | ២ | ១ | ២ | ៦៦ |
| ៧ | ៣ | ៤ | ២៧ | ៣៤ | ៤០ | ៥០ | ១០ | ១៣ | ៨០ |
| ៨ | ៥ | ៦ | ២២ | ២៨ | ៣៦ | ៤៥ | ១៧ | ២១ | ៨០ |
| ៩ | ០ | ០ | ២៨ | ៣៧ | ៣២ | ៤២ | ១៦ | ២១ | ៧៦ |
| ១០ | ៥ | ៨ | ២២ | ៣៧ | ១៥ | ២៥ | ១៨ | ៣០ | ៦០ |
| ១១ | ០ | ០ | ០ | ០ | ៣៥ | ៥៤ | ៣០ | ៤៦ | ៦៥ |
| ១២ | ០ | ០ | ២ | ៣ | ៣៨ | ៦៦ | ១៨ | ៣១ | ៥៨ |
| ១៣ | ២ | ២ | ២២ | ២៧ | ២៨ | ៣៤ | ៣ | ៣៧ | ៨២ |
| ១៤ | ១៥ | ២៣ | ១៥ | ២៣ | ២៣ | ៣៥ | ១៣ | ២០ | ៦៦ |
| ១៥ | ០ | ០ | ៣២ | ៣៩ | ២០ | ២៤ | ៣១ | ៣៧ | ៨៣ |
| ១៦ | ៩ | ១២ | ១៦ | ២២ | ១៨ | ២៥ | ៣០ | ៤១ | ៧៣ |
| ១៧ | ៤ | ៥ | ២៧ | ៣៥ | ២៧ | ៣៥ | ១៩ | ២៥ | ៧៧ |
| ១៨ | ០ | ០ | ១៣ | ១៧ | ២០ | ២៦ | ៤៤ | ៥៧ | ៧៧ |
| សរុប | ២៩៨ | ២៣ | ៣១១ | ២៤ | ៣៨៧ | ៣០ | ៣០៤ | ២៣ | ១៣០០ |

តារាងទី១៣ - ពិន្ទុនៃកត្តានៃភាពប្រែប្រួលរបស់ភាពក្រីក្រ

| លេខកូដភូមិ | P១ | P១% | P២ | P២% | P៣ | P3% | ពិន្ទុសរុប | P- សរុប % |
|---|---|---|---|---|---|---|---|---|
| ១ | ១៨០ | ៤ | ០ | ០ | ១១០ | ៣ | ៤១៦០ | ៧ |
| ២ | ៦០ | ១ | ១២០ | ៣ | ១៤០ | ៣ | ៤២១០ | ៨ |
| ៣ | ៣៣០ | ៧ | ៩០ | ២ | ២១០ | ៥ | ៤៦៣០ | ១៤ |
| ៤ | ០ | ០ | ០ | ០ | ១០០ | ៣ | ៣០៧០ | ៣ |
| ៥ | ០ | ០ | ០ | ០ | ៥០ | ១ | ៤៨៥០ | ១ |
| ៦ | ៦០ | ២ | ៣០ | ១ | ៥០ | ២ | ២៦១០ | ៥ |
| ៧ | ៣០ | ១ | ០ | ០ | ២៧០ | ៥ | ៥៨២០ | ៥ |
| ៨ | ២៧០ | ៥ | ០ | ០ | ១៣០ | ២ | ៥៣២០ | ៨ |
| ៩ | ០ | ០ | ០ | ០ | ៩០ | ២ | ៥៣៧០ | ២ |
| ១០ | ០ | ០ | ០ | ០ | ៣០ | ១ | ៤៧៣០ | ១ |
| ១១ | ០ | ០ | ៩០ | 2 | ១០ | ០ | ៥៤២០ | ២ |
| ១២ | ០ | ០ | ០ | ០ | ៨០ | ២ | ៥០៥០ | ២ |
| ១៣ | ០ | ០ | ២១០ | ៣ | ៨០ | ១ | ៧៣០០ | ៤ |
| ១៤ | ០ | ០ | ២៧០ | ៥ | ៦០ | ១ | ៤៩២០ | ៧ |
| ១៥ | ០ | ០ | ០ | ០ | ៣០ | ០ | ៦១៦០ | ០ |
| ១៦ | ៦០ | ១ | ០ | ០ | ៩០ | ២ | ៥៦៥០ | ៣ |
| ១៧ | ៦០ | ១ | ០ | ០ | ១២០ | ២ | ៦១៨០ | ៣ |
| ១៨ | ៩០ | ១ | ០ | ០ | ២២០ | ៣ | ៧៣៥៩ | ៤ |

តារាងទី ១៤ - ការដាក់ពិន្ទុកត្តានៃភាពប្រែប្រួលចំពោះភាពនៅដាច់ឆ្ងាយពីគេ

| លេខកូដភូមិ | *IS១ (-១០)* | *IS1%* | IS២ (-១០) | IS២% | IS៣ (-១០) | IS៣% | IS៤ (-១០) | IS៤% | IS៥ (-១០) | IS៥% | IS៦ (+១០) | IS៦% | IS៧ (-១០) | IS៧% | IS៨ (-១០) | IS៨% | ពិន្ទុសរុប | IS-សរុប-% |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | 0 | 0 | 0 | 0 | 0 | 0 | ៥0 | ១ | ៦៦0 | ១៦ | ៣៥0 | ៨ | ៣0 | ១ | 0 | 0 | ៤១៦0 | ២៦ |
| ២ | 0 | 0 | 0 | 0 | ៦៨0 | ១៦ | 0 | 0 | ៦00 | ១៤ | ៣៣0 | ៨ | ១២0 | ៣ | 0 | 0 | ៤២១0 | ៤១ |
| ៣ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | ៦៨0 | ១៥ | ២៧0 | ៦ | ២៧0 | ៦ | 0 | 0 | ៤៦៣0 | ២៦ |
| ៤ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | ៥៧0 | ១៩ | ១១0 | ៤ | ២៣0 | ៧ | 0 | 0 | ៣0៧0 | ៣0 |
| ៥ | ៧៦0 | ១៦ | 0 | 0 | 0 | 0 | 0 | 0 | ៧៦0 | ១៦ | ១00 | ២ | ៤១0 | ៨ | 0 | 0 | ៤៨៥0 | ៤២ |
| ៦ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | ៦៣0 | ២៤ | ៥0 | ២ | ៧0 | ៣ | 0 | 0 | ២៦១0 | ២៩ |
| ៧ | ៧៩0 | ១៤ | ៧៩0 | ១៤ | ៧៩0 | ១៤ | 0 | 0 | ៥៧0 | ១0 | ២៣0 | ៤ | ៣៦0 | ៦ | 0 | 0 | ៥៨២0 | ៦១ |
| ៨ | 0 | 0 | ៨00 | ១៥ | ៨00 | ១៥ | 0 | 0 | ៦៩0 | ១៣ | ១៤0 | ៣ | ៤៩0 | ៩ | 0 | 0 | ៥៣២0 | ៥៥ |
| ៩ | ៦៩0 | ១៣ | ៦៩0 | ១៣ | ៦៩0 | ១៣ | 0 | 0 | ៥៦0 | ១0 | ១៧0 | ៣ | ២៤0 | ៤ | 0 | 0 | ៥៣៧0 | ៥៧ |
| ១0 | ៦00 | ១៣ | ៦00 | ១៣ | 0 | 0 | 0 | 0 | ៣៤0 | ៧ | ៨0 | ២ | ១៩0 | ៤ | 0 | 0 | ៤៧៣0 | ៣៨ |
| ១១ | ៥៩0 | ១១ | ៥៩0 | ១១ | ៥៩0 | ១១ | 0 | 0 | ៥៧0 | ១១ | ៧0 | ១ | ៣៤0 | ៦ | 0 | 0 | ៥៤២0 | ៥១ |
| ១២ | ៥៨0 | ១១ | ៥៨0 | ១១ | ៥៨0 | ១១ | ៣0 | ១ | ៥១0 | ១0 | ៦0 | ១ | ២៧0 | ៥ | 0 | 0 | ៥0៥0 | ៥២ |
| ១៣ | ៨២0 | ១១ | 0 | 0 | 0 | 0 | 0 | 0 | ៧១0 | ១0 | ២00 | ៣ | ២៦0 | ៤ | 0 | 0 | ៧៣00 | ២៧ |
| ១៤ | ៦៤0 | ១៣ | 0 | 0 | 0 | 0 | 0 | 0 | 450 | 9 | ១២0 | ២ | ១៥0 | ៣ | 0 | 0 | ៤៩២0 | ២៨ |
| ១៥ | ៨៣0 | ១៣ | 0 | 0 | 0 | 0 | 0 | 0 | 790 | 13 | ១១0 | ២ | ២៩0 | ៥ | 0 | 0 | ៦១៦0 | ៣៣ |
| ១៦ | 0 | 0 | ៧១0 | ១៣ | ៧១0 | ១៣ | ២0 | 0 | 710 | 13 | ១៥0 | ៣ | ២៨0 | ៥ | 0 | 0 | ៥៦៥0 | ៤៦ |
| ១៧ | ៧៦0 | ១២ | ៧៦0 | ១២ | ៧៦0 | ១២ | ២0 | 0 | 700 | 11 | ៣២0 | ៥ | ១00 | ២ | 0 | 0 | ៦១៨0 | ៥៥ |
| ១៨ | ៧៧0 | ១0 | ៧៧0 | ១១ | ៧៧0 | ១0 | ២0 | 0 | 770 | 10 | ២៧0 | ៤ | ២៦0 | ៤ | ៧៧0 | ១0 | ៧៣៥៩ | ៦0 |

តារាងទី១៥ - ការដាក់ពិន្ទុនៃកត្តានៃភាពប្រែប្រួលផ្នែកសុខភាព

| លេខ កូដ ភូមិ | H១ (-១១០) | H១% | H២ (-១១០) | H2% | H3 (-១០) | H3% | H៤ (-២០) | H៤% | H៥ (-៣០) | H៥% | H៦ (-២០) | H៦% | H៧ (+១០) | H៧% | ពិន្ទុសរុប | H សរុប % |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ១១០ | ៣ | ៣០០ | ៧ | ៧៤០ | ១៨ | ៤០ | ១ | 150 | ៤ | ៨០ | ២ | ១០០ | ២ | ៤១៦០ | ៣៧ |
| ២ | ១១០ | ៣ | ៤១០ | ១០ | ៦៨០ | ១៦ | ៤០ | ១ | ១០ | ០ | ៨០ | ២ | ៥០ | ១ | ៤២១០ | ៣៣ |
| ៣ | ០ | ០ | ០ | ០ | ៨២០ | ១៨ | ០ | ០ | ២១០ | ៥ | ២០០ | ៤ | ១៣០ | ៣ | ៤៦៣០ | ២៩ |
| ៤ | ០ | ០ | ៣៧០ | ១២ | ៥៧០ | ១៩ | ០ | ០ | ១២០ | ៤ | ១៤០ | ៥ | ៩០ | ៣ | ៣០៧០ | ៤២ |
| ៥ | ០ | ០ | ៣៦០ | ៧ | ៧៥០ | ១៥ | ០ | ០ | ២៧០ | ៦ | ៨០ | ២ | ២១០ | ៤ | ៤៨៥០ | ៣៤ |
| ៦ | ០ | ០ | ២០ | ១ | ៦៣០ | ២៤ | ០ | ០ | ៩០ | ៣ | ២០ | ១ | ១២០ | ៥ | ២៦១០ | ៣៤ |
| ៧ | ០ | ០ | ០ | ០ | ៧៩០ | ១៤ | ០ | ០ | ២៧០ | ៥ | ៦០ | ១ | ១០០ | ២ | ៥៨២០ | ២១ |
| ៨ | ០ | ០ | ០ | ០ | ៨០០ | ១៥ | ០ | ០ | ៣០ | ១ | ០ | ០ | ១០ | ០ | ៥៣២០ | ១៦ |
| ៩ | ០ | ០ | ៦៩០ | ១៣ | ៦៩០ | ១៣ | ០ | ០ | ៩០ | ២ | ៦០ | ១ | ៣០ | ១ | ៥៣៧០ | ២៩ |
| ១០ | ០ | ០ | ៤៨០ | ១០ | ៦០០ | ១៣ | ០ | ០ | ២១០ | ៤ | ២២០ | ៥ | ១១០ | ២ | ៤៧៣០ | ៣៤ |
| ១១ | ១១០ | ២ | ៤៧០ | ៩ | ៥៩០ | ១១ | 40 | ១ | ៦០ | ១ | ១៨០ | ៣ | ១០០ | ២ | ៥៤២០ | ២៩ |
| ១២ | ២២០ | ៤ | ៣០០ | ៦ | ៥១០ | ១០ | ១០០ | ២ | ៦០ | ១ | ១៦០ | ៣ | ៨០ | ២ | ៥០៥០ | ២៨ |
| ១៣ | ១១០ | ២ | ១០៣០ | ១៤ | ៨២០ | ១១ | ៦០ | ១ | ៣០០ | ៤ | ៣៦០ | ៥ | ១៥០ | ២ | ៧៣០០ | ៣៩ |
| ១៤ | ០ | ០ | ៥៦០ | ១១ | ៦៤០ | ១៣ | ០ | ០ | ២៧០ | ៥ | ៣២០ | ៧ | ១២០ | ២ | ៤៩២០ | ៣៩ |
| ១៥ | ០ | ០ | ៦៧០ | ១១ | ៧៩០ | ១៣ | ០ | ០ | ៣៩០ | ៦ | ៣២០ | ៥ | ១៦០ | ៣ | ៦១៦០ | ៣៨ |
| ១៦ | ១១០ | ២ | ៣០០ | ៥ | ៦៩០ | ១២ | ៦០ | ១ | ២៧០ | ៥ | ១៨០ | ៣ | ៦០ | ១ | ៥៦៥០ | ៣០ |
| ១៧ | ០ | ០ | ១១០ | ២ | ៧៤០ | ១២ | ០ | ០ | ១២០ | ២ | ១៤០ | ២ | ៦០ | ១ | ៦១៨០ | ១៩ |
| ១៨ | ០ | ០ | ០ | ០ | ៧៧០ | ១០ | ០ | ០ | ៦០ | ១ | ២០ | ០ | ២០ | ០ | ៧៣៥៩ | ១២ |

## ៥.ការវាយតម្លៃកម្មវិធីអប់រំតាមខ្នងផ្ទះ

ក្រុមស្រាវជ្រាវមិនអាចរកបាននូវការសិក្សាដែលបានបោះពុម្ពផ្សព្វផ្សាយណាមួយចំពោះការវាយតម្លៃពីកម្មវិធីអប់រំតាមខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជាឲ្យបានល្អិតល្អន់ និងគ្រប់ជ្រុងជ្រោយទេ។ មានការសិក្សា២-៣ដែលទាក់ទងនឹងកម្មវិធីដែលជាផ្នែកមួយនៃការវាយតម្លៃរបស់ខ្លួនទៅលើកម្មវិធីអប់រំកុមារតូចទាំងមូលនៅក្នុងប្រទេសកម្ពុជា។

ការសិក្សាដែលលេចធ្លោមួយ គឺជាការសិក្សាដែលត្រូវបានផ្តល់មូលនិធិដោយអង្គការ UNICEF នឹងត្រូវបានធ្វើឡើងដោយ Nirma Rao និង Emma Pearson (២០០៧)។ ការសិក្សានេះតម្រង់ទៅរកការវាយតម្លៃពីប្រសិទ្ធភាពរបស់កម្មវិធីអប់រំកុមារតូចនៅក្នុងប្រទេសកម្ពុជាដោយរាប់បញ្ចូលទាំងកម្មវិធីអប់រំតាមខ្នងផ្ទះផងដែរ។ ការវិនិច្ឆ័យរបស់ពួកគាត់ គឺមានមូលដ្ឋានលើឥទ្ធិពលរបស់កម្មវិធីទៅលើការអភិវឌ្ឍន៍នៃការអប់រំកុមារ។ វិធីសាស្ត្រនៃការស្រាវជ្រាវមួយបានដាក់បញ្ចូលនូវការបង្កើតក្រុមកុមារចំនួន៤ក្រុម ដែលក្រុមនីមួយៗក្នុងចំណោមក្រុមទាំងនោះទាក់ទងនឹងកម្មវិធីមួយក្នុងចំណោមកម្មវិធីអប់រំកុមារតូចនៅក្នុងប្រេទេសកម្ពុជា (មតេយ្យសិក្សារដ្ឋ មតេយ្យសិក្សាសហគមន៍ មតេយ្យសិក្សាតាមខ្នងផ្ទះ និងក្រុមគ្រប់គ្រងសម្រាប់កុមារដែលមិនបានចុះឈ្មោះចូលរៀននៅក្នុងកម្មវិធីណាមួយ)។ អ្នកស្រាវជ្រាវបានវាយតម្លៃទៅលើក្រុមកុមារទាំង៤ ចំនួន២ដងដើម្បីប្រៀបធៀប ការអភិវឌ្ឍន៍លើការអប់រំរបស់ក្រុមនីមួយៗនៅក្នុងរយៈពេល១ឆ្នាំ។

នៅលើប្រធានបទរបស់កម្មវិធីអប់រំតាមខ្នងផ្ទះ Nirma Rao និង Emma Pearson បានរកឃើញថា "ពុំមានការខុសគ្នាទេ រវាងកុមារដែលរៀននៅមតេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំតាមខ្នងផ្ទះនៅក្នុងការធ្វើតេស្ត មុនពេលចូលរៀន និងក្រោយពេលចូលរៀន" (Rao ឆ្នាំ ២០០៧)។ នៅក្នុងពេលជាមួយគ្នានោះដែរ អ្នកនិពន្ធបានបង្ហាញនូវទស្សនៈជាច្រើនរបស់ភាគីពាក់ព័ន្ធតាមរយៈការលើកសរសើរកម្មវិធីអប់រំតាមខ្នងផ្ទះ "ចំពោះតួនាទីរបស់កម្មវិធីគឺការការអប់រំម្តាយចំពោះការអភិវឌ្ឍន៍កូន និងចំពោះការផ្តល់អំណាចដល់ពួកគាត់ ដើម្បីឲ្យក្លាយជាម្តាយដែលកាន់តែប្រសើរឡើង"(Raoឆ្នាំ២០០៧)។ ការស្រាវជ្រាវបានសន្និដ្ឋាននៅជាពាក្យសំដីរបស់អ្នកនិពន្ធថា "ការរកឃើញដ៏សំខាន់របស់យើងបានលើកឡើងថា ប្រសិនបើកុមារមិនអាចទៅមតេយ្យសិក្សារដ្ឋបាន កុមារទាំងនោះបានទទួលផលប្រយោជន៍ស្រដៀងគ្នានេះដែរ ពីមតេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំតាមខ្នងផ្ទះ" (Rao ឆ្នាំ ២០០៧)។

បញ្ហាដែលរកឃើញនៃការស្រាវជ្រាវដែលបានលើកឡើងពីខាងដើម និងសេចក្តីសន្និដ្ឋានរបស់កម្មវិធីអប់រំតាមខ្នងផ្ទះដែលការស្រាវជ្រាវនោះ បានបង្ហាញពីសេចក្តីសន្និដ្ឋានរបស់ខ្លួន ប៉ុន្តែការស្រាវជ្រាវនោះពុំបានពន្យល់ពីមូលហេតុដែលកម្មវិធីអប់រំតាមខ្នងផ្ទះមានប្រសិទ្ធភាពដូចគ្នានឹងកម្មវិធី មតេយ្យសិក្សាសហគមន៍ទេ។ សូម្បីតែអ្នកនិពន្ធក៏បានសារភាពដែរថា ភាគីដែលពាក់ព័ន្ធភាគច្រើនមានគំនិតខុសគ្នា "រាប់បញ្ចូលទាំងមន្ត្រីរដ្ឋាភិបាល គ្រូបង្រៀនសមាជិកក្រុមប្រឹក្សាឃុំសង្កាត់និងឪពុកម្តាយរបស់ខ្លួនឯងផ្ទាល់" (Rao ឆ្នាំ ២០០៧)។ ម៉្យាងវិញទៀតមានសំណួរ

មួយចំនួនទាក់ទងនឹងមធ្យោបាយដែលក្រុមកុមារដែលបានរៀននៅក្នុងកម្មវិធីអប់រំតាមខ្នងផ្ទះត្រូវបានគេប្រមូលផ្តុំ។ ការស្រាវជ្រាវបានសង្កត់ធ្ងន់ថាកុមារចំនួន ៧២% ដែលស្ថិតនៅក្នុងក្រុមកុមារដែលរៀននៅក្នុងកម្មវិធីអប់រំតាមខ្នងផ្ទះបានចូលរៀននៅមតេយ្យសិក្សារដ្ឋ ឬមតេយ្យសហគមន៍ដែរ ដែលធ្វើឲ្យមានការលំបាកក្នុងការមិនគិតគូរដល់ឥទ្ធិពលរបស់កម្មវិធីផ្សេងៗទៀត ទៅលើការអភិវឌ្ឍន៍កុមារទាំងនេះ ហើយធ្វើការសន្និដ្ឋានពីការអភិវឌ្ឍន៍របស់ពួកវាដោយផ្អែកលើលទ្ធផលនៃឥទ្ធិពលរបស់កម្មវិធីអប់រំតាមខ្នង ផ្ទះតែមួយមុខប៉ុណ្ណោះ។

ការវាយតម្លៃទៅលើកម្មវិធីអប់រំណាមួយអាចមានមូលដ្ឋានលើប្រការមួយចំនួនដូចជា៖ ១)ភាពត្រឹមត្រូវនិងទិសដៅរបស់កម្មវិធី២) ការរៀបចំនិងការអនុវត្តរបស់កម្មវិធី និងទី៣) លទ្ធផលនិងឥទ្ធិពល។

## ភាពត្រឹមត្រូវនិងទិសដៅរបស់កម្មវិធី

ភាពត្រឹមត្រូវសម្រាប់កម្មវិធីអប់រំតាមខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជាមានមូលដ្ឋានលើការពិតចំនួន២ ៖ ទី១ ដោយសារលទ្ធផលនៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាថ្មីៗនេះ និងស្ថានភាពសេដ្ឋកិច្ចនិងសង្គមរបស់ប្រទេស ស្ត្រីភាគច្រើនពុំបានទទួលការអប់រំជាផ្លូវការត្រឹមត្រូវទេ ហើយក៏មានការខ្វះខាតជំនាញក្នុងនាមជាឪពុកម្តាយរបស់ខ្លួនដែរ។ ទី២ រដ្ឋាភិបាលពុំនមានលទ្ធភាពក្នុងការផ្តល់ការអប់រំមតេយ្យសិក្សាដល់កុមារភាគច្រើនទេ ដោយសារតែកង្វះខាតធនធានមនុស្សនិងសេដ្ឋកិច្ចរបស់ប្រទេស។

ការពិតទាំងនេះកំពុងគាំទ្រដល់ភាពត្រឹមត្រូវរបស់ហេតុផលនេះ។ ស្ថិតិរបស់រដ្ឋាភិបាលបានបង្ហាញថាមានតែកុមារចំនួន១៦,៨% នៃចំនួនសរុបប៉ុណ្ណោះដែលមានអាយុពី0-៦ឆ្នាំ ដែលបានទទួលការអប់រំ ( MoEYS២០១៣)។ ការអង្កេតរបស់យើងបានរកឃើញថាមានម៉ែចំនួន ៤៥% ដែលមិនអាចអាននិងសរសេរ និងបានរកឃើញថា មានកុមារចំនួន៤៨% ដែលគ្រប់អាយុចូលរៀនមតេយ្យសិក្សា (៣-៥ ឆ្នាំ) ពុំបានទទួលការអប់រំថ្នាក់មតេយ្យសិក្សាទេ។ ជាងនេះទៅទៀត ការអង្កេតបានរកឃើញថា កុមារជាច្រើនកំពុងតែបាត់បង់ការគាំទ្រពីក្រុមគ្រួសារ ដែលមានសមាជិកច្រើនដែលជាប្រពៃណីរ ប្រភពនៃការគាំទ្រសំខាន់បានមកពីឪពុកម្តាយដែលមានជំនាញក្នុងការថែរក្សាកូន។
ការអង្កេតបានបង្ហាញថាមានតែគ្រួសារចំនួន ២៦% ដែលកំពុងរស់នៅក្នុងគ្រួសារដែលមានសមាជិកច្រើន ការអង្កេតបានចង្អុលបង្ហាញពីការខ្វះខាតសេវាជាសារជារណៈ ពីព្រោះរដ្ឋាភិបាលពុំមានលទ្ធភាពក្នុងការផ្តល់ចរន្តអគ្គីសនី និងផ្គត់ផ្គង់សេវាទឹកស្អាតសម្រាប់ទទួលទានរបស់ប្រជាពលរដ្ឋ។
ការអង្កេតរបស់យើងបានរកឃើញថាមានតែគ្រួសារចំនួន ១២% ភាគរយប៉ុណ្ណោះ ដែលមានភ្លើងអគ្គីសនីប្រើប្រាស់ ហើយពុំមានគ្រួសារណាដែលមានប្រព័ន្ធទឹកស្អាតដែលមានការកែលំអរទេ។

ទិសដៅចម្បងរបស់កម្មវិធីអប់រំតាមខ្នងផ្ទះ គឺការជួយដល់កុមារតូចៗដែលងាយរងគ្រោះដែលរដ្ឋាភិបាលមិនអាច

ជួយពួកគេបានតាមរយៈការអប់រំមតេយ្យសិក្សាដែលមាន។ តាមយោបល់នៃការសិក្សានេះ ទិសដៅរបស់កម្មវិធីនៅតែអាចធ្វើបាននៅក្នុងប្រទេសកម្ពុជា ហើយកម្មវិធីអប់រំតាមខ្នងផ្ទះអាចផ្តល់នូវវិធីសាស្ត្រដ៏ត្រឹមត្រូវក្នុងការសម្រេចបានទិសដៅនេះ។ ការវាយតម្លៃពីភាពងាយរងគ្រោះរបស់កុមាររបស់យើងបានរកឃើញថាកុមារចំនួន ៧៧%មានប្រភេទនៃភាពងាយរងគ្រោះមួយចំនួន ហើយកុមារចំនួន២៣% មានស្ថិតនៅក្នុងភាពងាយរងគ្រោះខ្ពស់។ កុមារមួយចំនួនកំពុងត្រូវការជំនួយ និងការធ្វើអន្តរាគមន៍ជាបន្ទាន់ ដែលជាផលវិបាកនៃការទទួលរងការឈឺចាប់របស់ខ្លួនដោយសារជម្ងឺរ៉ាំរ៉ៃ ជម្ងឺកង្វះអាហារូបត្ថម្ភ ឬពិការភាព។ ការជួយដល់កុមារទាំងនោះ និងឪពុកម្តាយរបស់ពួកគេគឺជាទិសដៅដ៏ត្រឹមត្រូវ និងមានមូលដ្ឋានលើហេតុផលដ៏រឹងមាំ។

## ការរៀបចំនិងការអនុវត្តន៍កម្មវិធី

ការរៀបចំសម្រាប់កម្មវិធីណាមួយ ត្រូវតែមានភាពសមស្របជាមួយនឹងទិសដៅ និងភាពដែលអាចសម្រេចបានរបស់វា។ យើងបានពិភាក្សាពីប្រវត្តិ និងការអនុវត្តន៍នូវកម្មវិធីអប់រំតាមខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជានៅក្នុងជំពូកទី២ នៃការសិក្សានេះ។ វាមានភាពច្បាស់លាស់ណាស់ថា ទិសដៅសំខាន់របស់អ្នករៀបចំកម្មវិធី គឺការជួយដល់កុមារដែលងាយរងគ្រោះតាមរយៈការកែលំអរនូវជំនាញសម្រាប់ការថែរក្សាកូនរបស់ឪពុកម្តាយរបស់គេ។

ចំណាប់អារម្មណ៍ដំបូងតាមរយៈឈ្មោះរបស់កម្មវិធីបានផ្តល់ឱ្យលោកអ្នកនូវគំនិតដែលថាផ្ទះគឺជាកន្លែងដែលសកម្មភាពរបស់កម្មវិធីភាគច្រើនត្រូវបានអនុវត្ត។ ប៉ុន្តែបើពិនិត្យមើលឲ្យស៊ីជំរៅទៅលើការរៀបចំកម្មវិធី អ្នកនឹងមើលឃើញថា "ផ្ទះ" កំពុងតែបាត់បង់នូវផ្នែកមួយនៃកម្មវិធី។ ដូចដែលយើងបានពិភាក្សាអំពីនៅក្នុងជំពូកទី១ នៃការសិក្សានេះ បទពិសោធន៍ជាអន្តរជាតិនៃ "កម្មវិធីអប់រំតាមខ្នងផ្ទះ" ការរៀបចំការរៀនសូត្រតាមខ្នងផ្ទះ គឺជាផ្នែកដ៏សំខាន់មួយរបស់កម្មវិធីទាំងអស់នេះ ហើយសម្រាប់ផ្នែកជាច្រើនក្នុងចំណោមនោះ គឺជាចំណុចសម្រាប់ភាពជោគជ័យរបស់ខ្លួន។ ការអប់រំតាមខ្នងផ្ទះដែលជាការរៀបចំសម្រាប់ការរៀនសូត្រមិនត្រឹមតែមានសារៈសំខាន់ក្នុងការនាំមកនូវសេវាកម្មផ្សេងៗដល់ឪពុកម្តាយប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាផ្នែកដ៏សំខាន់ក្នុងការជួយដល់កុមារតូចៗ។

នៅក្នុងការសង្កេតជាក់ស្តែងទៅលើការអនុវត្តន៍កម្មវិធី និងការសំភាសន៍ភាគីដែលពាក់ព័ន្ធរបស់កម្មវិធីក្រុមអ្នកស្រាវជ្រាវបានរកឃើញថា ការអនុវត្តសកម្មភាពនានាពុំបានធ្វើទៅតាមការណែនាំរបស់កម្មវិធីបានត្រឹមត្រូវនៅឡើយទេ។ ជាឧទហរណ៍ កម្មវិធីអប់រំកុមារតូចតាផ្ទះបានផ្តល់តួនាទីយ៉ាងសំខាន់ដល់ប្រធានភូមិ ក្នុងការជួយគាំទ្រកម្មវិធីជាពិសេសជំរុញដល់បណ្តាញក្រុមការងារពាក់ព័ន្ធការងារអប់រំកុមារតូចតាមផ្ទះ នៅក្នុងភូមិឲ្យអនុវត្តតាមការណែនាំ។ ឧទហរណ៍ផ្សេងៗទៀតចំពោះការមិនអនុវត្តតាមការរៀបចំរបស់កម្មវិធី គឺការពុំមានតួនាទីសម្រាប់សាលារៀននៅក្នុងការអនុវត្តកម្មវិធីជាក់ស្តែងនិងខ្វះក្រុមប្រឹក្សាបច្ចេកទេស។

ការសិក្សាស្រាវជ្រាវនេះពុំបានរកឃើញនូវតួនាទីដ៏សំខាន់របស់សហគមន៍ ឬតួអង្គសង្គមស៊ីវិល នៅក្នុងការអនុវត្ត កម្មវិធីទេ ។ ការសិក្សានេះបានរកឃើញថា ការអនុវត្តកម្មវិធីជាក់ស្តែង ត្រូវបានគ្រប់គ្រងដោយមន្ត្រីការិយាល័យ អប់រំស្រុក ដែលមានការទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលម៉ែៗដែលជាប្រធានក្រុម និងត្រួតពិនិត្យមើលទៅលើសកម្មភាពរបស់កម្មវិធីផ្សេងៗ។

សេចក្តីសន្និដ្ឋានចំពោះហេតុផលដែលនៅពីក្រោយភាពខុសផ្លែកគ្នា រវាងការរៀបចំកម្មវិធី និងការអនុវត្តន៍របស់វាគឺៈ ១) មិនមានគោលការណ៍ណែនាំអនុវត្តអោយបានច្បាស់លាស់សម្រាប់អនុវត្តន៍កម្មវិធីពីសំណាក់ភាគីដែលពាក់ព័ន្ធ ភាគច្រើន។ ២) សមត្ថភាពរបស់ភាគីដែលពាក់ព័ន្ធនៅមានកម្រិតនៅឡើយ។ ៣) ការខ្វះខាតនូវនីតិវិធីក្នុងការត្រួតពិនិត្យ និងវាយតម្លៃពីសំណាក់អង្គការនានាដែលទទួលខុសត្រូវលើការអនុវត្តន៍កម្មវិធី។

ចំណុចខ្សោយមួយក្នុងចំណោមចំណុចខ្សោយសំខាន់ៗនៃការរៀបចំកម្មវិធី គឺការពុំមានយន្តការក្នុងការវាស់វែងពីសេវាកម្មដែលគេមានបំណងផ្តល់ទៅឲ្យអ្នកទទួលផលរបស់កម្មវិធីទេ។ ការអង្កេតបានរកឃើញថាមានវគ្គបណ្តុះបណ្តាល២-៤ ដងដែរសម្រាប់ប្រធានក្រុមម៉ែៗក្នុងមួយឆ្នាំ។ ក្រៅពីសកម្មភាពនៃការបណ្តុះបណ្តាល ពុំមានសូចនាករដែលអាចជឿជាក់បានអំពីការប្រតិបត្តិ សកម្មភាពផ្សេងៗរបស់កម្មវិធីទេ លើកលែងតែលទ្ធផលនិងគុណភាពរបស់កម្មវិធី។ ការអង្កេតបានរកឃើញថា ម៉ែៗដែលជាប្រធានក្រុមចំនួន ៨៤% ពុំបានរៀបចំការប្រជុំជាផ្លូវការជាមួយម៉ែដែលជាសមាជិកផ្សេងៗទៀតបានទៀងទាត់នោះទេ។ ការប្រជុំជាផ្លូវការនៅទីនេះ យើងចង់សំដៅទៅដល់ការប្រជុំដែលរៀបចំឡើងយ៉ាងល្អិតល្អន់ដើម្បីផ្តល់នូវការណែនាំនិងបទពិសោធន៍របស់កម្មវិធី។
ការអង្កេតបាន បង្ហាញថាម្តាយចំនួន ៣៣% ដែលបានចូលរួមនៅក្នុងកម្មវិធីអប់រំតាមខ្នងផ្ទះ ពុំបានស្គាល់ប្រធានក្រុមរបស់ខ្លួនទេ ហើយម្តាយចំនួន៦៥% ដែលបានចូលរួមនៅក្នុងកម្មវិធីនេះបាននិយាយថា ពួកគាត់បានចូលរួមសកម្មភាព១-២លើកដែរ សម្រាប់រយៈពេលមួយឆ្នាំកន្លងមកនេះ ៣០% បានចូលរួមសកម្មភាព៣-៤ដង និង៥%មិនអាចចងចាំ បាននូវសកម្មភាពណាមួយក្នុងរយៈពេលដូចគ្នានេះទេ។

ការអង្កេតបានរកឃើញថាម៉ែៗចំនួន ២៩% បានឆ្លើយតបជាវិជ្ជមាន ចំពោះសំណួរថា តើពួកគាត់បានចូលរួមនៅក្នុងសកម្មភាពណាមួយដើម្បីកែលំអរជំនាញរបស់ខ្លួនក្នុងការថែរក្សាកូនដែរឬទេ។ ម៉ែៗចំនួន១៤នាក់ក្នុងចំណោមនោះបានលើកឡើងថា ពួកគាត់បានចូលរួមនៅក្នុងសកម្មភាពនានា ដែលតម្រង់ទៅរកការបង្កើនចំណេះដឹងរបស់ខ្លួនអំពីការមានផ្ទៃពោះ ២០នាក់បានលើកឡើងពីអាហារូបត្ថម្ភសម្រាប់កូន ៣១នាក់បានលើកឡើងពីទំលាប់ធ្វើឲ្យកូនមានអនាម័យ ២១នាក់បាននិយាយពីការបង្រៀនកូនឲ្យចេះអាន និងសរសេរជាមូលដ្ឋាន។ ការអង្កេតបានរកឃើញថា សកម្មភាពដែលម៉ែៗទាំងនោះចងចាំបំផុត គឺសកម្មភាពទាំងឡាយណាដែលធ្វើឡើងនៅក្នុងការប្រជុំ ឬទីកន្លែងសារធារណៈនិងមិនមែនការប្រជុំទាំងឡាយណាដែលធ្វើឡើងជាមួយប្រធានក្រុមម៉ែ ដូចដែលគេសន្មតថាកម្មវិធីតាមខ្នងផ្ទះទេ។សំណួរសួរថាតើអ្វីតម្លៃនិងគុណភាពព័ត៌មានដែលត្រូវបានគេផ្តល់ឲ្យដល់ម៉ែៗតាមរយៈកម្មវិធី។

## លទ្ធផល និងឥទ្ធិពលរបស់កម្មវិធី

ជំហានដំបូងសម្រាប់វាយតម្លៃលទ្ធផល និងឥទ្ធិពលរបស់កម្មវិធីណាមួយ គឺត្រូវរកឲ្យឃើញនូវរបៀបទាំងឡាយណាដែលបានទទួលផលប្រយោជន៍ពីការអនុវត្តកម្មវិធី។ ដំបូងការរៀបចំកម្មវិធីដើម្បីតម្រង់ទៅរកម្តាយរបស់កុមារដែលពុំទទួលបានផលប្រយោជន៍ពីកម្មវិធីមតេយ្យសិក្សាផ្សេងៗទៀត។ ការអង្កេតបានរកឃើញថាម្តាយចំនួន ៥៤% បានបំពេញលក្ខណៈវិនិច្ឆ័យនេះ។ ប៉ុន្តែមានម្តាយចំនួន១៦% ប៉ុណ្ណោះក្នុងចំណោមពួកគាត់ដែលកំពុងចូលរួមកម្មវិធីអប់រំតាមខ្នងផ្ទះ។ ចំណុចដៅទី២ សម្រាប់កម្មវិធីគឺម៉ែៗទាំងអស់ដែលមានកូនតូចៗដែលពួកគេមិនអាចទទួលបានផលប្រយោជន៍ពីកម្មវិធី។ នៅទីនេះការអង្កេតបង្ហាញថា ម៉ែៗចំនួន៧៣%ដែលបានសំភាសន៍ពុំបានចូលរួមនៅក្នុងកម្មវិធីអប់រំតាមខ្នងផ្ទះទេ។ នេះគឺជាសូចនាករនៃលទ្ធផល និងឥទ្ធិពលដែលនៅមានកម្រិតនៃផលវិបាករបស់កម្មវិធី ដោយសារចំនួននៃអ្នកទទួលផលរបស់កម្មវិធីនៅមានកម្រិត។

កម្មវិធីនានាដែលដូចគ្នា នឹងកម្មវិធីអប់រំតាមខ្នងផ្ទះកំពុងតែតម្រង់ទៅរកការជួយកុមារដែលងាយរងគ្រោះ និងកាត់បន្ថយភាពងាយរងគ្រោះរបស់កុមារ។ កម្មវិធីអប់រំតាមខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជាមានគោលបំណងដូចគ្នាដែរតាមរយៈការអប់រំម៉ែៗដែលមានកូនតូចៗ ដែលអាចកាត់បន្ថយភាពងាយរងគ្រោះរបស់កុមារនៅក្នុងទិដ្ឋភាពសំខាន់ៗ២ គឺសុខភាព និងការអប់រំ។ សំណួរដដែលៗរបស់ទិដ្ឋភាពទាំង២នេះ បានបង្ហាញឲ្យឃើញដោយខ្លួនឯងនូវសកម្មភាព និងអត្ថបទរបស់កម្មវិធីដែលភាគច្រើននៃសម្ភារៈសម្រាប់ការអប់រំ សម្រាប់គម្រោងតម្រង់ទៅរកការអប់រំម៉ែៗពីផ្នែកសុខភាព និងអប់រំ។ ជាការត្រឹមត្រូវលទ្ធផល និងឥទ្ធិពលល្អរបស់កម្មវិធីមានន័យថា កុមារងាយរងគ្រោះមានចំនួនតិចនៅតាមតំបន់ដែលកម្មវិធីត្រូវបានគេអនុវត្ត និងតម្រង់ទៅរកកុមារ។ នៅក្នុងឃ្លាខាងក្រោមការសន្មតនេះនឹងត្រូវបានគេធ្វើតេស្តសាកល្បង ដោយយោងទៅលើការសិក្សាពីការវាយតម្លៃពីភាពងាយរងគ្រោះ របស់កុមារ។

តារាងទី១៦ បង្ហាញពីលទ្ធផលនៃការវាយតម្លៃពីភាពងាយរងគ្រោះសម្រាប់កុមារដែលមានអាយុពី ៣-៥ ឆ្នាំ ដែលកុមារទាំងអស់នោះ គឺជាក្រុមគោលដៅដ៏ចំបងរបស់កម្មវិធីអប់រំតាមខ្នងផ្ទះ។ លទ្ធផលត្រូវបានគេបែងចែកជាក្រុម៖ កុមារដែលចូលរៀននៅមតេយ្យសិក្សា (មតេយ្យសិក្សារដ្ឋនិងសហគមន៍) កុមារដែលមិនទទួលបានសេវាអប់រំកុមារតូចណាមួយ និងកុមារដែលម៉ែៗបានចូលរួមនៅក្នុងកម្មវិធីអប់រំតាមខ្នងផ្ទះ។ ព័ត៌មានដែលទាក់ទងបំផុតទៅនឹងការអះអាងនៅទីនេះគឺភាគរយរបស់កុមារដែលមានភាពងាយរងគ្រោះខ្ពស់។ តារាងនេះបង្ហាញពីភាគរយរបស់កុមារដែលចូលរួមក្នុងកម្មវិធីអប់រំតាមខ្នងផ្ទះ ដែលមានចំនួនខ្ពស់ជាង ក្រុម២ផ្សេងទៀតបន្តិចដែលជាការចង្អុលបង្ហាញថា កម្មវិធីពុំសម្រេចបានលទ្ធផលណាមួយនៅក្នុងផ្នែកនេះទេ។

តារាងទី១៧ បង្ហាញពីផ្នែកផ្សេងទៀតនៃការប្រៀបធៀបការវាយតម្លៃភាពងាយរងគ្រោះរបស់កុមារ រវាងក្រុម

ចំនួន២៖ ក្រុមទី១ គឺក្រុមកុមារដែលកំពុងរស់នៅក្នុងភូមិដែលកម្មវិធីអប់រំតាមខ្នងផ្ទះត្រូវបានគេអនុវត្ត និងក្រុមទី២ គឺជាក្រុមកុមារដែលរស់នៅក្នុងភូមិដែលមិនមានអនុវត្តកម្មវិធីអប់រំតាមខ្នងផ្ទះទេ។ ទិន្នន័យបង្ហាញពីភាគរយរបស់កុមារដែលពុំមានភាពងាយរងគ្រោះនៅក្នុងភូមិដែលបានអនុវត្តកម្មវិធីអប់រំតាមខ្នងផ្ទះ មានចំនួនខ្ពស់ជាងភាគរយកម្រិតនៃភាពងាយរងគ្រោះ ដូចគ្នានៅក្នុងភូមិដែលពុំមានអនុវត្តកម្មវិធីអប់រំតាមខ្នងផ្ទះ។ នៅក្នុងពេលដូចគ្នានេះដែរភាគរយរបស់កុមារដែលស្ថិតនៅក្នុងកម្រិតនៃភាពងាយរងគ្រោះខ្ពស់មានចំនួនខ្ពស់ជាង បើប្រៀបធៀបជាមួយ នឹងសមភាគីរបស់ខ្លួននៅក្នុងភូមិដែលពុំមានការអនុវត្តកម្មវិធីអប់រំតាមខ្នងផ្ទះ។ លទ្ធផលនៃការប្រៀបធៀបនេះ គឺជាសូចនាករដ៏ទៃទៀត ដែលកម្មវិធីពុំបានធ្វើឲ្យមានឥទ្ធិពលច្រើនសម្បើម ចំពោះស្ថានភាពនៃភាពងាយរងគ្រោះរបស់កុមារនៅក្នុងកម្រិតមួយដែលធ្វើឲ្យមានការផ្លាស់ប្តូរ ចំពោះជិវិតរស់នៅរបស់អ្នកទទួលផលទេ។ តារាងទី១៧ ក៏បង្ហាញដែរថាកម្មវិធីពុំបានផ្តល់នូវលទ្ធផលគួរឲ្យកត់សំគាល់ណាមួយចំពោះការបង្កើនការចុះឈ្មោះចូលរៀន និងស្ថានភាពសុខភាពរបស់កុមារទេ។

តារាងទី ១៦ - ភាពងាយរងគ្រោះរបស់កុមារដែលមានអាយុពី ៣-៥ឆ្នាំ ដោយយោងទៅលើការទទួលបានកម្មវិធីមតេយ្យសិក្សារបស់ខ្លួន

| កុមារអាយុពី ៣-៥ឆ្នាំ | សរុប | ពុំមានភាពងាយរងគ្រោះ | | មានភាពងាយរងគ្រោះទាប | | មានភាពងាយរងគ្រោះមធ្យម | | មានភាពងាយ រងគ្រោះខ្ពស់ | |
|---|---|---|---|---|---|---|---|---|---|
| | | # | % | # | % | # | % | # | % |
| កុមារដែលចុះឈ្មោះចូលរៀននៅមត្តេយ្យសិក្សារដ្ឋ/សហគមន៍ | ២៧២ | ៦៨ | ២៥ | ៦៧ | ២៥ | ៩២ | ៣៤ | ៤៥ | ១៦ |
| កុមារពុំទទួលបានកម្មវិធីមត្តេយ្យសិក្សាណាមួយ | ១៨៥ | ៤៨ | ២៨ | ៤០ | ២៤ | ៥៣ | ៣១ | ៤៤ | ១៧ |
| កុមារដែលស្ថិតនៅក្នុងកម្មវិធី HB ប៉ុណ្ណោះ | ៣២ | ៩ | ២៨ | ៩ | ២៨ | ៨ | ២៥ | ៦ | ១៩ |

តារាងទី ១៧ - ភាពងាយរងគ្រោះរបស់កុមារនៅក្នុងភូមិដែលបានអនុវត្តកម្មវិធីអប់រំតាមខ្នងផ្ទះ និងភូមិដែលពុំមានអនុវត្តកម្មវិធីនេះ

| ភូមិ | កុមារសរុប | | ពុំមានភាពងាយរងគ្រោះ | | មានភាពងាយរងគ្រោះទាប | | មានភាពងាយរងគ្រោះមធ្យម | | មានភាពងាយរងគ្រោះខ្ពស់ | | កុមារដែលគ្រប់អាយុ ចុះឈ្មោះចូលរៀនពី ៦-១៥ឆ្នាំ | | | | កុមារដែលមានជម្ងឺរ៉ាំ រ៉ៃ និងកុមារពិការ | | មានជម្ងឺកាល ពី៦ខែមុន | | ធ្លាប់ទទួលបានការ ពិនិត្យជម្ងឺពីវេជ្ជបណ្ឌិតក្នុងរយៈពេល៦ខែកន្លងមក | | សម្រាកពេទ្យកាលពីឆ្នាំមុន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | មិនបានចុះឈ្មោះ | | បានចុះ ឈ្មោះ | | | | | | | | | |
| | # | % | # | % | # | % | # | % | # | % | # | % | # | % | # | % | # | % | # | % | # | % |
| ដោយពុំមានកម្មវិធីអប់រំតាមខ្នងផ្ទះ | ៤៤៥ | ៣៤ | ១២២ | ២៧ | ១១៣ | ២៦ | ១១១ | ២៥ | ៩៩ | ២២ | ៣៤ | ១៨ | ១៥១ | ៨២ | ២១ | ៥ | ៤៦ | ១០ | ៦៣ | ១៤ | ៤៣ | ១០ |
| មានអនុវត្តកម្មវិធីអប់រំតាមខ្នងផ្ទះ | ៨៥៥ | ៦៦ | ១៧៦ | ២១ | ១៩៨ | ២៣ | ២៧៦ | ៣២ | ២០៥ | ២៤ | ៦៦ | ១៨ | ៣០០ | ៨២ | ៣៨ | ៤ | ៩៤ | ១១ | ១១៨ | ១៤ | ៧១ | ៨ |

## ៦.ការពិភាក្សាចុងក្រោយនិងអនុសាសន៍

ការជួយដល់កុមារដែលងាយរងគ្រោះ គឺជាបេសកកម្មចំបងរបស់អង្គការ មិនមែនរដ្ឋាភិបាលដែលមិនរកផលចំណូល។ សម្រាប់រដ្ឋាភិបាល ការជួយដល់កុមារដែលងាយរងគ្រោះគឺជាភារកិច្ចមួយ និងជាសញ្ញាមួយនៃអភិបាលកិច្ចល្អ។ គោលនយោបាយយុទ្ធសាស្ត្រកម្មវិធី និងគម្រោងនានាត្រូវបានដឹកនាំដោយ ទិសដៅនៃការជួយដល់កុមារដែលងាយរងគ្រោះ។ នៅក្នុងប្រទេសក្រីក្រដូចជាប្រទេសកម្ពុជា កុមារដែលងាយរងគ្រោះមានចំនួនច្រើនភាពជោគជ័យនៃការជួយដល់កុមារទាំងនោះ មិនត្រឹមតែជាការកែតម្រូវបច្ចុប្បន្នភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការកសាងអនាគតផងដែរ។

ដូចដែលយើងបានពិភាក្សានៅក្នុងជំពូកខាងដើម ការសិក្សាស្រាវជ្រាវនេះកម្មវិធីអប់រំតាមខ្នងផ្ទះ បានផ្តួចផ្តើមឲ្យមានការជួយកុមារដែលងាយរងគ្រោះ។ ភាពងាយរងគ្រោះរបស់កុមារកើតចេញពីលក្ខខណ្ឌនៃភាពក្រីក្រនិងការមិនរាប់រករបស់សង្គម។ កម្មវិធីនេះមានមូលដ្ឋានលើហេតុផលដែលមានសុពលភាព ហើយបទពិសោធជាក់ស្តែងរបស់កម្មវិធីបានចង្អុលបង្ហាញពីផលប្រយោជន៍របស់កម្មវិធី ចំពោះអ្នកទទួលផល។ កម្មវិធីអប់រំតាមខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជាពុំមានភាពខុសគ្នាទេ ចំពោះទិសដៅរបស់វាបើប្រៀបធៀបជាមួយនឹង កម្មវិធីអប់រំតាមខ្នងផ្ទះផ្សេងៗទៀតនៅជុំវិញពិភពលោក។ ស្របពេលជាមួយគ្នានេះដែរលក្ខណៈពិសេសនៃភាពក្រីក្ររបស់ប្រទេសកម្ពុជា និងការដោះស្រាយនូវមរតកពីអតីតកាលមានលំអានរបស់វាទៅលើការអនុវត្តកម្មវិធី។

ការវាយតម្លៃកម្មវិធីនៅក្នុងប្រទេសកម្ពុជាពុំមែនជារឿងងាយស្រួលទេ បើគិតគូរពិចារណាទៅលើការពិតដែរថាពុំមានការសិក្សាច្រើនពីកម្មវិធីនេះទេ ព្រមទាំងមានការខ្វះខាតនូវនិតិវិធីសម្រាប់ការរៀបចំចងក្រងឯកសារ ការត្រួតពិនិត្យនិងការវាយតម្លៃកម្មវិធី។ ការវាយតម្លៃនេះត្រូវបានគេព្យាយាមដើម្បីវាស់វែងពីភាពងាយរងគ្រោះរបស់កុមារ ដោយផ្អែកលើកត្តាដែលជាទិសដៅមួយចំនួនដែលអាចអនុវត្តបាន ចំពោះបរិយាកាសផ្នែកសង្គមនិងរូបវន្តរបស់កុមារ។ លទ្ធផលនៃការវាយតម្លៃទៅលើកុមារចំនួន១៣០០នាក់ គឺស្របជាមួយនឹងការពិតជាក់ស្តែងនៃសង្គមកម្ពុជា ព្រមទាំងលទ្ធផលនៃការអង្កេតថ្នាក់ជាតិមួយចំនួន។ វិធីសាស្ត្រនៃការវាយតម្លៃពីភាពងាយរងគ្រោះរបស់កុមារអាចត្រូវបានគេប្រើប្រាស់ជាឧបករណ៍នៅក្នុងគម្រោងអភិវឌ្ឍណាមួយ ដែលតម្រង់ទៅរកការកែលំអរស្ថានភាពរបស់កុមារ។ ការសិក្សានេះបានបង្ហាញភស្តុតាងថា គេអាចប្រើប្រាស់វាជាឧបករណ៍វាយតម្លៃក្រៅពីវិធីសាស្ត្រវាយតម្លៃផ្សេងទៀត។

ការសិក្សានេះបញ្ជាក់ថា ពុំមែនមានតែការខ្វះខាតនូវធនធានសម្រាប់គ្រប់គ្រងការអនុវត្តគម្រោង នៅក្នុងប្រទេសកម្ពុជាទេ ប៉ុន្តែក៏មានការខ្វះខាតនូវការទទួលយកផ្នែកអារម្មណ៍ដើម្បីធ្វើអ្វីមួយ តិចជាងអ្វីដែលយើងត្រូវធ្វើដោយសារការខ្វះខាតធនធានរបស់យើង។ អារម្មណ៍ត្រូវបានគេសំដៅទៅរក( ការធ្វើអ្វីមួយ វាប្រសើរជាជាងការមិនធ្វើអ្វីទាំងអស់ )។វាមិនមែនជាការខ្មាស់អៀនទេក្នុងការខកខានចំពោះការអនុវត្តកម្មវិធីអភិវឌ្ឍណាមួយ។

សំណួរគឺ តើយើងត្រូវធ្វើដូចម្ដេច? ឬថាតើមានវិធីសាស្ត្រមួយដើម្បីកែលំអរកម្មវិធីនេះ និងធ្វើឲ្យមានការផ្លាស់ប្ដូរជាដុំកំភួនចំពោះការរៀបចំ និងការអនុវត្តន៍របស់វាដើម្បីឲ្យទទួលបានជោគជ័យ?

យើងដាក់សំណួរទាំងនេះសម្រាប់ឲ្យក្រុមពិភាក្សាដែលបានចូលរួមនៅក្នុងកម្មវិធីអប់រំតាមខ្នងផ្ទះ ដែលបានរៀបចំឡើងចំនួន២លើកសម្រាប់គោលបំណងនេះ។ ចំណុចខាងក្រោមសង្ខេបពីយោបល់អ្នកទាំងនោះ ៖

១).ពួកគាត់ជឿថា កម្មវិធីបានទទួលជោគជ័យមួយចំនួនដែរ នៅក្នុងការផ្លាស់ប្ដូរជីវិតរបស់កុមារនៅតាមភូមិដែលកម្មវិធីបានអនុវត្ត។ ពួកគាត់មួយចំនួនបានលើកឡើងថា កម្មវិធីបានទទួលលទ្ធផលជាវិជ្ជមានមួយចំនួន ដូចជាការបង្កើនចំណេះដឹងរបស់ក្នុងការថែរក្សាកូន ការបង្កើនការចុះឈ្មោះចូលរៀននិងកាត់បន្ថយអំពើហឹង្សាលើកុមារ។ ពួកគាត់ធ្វើការសន្និដ្ឋានទាំងនេះ ដោយផ្អែកលើការសង្កេតផ្ទាល់ខ្លួនក្នុងពេលដែលពួកគាត់ចុះត្រួតពិនិត្យតំបន់ដែលអនុវត្តកម្មវិធីនេះ ឬពិភាក្សាជាមួយភាគីដែលពាក់ព័ន្ធ។

២).ពួកគាត់ខ្លះបានឃើញការគាំទ្ររបស់អង្គការអន្តរជាតិចំពោះកម្មវិធីនេះ ដូចជាUNICEF និងធនាគាពិភពលោកថា ជាភស្តុតាងមួយនៃការទទួលជោគជ័យរបស់កម្មវិធី។

៣).ពួកគាត់គិតថា កម្មវិធីអប់រំតាមខ្នងផ្ទះ នៅតែជាជម្រើសតែមួយគត់សម្រាប់កុមារតូច ដែលពុំមានកម្មវិធីអប់រំមតេយ្យសិក្សាថ្នាក់កណ្ដាលផ្សេងៗទៀត។ ក្នុងពេលជាមួយគ្នានេះដែរពួកគាត់ក៏ឯកភាពដែថា មានចន្លោះប្រហោងខ្លះក្នុងការអនុវត្តកម្មវិធី។

៤).ពួកគាត់បានឯកភាពថាកម្មវិធីបន្ត ប៉ុន្តែពួកគាត់មានការខ្វែងគំនិតគ្នា ថាតើកម្មវិធីគួរមិនកែលំអរឲ្យប្រសើរឬយ៉ាងណា។

៥).ពួកគាត់ឯកភាពទៅលើតម្រូវការសម្រាប់កម្មវិធី និងទិសដៅដ៏ចំបងរបស់វាសម្រាប់ការជួយដល់កុមារដែលងាយរងគ្រោះ។ ពួកគាត់ចែករំលែកនូវគំនិតដែលចាំបាច់សម្រាប់ការពង្រឹងនិតិវិធីនៃការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី។

៦).ពួកគាត់ខ្លះគិតថា ការខ្វះខាតនូវលទ្ធផល និងឥទ្ធិពលរបស់កម្មវិធី គឺជាលទ្ធផលដែលកម្មវិធីពុំមានធនធានគ្រប់គ្រាន់។ អ្នកផ្សេងទៀតមើលឃើញថា កម្មវិធីនេះពុំទាន់បានអនុវត្តឲ្យមានរយៈពេលវែងគ្រប់គ្រាន់ដើម្បីទទួលបាននូវលទ្ធផលនិងឥទ្ធិពលដែលបានរំពឹងទុករបស់វាទេ។
ចំណែកឯអ្នកផ្សេងទៀត សុំឲ្យមានពេលវេលាច្រើនថែមទៀត។

ការសិក្សាស្រាវជ្រាវនេះផ្តល់អនុសាសន៏មួយចំនួនដូចខាងក្រោម ៖

១). ការចុះត្រួតពិនិត្យតាមផ្ទះ គឺជាស្នូលនៃកម្មវិធីអប់រំតាមខ្នងផ្ទះ ហើយវាជាចំណុចសំខាន់នៃការទទួលជោគជ័យរបស់កម្មវិធី។ ហេតុដូច្នេះហើយវាមានភាពចាំបាច់នៃការអនុវត្តកម្មវិធីនេះដែលប្រាកដថាសេវាកម្មរបស់កម្មវិធីបានទៅដល់ដៃ ឪពុកម្តាយនៅតាមផ្ទះរបស់ខ្លួន។

២).ការពង្រឹងតួនាទីរបស់អ្នកដែលមានជំនាញវិជ្ជាជីវៈនៅក្នុងកម្មវិធី។ បទពិសោធន៍ជាអន្តរជាតិរបស់កម្មវិធី ចង្អុលបង្ហាញច្បាស់លាស់ពីសារៈសំខាន់នៃតួនាទីរបស់អ្នកដែលមានជំនាញវិជ្ជាជីវៈដែលតួនាទីនេះពុំមាន នៅ ក្នុងកម្មវិធីនៅក្នុងប្រទេសកម្ពុជាទេ។

៣).សហគមន៍តាមមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល សាលារៀនត្រូវមានការទទួលខុសត្រូវនាំមុខមួយនៅក្នុងការរៀបចំចាត់ចែងកម្មវិធីនេះ។

៤).កម្មវីធីត្រូវតម្រង់ទៅរកកុមារដែលងាយរងគ្រោះបំផុតនៅក្នុងសហគមន៍ ហើយត្រូវប្រើប្រាស់ឲ្យអស់លទ្ធភាពនូវសកម្មភាពរបស់វា ដោយយោងទៅលើតម្រូវការរបស់កុមារនៅតាមភូមិនីមួយៗ។ ការវាយតម្លៃពីភាពងាយរងគ្រោះរបស់កុមារ គឺជាវិធីសាស្ត្រដែលមានប្រយោជន៍ចំពោះការរៀបចំផែនការនិងការអនុវត្តកម្មវិធី។

៥). ពង្រឹងនិតិវិធីនៃការរៀបចំចងក្រងឯកសារ ការត្រួតពិនិត្យនិងការវាយតម្លៃកម្មវិធី ។

## Bibliography


1. Anthony, Kelly K., Karen M. Gil, and Laura E. Schanberg (2003) Brief report: Parental perceptions of child vulnerability in children with chronic illness (*Journal of Pediatric Psychology* 28, no. 3 (2003)) pp185-190.

2. Baker, Amy J. L., Piotrkowski, Chaya S. & Brooks-Gunn, Jeanne (1998) The effects of the Home Instruction Program for Preschool Youngsters (HIPPY) on children's school performance at the end of the program and one year later (Early Childhood Research Quarterly, Vol. 13, No. 4 )pp 571-588

3. Baker, Amy J. L., Piotrkowski, Chaya S. & Brooks-Gunn, Jeanne (1999) The Home Instruction Program for Preschool Youngsters (HIPPY)(The Future of Children; Spring/Summer 1999; 9, 1)pp 116-133

4. Barnett, T, Roost, F. & McEachran, J (2012) Evaluating the Effectiveness of the Home interaction program for Parents and Youngsters (HIPPY) (Family Matters 2012, No. 91) pp 27-37
5. Boocock, Sarane Spence (1995) Early Childhood programs in other Nations: Goals and outcomes (The Future of Children, Vol. 5, No. 3– Winter 1995) pp 94-114
6. Bradley RH, Corwyn RF, Pipers McAdoo H, Garcia Coll C. (2001) The home environments of children in the United States part I: variations by age, ethnicity and poverty status (*Child Development* 2001;72(6)) pp. 1844–67.
7. Bronfenbrenner U, Morris P. (1998) The ecology of developmental processes. In: W Damon, RM Lerner editor(s). *Handbookof Child Psychology: Vol 1. Theoretical Models of Human Development*. 5th Edition.(Wiley, New York) pp 993–1028.
8. Brookes, S. J., Summers, J. A., Thornburg, K. R., Ispa, J. M., & Lane, V. J. (2006) Building successful home visitor–mother relationships and reaching program goals in two Early Head Start programs: A qualitative look at contributing factors ( *Early Childhood Research Quarterly*, Vol. *21*, No.1) pp 25-45.
9. Daniel, Brigid (2010) Concepts of Adversity, Risk, Vulnerability and Resilience: A Discussion in the Context of 'Child Protection System' (Social Policy & Society, Vol. 9, No. 2,) pp 231-241
10. Evangelou, M., & Sylva, K. (2003). *The effects of the peers early educational partnership (Peep) on children's developmental progress*. (DfES Publications, University of Oxford)
11. Field, F. (2010) *The foundation years: preventing poor children becoming poor adults, the report of the Independent Review on Poverty and Life Chances* (HM Government, UK).

12. Ford, D. M & Lerner, R. M. (1992) Development systems theory (Sage, CA, USA)

13. Gomby, D. S., Culross, P. L., & Behrman, R. E. (1999) Home visiting: Recent program evaluations: Analysis and recommendations (*The Future of Children*, Vol. 9, No. 1, Spring-Summer 1999) pp 4-26.
14. Iltus, Selim (2006) Significance of home environments as proxy indicators for early childhood care and education (UNSCO, 2007/ED/EFA/MRT/PI/16)

15. Johnson, U. Y., Martinez-Cantu, V., Jacobson, A. L., & Weir, C. M. (2012). The Home Instruction for Parents of Preschool Youngsters Program's Relationship with Mother and School Outcomes (*Early Education & Development*, Vol. *23*, No. 5) pp 713-727.

16. Kaplan GA, Turrell G, Lynch JW, Everson SA, Helkala EL, Salonen JT (2001) Childhood socioeconomic position and cognitive function in adulthood ( International Journal of Epidemiology 2001;30(2)) pp 256–63.
17. Korfmacher, J., Green, B., Staerkel, F., Peterson, C., Cook, G., Roggman, L., ... & Schiffman, R. (2008). Parent involvement in early childhood home visiting. In *Child and Youth Care Forum* (Vol. 37, No. 4, 2008, Springer Netherlands) pp. 171-196
18. Lee, S. M., & Olesen, N. W. (2001). Assessing for alienation in child custody and access evaluations (*Family Court Review*, *39*, no. 3 (2001)) pp282-298

19. Leung, C., Tsang, S., & Dean, S. (2010) Evaluation of a program to educate disadvantaged parents to enhance child learning (*Research on Social Work Practice*, Vol. *20*, No. 6) pp 591-599.
20. Leung, C., Tsang, S., & Dean, S. (2011). Outcome Evaluation of the Hands-On Parent Empowerment (HOPE) Program (*Research on Social Work Practice*, Vol. *21*, No. 5, 2011) pp. 549-561
21. Lucas P, McIntosh K, Petticrew M, Roberts HM, Shiell A. (2008) Financial benefits for child health and well-being in low income or socially disadvantaged families in developed world countries. *Cochrane Database of Systematic Reviews* 2008,Issue 2. [DOI: 10.1002/14651858.CD006358.pub2]
22. Magnusson, D (1995) Individual development: A holistic integrated model. In P. Moen, G. H. Elder & K. Luscher (Eds.) Examining lives in context, pp 19-60 (American Psychological Association, Washington, DC, USA)

23. Marmot, Michael, and R. Bell (2012) Fair society, healthy lives (Public *Health, Vol. 126, Supplement 1, September* 2012) pp S4-S10
24. Matthews KA, Gallo, LC, Taylor, SE. (2010) Are psychosocial factors mediators of socioeconomic status and health connections?. *Annals of the New York Academy of Sciences* 2010;1186:146–73.

25. Miller, S., Maguire, L. K., Macdonald, G. (2012) Home-based child development interventions for preschool children from socially disadvantaged families. (Campbell Systematic Reviews 2012: No.1) DOI: 10.4073/csr.2012.1. Also. Could find online on: www.campbellcollaboration.org/lib/download/1658/
26. MoEYS (2010) Education Strategic Plan 2009-2013. Could find online MoEYS website, link address is http://www.moeys.gov.kh/en/policies-and-strategies/73-policies/89-2012-08-22-08-22-12.html

27. MoEYS (2013) The Education, Youth and Sport performance in the Academic Year 2012 -2012 and Goals for the Academic Year 2012-2013 (Education Congress Papers, 18-20 march 2013, Phnom Penh). All the congress documents could find online on MoEYS website, link address is http://www.moeys.gov.kh/en/education-congress-2013.html
28. Najman JM, Aird R, Bor W, O'Callaghan M, Williams GM, Shuttlewood GJ. (2004) The generational transmission of socioeconomic inequalities in child cognitive development and emotional health (*Social Science and Medicine* 2004;58 (6)) pp 1147–58.
29. Powell, Christine (1999) Overview of early child-care and education programmes and Jamaican case studies (*FOOD AND NUTRITION BULLETIN-UNITED NATIONS UNIVERSITY-* Vol. 20, no. 1,1999) pp 108-120
30. Rao, N., & Pearson, E. (2007). An evaluation of early childhood care and education programmes in Cambodia (*UNICEF, Geneva) online: http://www. unicef. org/evaldatabase/files/CBD_early_childhoodcare_evaluation. pdf*.
31. Rao, Nirmala & others (2012). Is Something Better Than Nothing? An Evaluation of Early Childhood Programs in Cambodia (Child Development, May/June 2012, Vol. 83, No. 3) pp 864-876

32. Schoon I, Sacker A, Bartley M. (2003) Socio-economic adversity and psychosocial adjustment: a developmental contextual perspective (*Social Science and Medicine* 2003;57(6))pp 1001–15.
33. Sektnan M, McClelland MM, Acock A, Morrison FJ. (2010) Relations between early family risk, children's behavioural regulation, and academic achievement (*Early Childhood Research Quarterly* 2010; Vol. 25, No. 4)pp 464–479.
*34.* Siddiqi A, Irwin LG, Hertzman C. (2007) *Towards Environment Assessment Model for Early Childhood Development . Evidence Report for the World Health Organization's Commission on the Social Determinants of Health*. Vancouver, BC: Human Early Learning Partnership (HELP), 2007.
*35.* Slavin, R. E. (2008). Perspectives on evidence-based research in education—What works? Issues in synthesizing educational program evaluations (*Educational Researcher*, Vol. *37,* No. 1) pp 5-14.
36. Wachs, T. D. (1992) The nature of nurture (Sage, CA, USA)

37. Wachs, T. D. (2000) Necessary but not sufficient (American Psychological Association, Washington, DC, USA)

38. Wagner, M. M., & Clayton, S. L. (1999) The Parents as Teachers program: Results from two demonstrations (*The Future of Children*, Vol.9, No.1, Spring-Sumer 1999)pp 91-115
39. Westheimer, M (1997) Ready or Not: One Home-based Response to the School Readiness Dilemma (*Early Child Development and Care*, Vol. *127*, No.1) pp. 245-257.
40. White, K. R., Taylor, M. J., & Moss, V. D. (1992) Does research support claims about the benefits of involving parents in early intervention programs?(*Review of Educational Research*, Vol. *62, No.*1, Spring 1992 )pp. 91-125
41. World Bank (2012) KH-Education For All Fast Track Initiative Catalytic Fund (P109925): implementation Status & Results (Report No. ISR8903). Available online: http://www-wds.worldbank.org/external/default/WDSContentServer/WDSP/EAP/2012/12/18/090224b08181c14b/1_0/Rendered/PDF/Cambodia000KH00Report000Sequence008.pdf

